ក្រុមជំនុំទំនៀមទម្លាប់

COMMISSION DES MŒURS & COUTUMES

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣១ លេខ ៧ ខែកក្កដា

ព. ស. ២៥០២ គ. ស. ១៩៥៩

ភ្នំពេញ

LIBRARY BUDDHIST INST
៧ប

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង

**ផ្នែកសាសនា** — ទំព័រ

- អំពីការត្រឡប់ខ្លួន លោក ស៊ុន-ហ៊ាន រៀបរៀង . . . . . . . ៧២៥
- តិលមុដ្ឋិជាតក ព្រះញាណកោសល ញាណ.ឈិន រៀបរៀង . . . . . ៧៣៤
- សុភជាតក (តមក) លោក ថង-វង់ ចម្លងពីសាស្ត្រាស្លឹករឹត . . . ៧៥៣

**ផ្នែកអក្សរសាស្ត្រ**

- រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន លោក ភ៊យ-ពុក រៀបរៀង. . . . ៧៧៣
- រឿងមរណមាតា លោក ប៊ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត . . . . . ៧៨៤
- រឿងព្រេង ថែងអំពីអ្នកប្រើគំនិតខុសនាំឲ្យមានទុក្ខដល់ខ្លួន លោក ម៉ុន-អេង រៀបរៀង ៧៩៣
- រឿងហង្សយន្ត (តទៅ) លោក អ៊ឹម-ភន ចម្លងពីសាស្ត្រាស្លឹករឹត . . . . ៨០១
- ទំនៀមកាន់ទុក្ខសពនៃសាមញ្ញជនជាតិខ្មែរ លោក ប៊ូ-ប៉ូ រៀបរៀង . . . ៨១៩
- រឿងសាមកុក (តមក) ឧកញ៉ា ទួ-កន ប្រែ . . . . . . . . . ៨២៣

**ផ្នែកកំណត់ទិន្នប្រវត្តិការណ៍**

- ពត៌មានផ្សេងៗ របស់ក្រសួងធម្មការ . . . . . . . . . . . . ៨៣៥
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង. . . . ៨៣៨

មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃជាវ ២៣០១០០

# KAMBUJASURIYA

Revue religieuse et littéraire
éditée par l'Institut Bouddhique

## sommaire

### Partie religieuse :


— La manière de se tourner par M. SIN-HEAN . . . . . . 725
— Tilamuthijâtaka par Preah Nhean Kosal NHEAN-CHHŒUN 734
— Surabajataka (suite) recueilli du manuscrit sur feuilles de latanier par M. THANG-VONG . . . . . . . 753


### Partie littéraire :


— Contes et Légendes du Japon par M. RAY-BUC . . . . . 773
— Histoire de Marana Mâtâ recueillie du manuscrit sur feuilles de latanier par M. By-Suvann . . . . . . . . . 784
— La pensée fausse conduit l'homme à la misère par M. MAN-ENG. . . . . . . . . . . 793
— Histoire de Hang-Yon (suite) recueillie du manuscrit sur feuilles de latanier par M. IM-PHON . . . . . . . 800
— Le deuil selon la coutume cambodgienne par M. BOU-PO . 819
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 823


### Notes et Chroniques :


— Nouvelles diverses du Ministère des Cultes . . . . . . 835
— Dictionnaire Sanskrit-Khmer (suite) par vén. PANG-KHAT . 838



Prix d'abonnement annuel (comprenant 12 numéros) : 230$00

## ផ្នែកសាសនា

### វិចារណកថា

# អំពីការត្រឡប់ខ្លួន

លោក ស៊ិន - ហ៊ាន រៀបរៀង

បុគ្គលណាធ្វើអំពើបាបហើយ បិទខ្ទប់អំពើបាបនោះ ដោយកុសល គឺអរហត្តមគ្គបាន បុគ្គលនោះឈ្មោះថា ញុំាងនូវលោកនេះ ឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្ររះផុតពាកពពក ។

(អង្គុលិមាលត្ថេរ គាថាធម្មបទ)

បុគ្គលណាមួយ កាលពីមុនប្រមាទហើយ លុះកាលជាខាងក្រោយ មិនប្រមាទវិញ បុគ្គលនោះឈ្មោះថា ញុំាងនូវលោកនេះ ឲ្យភ្លឺច្បាស់ ដូចព្រះចន្ទ្ររះផុតពាកពពក ។

(សម្មជ្ជនត្ថេរ គាថាធម្មបទ)

អធិប្បាយៈ កាលបើយើងពិចារណាដោយម៉ត់ចត់ចំពោះពាក្យប្រៀនប្រដៅខាងព្រះពុទ្ធសាសនា តាមទំនងពុទ្ធភាសិតខាងលើនេះ តែងបាន ជួបប្រទះនូវគោលវិជ្ជាធម៌នៃការត្រឡប់ខ្លួននេះ មាននៅច្រើនកន្លែង ព្រម ទាំងមានសេចក្ដីជ្រាលជ្រៅគួរធ្វើទុកក្នុងចិត្តរាប់ពាន់ ៗ ពុទ្ធសាសនាបាន ចោលពន្លឺមកលើផែនដីកម្ពុជាតាំងពីបុរាណកាល, ប្រជាជាតិខ្មែរក៏បាន

ទទួលនូវវិប្បធម៌ពុទ្ធសាសនា ទុកជាសរណៈដ៏ឧត្តម តាំងពីកាលនេះរៀងមក ដើម្បីបង្រ្កាបសេចក្ដីភិតភ័យ និងដើម្បីសម្រេចសេចក្ដីប្រាថ្នា ព្រមទាំងបញ្ជាក់នូវសេចក្ដីទុកចិត្តរបស់ខ្លួនក្នុងអនាគត មិនគួរបំភ្លេចចោលនូវគោលធម៌ការគ្រប់គ្រងខ្លួនដ៏សំខាន់នេះ ហើយបណ្ដោយខ្លួនឲ្យលិចលង់ក្នុងសេចក្ដីសប្បាយ ឬក៏ធ្វើសេចក្ដីអាក្រក់រឹតតែខ្លាំងឡើងដោយគិតខ្ញុំថា "បានជាខូចជ្រុលទៅហើយ ត្រូវខូចឲ្យពេញទី" ប្រហែលគ្នានឹងថា "ប្រឡាក់ភក់ហើយ ខ្លាចអ្វីនឹងចុះភក់ទៀត" នោះឡើយ ។

មែនពិតក្នុងលោកនេះ មនុស្សយើងគ្រប់គ្នាដែលធ្វើកិច្ចការអ្វីមួយ តែងមានការខុសខ្លះជាធម្មតា បើមិនច្រើនក៏តិច ដូចសុភាសិតលោកចែងទុកថា "មនុស្សដែលមិនខុស គឺមនុស្សមិនធ្លាប់ធ្វើអ្វីឡើយ, ការខុសជារបស់អ្នកធ្វើ ការឲ្យអភ័យជារបស់ទេវតា" ។ មានសុភាសិតមួយទៀតបញ្ជាក់សេចក្ដីនេះថា "កំហុសជារបស់មនុស្ស តែមនុស្សដែលល្អត្រូវចេះគ្រប់គ្រងខ្លួន" ។

ខាងព្រះពុទ្ធសាសនាបានអនុមតិយល់ព្រមថា បុគ្គលក្នុងលោកមានឱកាសនឹងប្រព្រឹត្តអាក្រក់ ឬធ្វើខុស ដែលនាំឲ្យវិនាសបានដោយងាយណាស់ ព្រោះមានវត្ថុកាមភេទដែលដឹកនាំឲ្យកើតកិលេសជាហេតុឲ្យធ្វើអាក្រក់ជាច្រើន ទើបលោកប្រៀនប្រដៅឲ្យមានសតិស្មារតីនិងការពិចារណាជាមុន អំពីដំណើរធ្វើកិច្ចការអ្វីៗតទៅ តែថា បើជាអ្នក

ធ្វើខុសរួចហើយ ទីនឹងត្រឡប់ធ្វើឲ្យត្រូវវិញមិនបាន តើគួរនឹងបណ្ដោយទុកឲ្យនៅខុសដូច្នោះហូតទៅ ឬថានឹងធ្វើឲ្យសេចក្ដីខុសនោះ ឲ្យតែតែខុសខ្លាំងឡើង ដោយប្រកាន់គោលថាឲ្យៗថា កាលបើបានជាខូចផុតទៅហើយ ត្រូវខូចឲ្យពេញទី, ន័យនេះគប្បីជ្រាបដោយឧបមា:

សំពត់ស្លៀកដណ្ដប់ដែលដាច់ដាចផុះធ្លាយទៅ ដោយហេតុណាមួយ បុគ្គលគួរនឹងប៉ះជុលឲ្យល្អ ឬគួរនឹងស្លៀកដណ្ដប់ទៅទាំងដាចយ៉ាងនេះ ឬថាគួរនឹងហែកឲ្យតែតែដាច់ ហើយស្លៀកដណ្ដប់? ន័យនេះត្រូវតបថា គួរតែប៉ះជុលឲ្យល្អ ។

- មួយទៀត បុគ្គលមានកាយប្រឡាក់របស់ស្មោកគ្រោកមានក្លិនស្អុយជាដើម, តើគួរនឹងលាងឲ្យជ្រះសិន ឬបណ្ដោយទុកឲ្យនៅ ឬថាគួរនឹងយករបស់ស្មោកគ្រោកនោះ មកលាបខ្លួនឲ្យតែតែប្រឡាក់ច្រើនថែមទៀត? ន័យនេះត្រូវតបថា គួរលាងចេញឲ្យស្អាត ។

-មួយវិញទៀត បុគ្គលដើរទៅកាន់ទីបំណងណាមួយ លុះដល់ផ្លូវបែកជា២ ក៏ច្រឡំស្រពេចស្រពិលចាំមិនបានថា ផ្លូវណាត្រូវ-ខុស លុះកាលជ្រើសរើសដើរទៅតាមផ្លូវណាមួយអស់វេលាជាយូរ ទើបដឹងថាដើរខុសផ្លូវ, តើគួរនឹងត្រឡប់ក្រោយមកកាន់ផ្លូវបែកចាស់ ហើយដើរផ្លូវដែលត្រូវតទៅជាថ្មី ទាំងដឹងខ្លួនថា ខុសហើយនោះ ឬគួរឈប់ស្ងៀមនៅត្រឹមនោះ ឬថាគួរដើរតទៅទៀត? សុម្បីន័យនេះក៏ត្រូវ

តបថា គួរត្រឡប់ក្រោយមកដើរផ្លូវដែលត្រូវតទៅជាថ្មី ។

ការងារឬសេចក្ដីប្រព្រឹត្តក៏ដូចគ្នា អ្នកណាធ្លាប់ខុសមកហើយ មិនគួរបណ្ដោយឲ្យនៅយ៉ាងនោះ ឬចូលចិត្តធ្វើឲ្យរឹតតែខុសខ្លាំងទេ គួរតែគិតកែខៃត្រឡប់ខ្លួនធ្វើតាមផ្លូវដែលល្អត្រូវ ទើបប្រពៃ ។

អ្នកដែលធ្លាប់ធ្វើខុសមកហើយ ដកអាល័យក្នុងជីវិតពុំបាន ឬកើតទោសៈធ្វើសេចក្ដីខុសខ្លាំងបំពាន ឈ្មោះថាប្រគល់ខ្លួនឯងឲ្យដល់នូវសេចក្ដីអាក្រក់និងសេចក្ដីខុសជាប្រាកដ ឈ្មោះថាមិនមែនជាម្ចាស់របស់ខ្លួនឯង ទាំងឈ្មោះថា មិនបានធ្វើតាមពាក្យប្រៀនប្រដៅខាងព្រះពុទ្ធសាសនា ដែលប្រដៅឲ្យផ្គត់ផ្គង់ជីវិតរបស់ខ្លួនឲ្យប្រព្រឹត្តទៅក្នុងផ្លូវល្អ ដោយការធ្វើសេចក្ដីល្អទៀតផង ។ បុគ្គលគួរបណ្ដុះសតិអារម្មណ៍ចំពោះការប្រព្រឹត្តិរបស់ខ្លួនក្នុងបច្ចុប្បន្ននិងអនាគតទៅជាថ្មី ឲ្យត្រូវតាមគន្លងធម៌ ព្រមទាំងគួរប្រកបហេតុនៃសេចក្ដីចំរើន តាមសមគួរដល់ផ្លូវលោកឬផ្លូវធម៌ទើបអាចជួយខ្លួនឯងដែលជាអ្នកធ្លាក់មកហើយ ឲ្យរុងរឿងភ្លឺស្វាងតទៅ, ឧបមាដូចផ្កាឈូកកើតក្នុងគំនរសម្រាម កាលដុះលូតលាស់ខ្ពស់ឡើង គង់មានក្លិនក្រអូបចេញទៅបាន ។ ខាងព្រះពុទ្ធសាសនាសរសើរចំពោះបុគ្គលនេះថាជាអ្នកមិនព្រមបណ្ដោយខ្លួន ឲ្យនៅក្នុងអំណាចនៃសេចក្ដីអាក្រក់និងសេចក្ដីខុស ។ កាលបើពោលបញ្ជាក់ពាក្យថា «កំហុសជារបស់មនុស្ស តែមនុស្សដែលល្អត្រូវចេះត្រឡប់កែខ្លួន» ក៏គួរ

ពិចារណាដល់គោលវប្បធម៌នៃព្រះពុទ្ធសាសនា ដែលប្រៀនប្រដៅចំពោះការត្រឡប់កែខ្លួននេះតទៅទៀត ។

១– ក្នុងព្រះត្រៃបិដក មានរឿងប្រាកដថា ភិក្ខុខ្លះ ព្រាហ្មណ៍ខ្លះ ប្រព្រឹត្តល្មើសចំពោះព្រះពុទ្ធ ព្រោះប្អូលចិត្តខុស កាលបើដឹងខ្លួនថាខុស ទូលសូមខមាទោស, ព្រះអង្គក៏ទ្រង់ប្រទានអភ័យ ហើយត្រាស់ថា "ការដែលបុគ្គលឃើញទោសប្រព្រឹត្តល្មើសហើយ ត្រឡប់ធ្វើឲ្យត្រូវតាមគន្លងធម៌ សង្រួមប្រយ័ត្នតទៅវិញនោះ ជាសេចក្ដីចំរើនក្នុងវិន័យព្រះអរិយៈ" នេះសំដែងឲ្យឃើញថា ក្នុងអរិយវិន័យមិនទិយមទូវក្ការបេបេស ឬព្រងើយកន្តើយក្នុងការដឹងខ្លួនថា ប្រព្រឹត្តខុសល្មើសចំពោះអ្នកដទៃ ។

២– ក្នុងផ្លូវវិន័យ ភិក្ខុណាប្រព្រឹត្តខុស ជាហេតុឲ្យសង្ឃដាក់ទោស ដូចមិនឲ្យមានអ្នកណាគប់រក និយាយចរចាជាមួយ ឬគ្រហស្ថណាប្រព្រឹត្តបង្ករឿងឲ្យកើតសេចក្ដីវិនាសដល់ភិក្ខុសង្ឃនិងសាសនា, សង្ឃត្រូវសូត្រប្រកាសផ្កាប់បាត្រ មិនទទួលទេយ្យធម៌របស់អ្នកនោះ ។ កាលបើភិក្ខុនិងគ្រហស្ថទាំងនោះត្រឡប់កែខ្លួនបាន, សង្ឃក៏សូត្រប្រកាសលើកទោសនោះចោលចេញ ឲ្យជាអ្នកមានសិទ្ធិសេរីភាពតាមធម្មតាដូចដើម នេះសំដែងឲ្យឃើញថា ការដាក់ទោសនោះ ពិតជាមានបំណងល្អចំពោះអ្នកប្រព្រឹត្តខុសឲ្យបានត្រឡប់កែខ្លួនត្រូវវិញជាប្រាកដ ។

៣ - ក្នុងការប្រៀនប្រដៅអំពីសេចក្ដីមិនប្រមាទ ព្រះអង្គទ្រង់ប្រដៅ

មិនឲ្យប្រមាទក្នុងការលះបង់នូវការឃើញខុស ធ្វើសេចក្ដីឃើញឲ្យត្រូវ ។ រីឯការឃើញនេះ នឹងធ្វើឲ្យឃើញត្រូវហូតទៅគ្រប់រឿងនោះ ។ ជាការកម្រណាស់ ព្រោះរឿងដែលខ្លួនមិនធ្លាប់សិក្សាស្រាវជ្រាវ ឬរឿងដែលខ្លួនដឹងមិនពិត ក៏ជាការចាំបាច់ត្រូវតែមានសេចក្ដីឃើញខុស ចូលចិត្តខុសខ្លះពុំខាន ។ ពិសេសបំផុតក្នុងធម្មប្បដិបត្តិ មានគណាចារ្យមេលទ្ធិប្រៀនប្រដៅជាច្រើន ដែលប្រកាសថា សូម្បីតែព្រះពុទ្ធជាម្ចាស់នៃយើង ក៏ធ្លាប់បានសិក្សានិងប្រតិបត្តិតាម ពាក្យប្រៀនប្រដៅរបស់គណាចារ្យទាំងនោះដែរ តែការសិក្សាគ្រប់គ្រាន់ហើយ ឃើញថានៅមិនមែនជាផ្លូវត្រូវពិតប្រាកដ ទើបទ្រង់ស្រាវជ្រាវរិះរកដោយព្រះអង្គឯងជាថ្មីទៀត នេះឯងសំដែងឲ្យឃើញថាព្រះអង្គទ្រង់ប្រកាន់ហេតុផលដែលត្រូវ បើត្រឡប់វិញព្រះអង្គមិនព្រមលិចលង់នៅក្នុងសេចក្ដីខុស ; មនុស្សខ្លះមានសេចក្ដីឃើញយ៉ាងណាក៏ក្រាញរឹងដំហរនៅយ៉ាងនោះ សូម្បីដឹងថាសេចក្ដីឃើញរបស់ខ្លួននោះខុស ក៏មិនព្រមលះបង់ផ្លាស់ប្ដូរឡើយ ។ ព្រះកុមារកស្សបៈជាសាវ័ករបស់ព្រះពុទ្ធបានប្រៀបបុគ្គលបែបនេះ ទៅនឹងអ្នកដែលមិនព្រមលះបង់ចោលនូវសម្ពាយសម្បកព្រាលជាដើម ដោយបំណងនឹងធ្វើប្រយោជន៍ខ្លះដើម្បីខ្លួន សូម្បីបានជួបប្រទះនូវវត្ថុមានដំលៃផ្សេងៗក្នុងរយៈផ្លូវមានមាសប្រាក់ជាដើម ក៏មិនព្រមលះបង់ចោលនូវសម្ពាយនោះដែរ ដោយនឹកស្ដាយថាសម្ពាយនេះ ខ្លួនបានរែកស្ពាយមកយូរយារណាស់ហើយ ។ មួយទៀតក្នុង

ការសន្ទនាធម៌ ឬសន្ទនារឿងរ៉ាវផ្សេងៗនឹងអ្នកដទៃ បើប្រាថ្នាប្រយោជន៍ពិតៗ ក៏គួរតែព្រមទទួលខុសចំពោះអ្នកដទៃ ក្នុងពេលដែលឃើញថាពាក្យរបស់ខ្លួនមិនត្រឹមត្រូវ ហើយយកតាមហេតុផលរបស់អ្នកដទៃដែលត្រឹមត្រូវល្អជាង ។ ឧទាហរណ៍ដូចព្រះនាគសេនត្ថេរ កាលសន្ទនានឹងព្រះបាទមិលិន្ទ្រក៏បានថ្វាយសេចក្ដីចូលចិត្តជាមុនថា ត្រូវសន្ទនាតាមបណ្ឌិតវាទ គឺប្រកាន់ហេតុផល ដែលត្រូវជាប្រមាណ, នេះឈ្មោះថាសំដែងខ្លួន ការត្រឡប់កែខ្លួនចាកភាពជាអ្នកឃើញខុសហើយ ត្រូវព្យាយាមសិក្សាស្រាវជ្រាវរកឲ្យដឹងពិតក្នុងរបស់ទោះដោយខ្លួនឯង ។ មួយវិញទៀត កាលសន្ទនាប្រាស្រ័យនឹងអ្នកដទៃ ក៏គួរយល់ព្រមតាមសេចក្ដីឃើញណាដែលត្រឹមត្រូវដោយហេតុផល មិនគួរប្រកាន់ខុសរឹងដំបារតាមមតិរបស់ខ្លួន ទាំងដឹងថាខុសការបេះត្រឡប់កែខ្លួនបានដូច្នេះ រមែងប្រព្រឹត្តដើម្បីប្រយោជន៍ខ្លួនយ៉ាងច្រើន ។

៤- អ្នកណាក៏ដោយ សូម្បីធ្លាក់ខ្លួនទៅជាមនុស្សអាក្រក់ប្រព្រឹត្តអាក្រក់មកពីមុនយូរហើយ ដោយមានវេតៈបាបពេចដឹកនាំក្ដី ដោយសេចក្ដីល្ងង់ខ្លៅអាប់ឥតបញ្ញា ឬដោយហេតុណាៗក្ដី កាលបើដឹងថាខ្លួនប្រព្រឹត្តខុសហើយ គួរលះបង់ចោលនូវសេចក្ដីប្រព្រឹត្តខុសនោះចេញ ត្រឡប់កែខ្លួនឲ្យជាមនុស្សល្អត្រឹមត្រូវឡើង ផ្ដើមប្រព្រឹត្តសេចក្ដីល្អតទៅ, គួរយ៉ាងដូចព្រះអង្គុលិមាល ធ្លាប់ធ្វើជាចោរកាប់សម្លាប់មនុស្សមកជាច្រើន

តែបេះត្រឡប់កែខ្លួនបានមកតាំងនៅក្នុងសីលធម៌ ទាល់តែបានសម្រេច ព្រះអរហត្តផល ហើយបន្លឺខ្ពានវាចាសំដែងពីសេចក្ដីឃើញចំពោះរឿង ការត្រឡប់កែខ្លួននេះ ដោយជ្រះថ្លាក្នុងចិត្តពិតប្រាកដតាមពុទ្ធភាសិតដែល បានតាំងទុកជាគោលខាងដើមនោះ ។

៥- កាលបើពិចារណា អំពីរឿងពុទ្ធប្រវត្តិ និងសាវកប្រវត្តិហើយ អាចយល់ឃើញថា ព្រះពុទ្ធជាម្ចាស់ក្ដី សាវកទាំងឡាយក្ដី សុទ្ធតែធ្លាប់ បានឆ្លងកាត់នូវគោលវិជ្ជធម៌ ការត្រឡប់កែខ្លួនដូច្នោះទាំងអស់អង្គ ៗ ក្នុងអបទានសំដែងពីបុព្វកម្មរបស់ព្រះអង្គថា ព្រះពុទ្ធជាម្ចាស់ ព្រះអង្គធ្លាប់ ជាអ្នកលេងឈ្មោះ បុនាលិ បានពោលមើលងាយព្រះបច្ចេកពុទ្ធក្នុងជាតិ ដែលកន្លងមកហើយ និងប្រព្រឹត្តអាក្រក់ក្នុងជាតិ ជាលំដាប់តទៅទៀត ក្នុងទីបំផុតក៏ព្យាយាមត្រឡប់កែខ្លួន លែងប្រព្រឹត្តអាក្រក់បានត្រាស់ជាព្រះ ពុទ្ធអង្គក្នុងលោក ។ សាវកទាំងឡាយដូចព្រះសារីបុត្តនិងព្រះមោគ្គល្លាន ជាដើម ធ្លាប់កាន់សាសនាដទៃមកពីមុន តែកាលបានស្ដាប់គោលវិជ្ជា-ធម៌ដ៏ប្រកបដោយហេតុផល ក្នុងសាសនារបស់ព្រះមានព្រះភាគ ក៏ត្រឡប់ ខ្លួន ត្រឡប់ចិត្ត ត្រឡប់សេចក្ដីឃើញ ប្រព្រឹត្តព្រហ្មចារ្យក្នុងព្រះពុទ្ធ សាសនាវិញ ។ ជដិល ១ ពាន់រូប គឺឧរុវេលកស្សបៈ នទីកស្សបៈ និង គយាកស្សបៈ ៣ នាក់បងប្អូនជាប្រធាន ក៏ធ្លាប់ប្រកាន់តឹងរ៉ឹងក្នុងលទ្ធិដទៃ មកពីមុនដែរ, កាលបើបានស្ដាប់ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់

ហើយ ក៏ពិចារណាឃើញដោយចិត្តរបស់ខ្លួនឯងថា លទ្ធិដើមរបស់ខ្លួនពុំមានខ្លឹមសារ ទើបត្រឡប់មកសូមឧបសម្បទាក្នុងសំណាក់ព្រះពុទ្ធជាម្ចាស់វិញ ។ ពិសេសបំផុត ព្រះឧរុវេលកស្សបៈបានពោលប្រកាសហេតុផលអំពីការដែលលើកលែងលទ្ធិដើម មកកាន់កាន់ព្រះពុទ្ធសាសនាវិញ ដល់ប្រជាជនក្នុងដែនមគធៈ ។

ព្រោះហេតុនេះ យើងជាពុទ្ធបរិស័ទគ្រប់គ្នាគប្បីប្រារព្ធនូវការត្រឡប់កែអង្គរបស់ព្រះមានព្រះភាគ និងការកែខ្លួនរបស់ព្រះសង្ឃបុរាណជដិលជាដើមនោះ យកមកជាអារម្មណ៍ ហើយត្រូវត្រួតពិនិត្យមើលនូវសេចក្តីប្រព្រឹត្តរបស់ខ្លួនថែមទៀត ។ បើអធ្យាស្រ័យរបស់យើងនៅមានឃោរឃៅ គិតគួរកែខៃឲ្យស្លូតបូតទន់ភ្លន់ បើនៅជាអ្នកខ្ជិលច្រអូស គិតគួរប្រារព្ធតាំងសេចក្តីព្យាយាមឡើង, សេចក្តីខុសណាៗ ដែលខ្លួនធ្លាប់ប្រកាន់រឹងជំហរមក, កាលដឹងថាខុសហើយ ចូរត្រឡប់កែសេចក្តីឃើញខុសនោះចោលចេញ ហើយធ្វើឲ្យត្រូវត្រង់ជាថ្មីទៅ ។

ថ្ងៃណាដែលធ្វើដូច្នោះ ថ្ងៃនោះទុកជាថ្ងៃសុភមង្គលនៃពួកយើងជាពុទ្ធបរិស័ទទាំងអស់គ្នា ព្រោះបានកំចាត់បង់នូវសេចក្តីខុសក្នុងពេលមុនដោយការត្រឡប់កែខ្លួនឲ្យជាមនុស្សល្អទៅ ។ បុគ្គលបានគ្រប់សម្បត្តិដែលកើតអំពីការធ្វើសេចក្តីល្អមានសីលជាដើម ដោយការត្រឡប់កែខ្លួនហើយ ឈ្មោះថាញុំាំងជីវិតរបស់ខ្លួនឲ្យស្រស់រីករាយជាទីបំផុត ។

# តិលមុដ្ឋិជាតក[១]

ព្រះញាណកោសល ញាណ-ឈឹង រៀបរៀង

ឆមោ ៣ ៥៥ ។

សូមនមស្ការ បំពោះព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់អង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្តីគោរព ។

លំដាប់នេះ នឹងពណ៌នាអំពីបុគ្គលជាអរិយៈ ៤ ប្រភេទគឺ :

១- អាចារអរិយ,

២- ទស្សនអរិយ,

៣- លិង្គអរិយ,

៤- បដិវេធអរិយ ។

មានសេចក្តីប្រែ និងអធិប្បាយដូចតទៅនេះ :

១-អាចារអរិយៈ ប្រែថា បុគ្គលអ្នកមានការប្រព្រឹត្តត្រឹមត្រូវ មានកិរិយាមារយាទល្អ អាកប្បកិរិយាថ្លៃថ្នូរ ឬកពាសមរម្យ ចរិយាខ្ពង់ខ្ពស់ ជាបរិនាយកអ្នកដឹកនាំគេ ឬសត្វពាហនៈ ដូចដំរីសេះជាអាទិ៍ ដែលគេហ្វឹកហ្វឺនបានបទ ដូចមានឧទាហរណ៍ថា "អ្នកនេះមានអាកប្បកិរិយាល្អ

---

១-ជាតកដ្ឋកថា ចតុត្ថោ ភាគោ ទំព័រ ៨-១៤ ។

ណាស់ ដំរីសេះនេះ បានបទល្អណាស់ ប៉ុណ្ណេះជាដើម នេះជា
អាចារអរិយៈ ។

២-ទស្សនអរិយៈ ប្រែថា បុគ្គលជាមនុស្សជាតិទិនសត្វពាហ-
នៈដែលមានរូបល្អ មានឥរិយាបថស្រគត់ស្រគំ គួរជ្រះថ្លា គួរក្រឡេក
មើល ដូចឧទាហរណ៍ខាងលើដែរ នេះជាទស្សនអរិយៈ ។

ន័យដទៃទៀត ជនប្រុសស្រីណា បានឃើញព្រះសម្ពុទ្ធ ព្រះ
បច្ចេកពុទ្ធ ឬបានឃើញពុទ្ធសាវកហើយ កើតសទ្ធាជ្រះថ្លា ចំពោះអរិយៈ
ទាំងនោះ ការឃើញនោះឈ្មោះថា ទស្សនានុត្តរិយៈ ការឃើញវិសេស(១)
ការឃើញឥតទោស ។

៣-លិង្គអរិយៈ ប្រែថា បុគ្គលដែលមានឋានៈត្រឹមណាក៏ដោយ
ទោះជាគ្រហស្ថ ឬបព្វជិត មានសីលបរិសុទ្ធិ៍ សៅហ្មងខ្លះ គ្រាន់តែមាន
សំលៀកបំពាក់ពណ៌លឿង-ស កាន់យកភេទជាសមណៈគួរជ្រះថ្លា គួរ
ក្រឡេកមើល ដូចពុទ្ធបរិស័ទចំពួកខ្លះកាន់សីល ៨-១០ ស្លៀកពាក់
សំពត់ពណ៌លឿង-ស កោរសក់ កោរពុកមាត់ ពុកចង្កា ស្អាតបាត
នេះជាលិង្គអរិយៈ ។

៤-បដិវេធអរិយៈ ប្រែថា ព្រះអរហន្តទាំងឡាយ មានព្រះ
សម្ពុទ្ធជាដើម ដូចមានបាលីថា អរិយា វុច្ចន្តិ ពុទ្ធា ច បច្ចេក-

---

១-អនុត្តរិយសូត្រ. ភាគណ្ឌៈ ទំព័រ ៣២១, ឆក្កង្គុត្តរៈ ភាគ ៤២- ទំព័រ ១០ ។

ពុទ្ធា ច ពុទ្ធសាវកា ច "ព្រះសព្វញ្ញុពុទ្ធក្តី ព្រះបច្ចេកពុទ្ធក្តី ពុទ្ធសាវកក្តី សុទ្ធតែជាអរិយៈទាំងអស់" នេះជាបដិវេធអរិយៈ ។

ប៉ុន្តែ ក្នុងទីនេះ អ្នកនិពន្ធមានបំណងនឹងដកស្រង់ចំពោះតែអាចារអរិយៈទី ១ ខាងដើមមកសំដែងឲ្យពិស្តារ, ដូចមានបទសុភាសិតថា :

អរិយោ អនរិយំ កុព្វំ
យោ ទណ្ឌេន និសេធតិ
សាសនំ តំ ន តំ វេរំ
ឥតិ នំ បណ្ឌិតា វិទូ ។

ប្រែថា នរជនណាបានប្រហារគេ គឺដាល់គប់ទះ ឬវាយដោយរំពាត់ហើយហាមប្រាម ចំពោះជនអ្នកដែលប្រព្រឹត្តអំពើអាក្រក់ពុំគាប់ប្រសើរនរជនអ្នកហាមប្រាមនោះ បានឈ្មោះថា អាចារអរិយៈ ពាក្យប្រដៅរបស់លោកនោះចាត់ជាទូន្មាន ពាក្យនោះមិនមែនជាពៀរឡើយ អ្នកប្រាជ្ញតែងស្គាល់ច្បាស់នូវនរជននោះ ដូច្នេះឯង ។

មិនតែប៉ុណ្ណោះសោត ពោះទាំងវាចារបស់មាតាបិតាគ្រូអាចារ្យដែលពោលប្រាកប្រោះបញ្ឆោះបញ្ឆៀ ដូចពាក្យថា អ្នកឯងត្រូវក្របីវែធ, អ្នកឯងត្រូវតែវាសម្លាប់ចោលដើម ដោយពាក្យកបុត្តធីតា ឬ កូនសិស្ស ដែលមានកំហុស ប៉ុន្តែ ចិត្តរបស់លោកនៅមានមេត្តាទន់ភ្លន់ចំពោះជីវភាព នឹងប្រយោជន៍

ដែលផ្តល់នូវសេចក្តីចំរើនតទៅមុខ របស់បុត្តធីតាឬកូនសិស្សនោះៗ ជាដរាប ។ វាចាដែលពោលដោះនោះមិនហៅថា "ផរុសវាចា" ឡើយ(១) ហើយមាតាបិតា និងគ្រូទាំងនោះ គង់បានឈ្មោះថា អាចារិយៈ ដោយពិត ៗ ។ ឧទាហរណ៍ ដែលនាំមកប្រៀបធៀបនេះ ស្របគ្នានឹងបទសុភាសិតខាងដើមនោះដែរ ។

បន្ទាប់អំពីនេះ សូមសំដែងជាតកដែលជាបុព្វហេតុនៃអរិយបុគ្គលទាំង ៤ ដូចមានសេចក្តីថា :

កាលសម្តេចព្រះសុគតជាម្ចាស់ទ្រង់គង់នៅឡើយ ព្រះអង្គទ្រង់ប្រថាប់នៅវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ទ្រង់ប្រារព្ធនឹងភិក្ខុ១រូប ដែលជាអ្នកឆាប់ក្រោធ ។

សេចក្តីថា មានភិក្ខុ១រូបជាអ្នកឆាប់ក្រោធ ជាអ្នកមានចិត្តក្រៀមក្រំ គ្រាន់តែគេនិយាយលើសពាក្យបន្តិចបន្តួច ក៏ជេរប្រទេចគេ តែងតែប្រមូលទោសក្រោធមិនសមហេតុផល ធ្វើឲ្យជាក់ស្តែង ដូចបុរាណថា ចាប់ដៃរឹតពូតជាដុំ ៗ ថ្ងៃមួយ ភិក្ខុច្រើនរូប អង្គុយប្រជុំគ្នា សន្ទនាថា អាវុសោទាំងឡាយ ! ភិក្ខុជាអ្នកក្រោធ១រូបនោះ មានចិត្តក្រៀមក្រំតែងពោលពាក្យមើកម៉ាំង ជេរប្រទេចគេ ឮសូរប្រេះៗ ដូចអំបិលដុះក្នុងជើងក្រាន, ភិក្ខុនេះ បួសក្នុងធម៌វិន័យដែលប្រដៅឲ្យអត់សង្កត់សេចក្តីក្រោធ, ឯខ្លួនលោកបែរជាឆាប់ក្រោធ មិនអាចនឹងអត់សង្កត់ទប់ទល់

---

១- អដ្ឋកថាមង្គលសូត្រ, វិន័យកថា ទំព័រ ៣២-៩៣ ។

សេចក្តីក្រោធនោះ ។ ព្រះបរមសាស្តា ទ្រង់បានស្តាប់ពាក្យភិក្ខុទាំង នោះហើយ ទើបទ្រង់ឲ្យហៅភិក្ខុនោះមកត្រាស់សួរថា នែភិក្ខុ ! ឮថា អ្នកឯងជាអ្នកឆាប់ក្រោធមែនឬ ? ។ ភិក្ខុនោះទូលស្របថា ក្រាបទូល មែន ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ មិនមែនជាអ្នកឆាប់ក្រោធតែក្នុងបច្ចុប្បន្ននេះទេ ពីមុនមក ភិក្ខុនេះ ធ្លាប់ ជាអ្នកឆាប់ក្រោធដូច្នេះដែរ" លុះទ្រង់ត្រាស់ហើយ ក៏នាំអតីតនិទានថា :

អតីតេ ពារាណសិយំ ព្រហ្មទត្តេ រជ្ជំ ការេន្តេ .

ក្នុងអតីតកាល មានព្រះមហាក្សត្រមួយអង្គទ្រង់ព្រះនាមព្រះបាទ ព្រហ្មទត្ត សោយរាជ្យក្នុងក្រុងពារាណសី ទ្រង់មានព្រះរាជបុត្រមួយអង្គ ព្រះនាម ព្រហ្មទត្តកុមារ ។

ទំនៀមក្សត្រពីបុរាណគ្រប់ៗ ព្រះអង្គសឹងជ្រាបច្បាស់ថា រាជកុមារ សុទ្ធតែមានមានះរឹងត្អឹង ប៉ុន្តែជាអ្នកចេះអត់សង្កត់ត្រជាក់ក្តៅស្រេកឃ្លាន បាន ត្រូវតែឲ្យចេះដឹងចរិយាសាស្ត្រ ចំណេះវិជ្ជានិងកិរិយាមារយាទ សម្រាប់លោក ទ្រង់តែងបញ្ជូនរាជបុត្ររបស់ខ្លួន ៗ ឲ្យទៅរៀនក្នុង សំណាក់អាចារ្យទិសាបាមោក្ខ ដែលមានក្នុងប្រទេស បើមិនមានទេ ក៏បញ្ជូនឲ្យទៅប្រទេសក្រៅ ។ ព្រោះហេតុនោះ ព្រះបាទព្រហ្មទត្ត ទ្រង់ត្រាស់ហៅព្រះរាជបុត្រ ដែលមានអាយុ ១៦ ឆ្នាំ មក ទ្រង់ប្រទាន ស្បែកជើងសង្រែក ១ គូ ឆ័ត្រស្លឹក ១ ប្រាក់ ១ ពាន់កហាបណៈ ហើយត្រា

ថា "នែកូន! អ្នកត្រូវទៅកាន់ក្រុងតក្កសិលា ដើម្បីរៀនសិល្បសាស្ត្រចុះ ។ ព្រះរាជកុមារក៏ទទួលព្រះរាជឱង្ការថា «សាធុ» ហើយសំពះលាមាតាបិតា ដើរចេញទៅតាមលំដាប់ ក៏បានដល់គ្រឹះស្ថានអាចារ្យនៅក្រុងតក្កសិលានោះ ។ កាលនោះអាចារ្យទិសាបាមោក្ខ ទើបនឹងបង្រៀនពួកមាណពជាសិស្សរួចហើយ ក្រោកទៅអង្គុយនៅមាត់ទ្វារ ។ រីឯព្រះរាជកុមារ បានឃើញអាចារ្យអង្គុយនៅមាត់ទ្វារហើយ ក៏ដោះស្បែកជើង ដំឡើងឆ័ត្រ សំពះអាចារ្យ ហើយឈរនៅស្ងៀម ។ អាចារ្យ បានជ្រាបនូវការលំបាកតាមផ្លូវ ក៏សង្គ្រោះព្រះរាជកុមារដោយអាគន្តុកកិច្ច ។ លុះព្រះរាជកុមារសោយរួចហើយសម្រាកកាយបន្តិច ទើបចូលទៅរកអាចារ្យ សំពះតាមកិច្ចគួរសម ។ អាចារ្យបានសួរថា: អ្នកមកពីនគរណា? ។ – ខ្ញុំមកពីនគរពារាណសី ។ – អ្នកឯងជាបុត្រលោកណា? ។ ខ្ញុំជាព្រះរាជបុត្ររបស់ព្រះបាទពារាណសី ។ –អ្នកឯងមកដើម្បីអ្វី? ។ – ខ្ញុំមកដើម្បីនឹងរៀនសិល្បសាស្ត្រ ។ – អ្នកត្រូវការរៀនឈ្នួល ឬ រៀនតាមធម្មតា? ។ ខ្ញុំត្រូវការរៀនឈ្នួល ។ លុះដំរបហើយ ក៏យកប្រាក់១ពាន់កហាបណៈ ដំកល់ទុកទៀបបាទមូលនៃលោកអាចារ្យ ។

មានសេចក្តីថា ក្នុងជំនាន់នោះ កូនសិស្សធម្មតាដែលឥតថ្លៃឈ្នួល រៀនបានតែវេលាយប់ ឯវេលាថ្ងៃធ្វើការជូនលោកអាចារ្យ ។

ចំណែកកូនសិស្សឈ្មួល រៀនបានទាំងយប់ទាំងថ្ងៃ ដូចជាបុត្របរិស័ទ្ធ គេហដ្ឋានដូច្នោះ ហេតុនោះ អាចារ្យទិសាបាមោក្ខ បង្រៀនព្រះរាជកុមារ ដោយសុភនក្ខត្តពេលវេលាល្អ ព្រះរាជកុមារក៏បានរៀនចេះដឹងជាប់រហ័សតាមចិត្ត ។ មានថ្ងៃមួយ ក្រៅពីពេលរៀន ព្រះរាជកុមារ នាំគ្នាទៅងូតទឹកងងូតទឹក ជាមួយនឹងអាចារ្យ ។ កាលនោះមានស្ត្រីចាស់ម្នាក់យកល្ងទៅហាល ដើម្បីឲ្យស្ងួតសម្ងួត រួចអង្គុយឃ្លាំចាំមើល ។ ព្រះរាជកុមារបានឃើញល្ងនោះ ក៏ទឹកមាត់ស្រាយ ទើបទៅកើបយកល្ង ១ ក្ដាប់មកសោយ ។ ស្ត្រីចាស់បានឃើញហើយគិតថា កុមារនេះឃ្លានខ្លាំងណាស់ ប៉ុន្តែគាត់មិននិយាយថាអ្វីឡើយ គាត់នៅស្ងៀម ។ លុះដល់ថ្ងៃជាគម្រប់ពីរគម្រប់បី ព្រះរាជកុមារធ្វើដូចមុនទៀត ស្ត្រីចាស់បានឃើញហើយ លើកដៃគក់ទ្រូង ព្រះហឫទ័យថា "អាចារ្យទិសាបាមោក្ខ នាំកូនសិស្សឲ្យមកប្លន់ខ្ញុំ" ។ អាចារ្យទិសាបាមោក្ខសួរថា " នែយាយ ! ដំណើរអ្វី ? ស្ត្រីចាស់ឆ្លើយថា "លោកម្ចាស់ កូនសិស្សរបស់លោកវាយកល្ង ដែលខ្ញុំកំពុងហាលមកទទួលទាន គឺថ្ងៃនេះ ១ ក្ដាប់ ពីម្សិលម៉ិញ ១ ក្ដាប់ ពីម្សិលម្ងៃ ១ ក្ដាប់ បើទទួលទានតែយ៉ាងនេះ ល្ងរបស់ខ្ញុំនឹងវិនាសអស់ទៅទេ ។ ហើយ ! ។ អាចារ្យឃាត់ថា នែយាយ ! កុំយំសោកឡើយចាំខ្ញុំសងថ្លៃជូន ។ ស្ត្រីចាស់ឆ្លើយថា ខ្ញុំពុំត្រូវការឲ្យសងថ្លៃទេ សុំឲ្យតែលោកគ្រូប្រដៅកូនសិស្សកុំឲ្យធ្វើដូចមុនទៀតតែប៉ុណ្ណោះ ។

អាចារ្យទិសាបាមោក្ខនិយាយថា បើដូច្នោះ យាយឯងចាំមើលចុះ លុះថាហើយ ក៏ប្រើមាណពពីររូបឲ្យចាប់ព្រះរាជកុមារត្រង់ដៃទាំងសងខាង រួចហើយ យកបន្ទះឫស្សីវាយ៣ខ្ទាប់ចំកណ្ដាលខ្នងហាមប្រាមថា "នែកុមារ! អ្នកកុំធ្វើដូចមុនទៀត" ។ ឯព្រះរាជកុមារនោះខ្ញាល់ណាស់ ធ្វើព្រះនេត្រក្រឡៅសំឡក់មើលអាចារ្យ តាំងពីបាទជើងដរាបដល់ក្បាល (ចងគំនុំទុក) ។ អាចារ្យក៏បានជ្រាបថា ព្រះរាជកុមារនេះខ្ញាល់ចំពោះខ្លួនដែរ ។ លុះព្រះរាជកុមារបានរៀនចេះចប់វិជ្ជាហើយ ក៏ចងចិត្តថា ទៅអនាគតដ៏ខ្ញុំ អញត្រូវតែសម្លាប់អាចារ្យនេះឲ្យបាន លុះគិតហើយជំរាបថា "បពិត្រលោកអាចារ្យ បើកាលណាខ្ញុំបានទៅដល់មាតុភូមិហើយ បានសោយរាជ្យ ក្នុងក្រុងពារាណសី ខ្ញុំនឹងផ្ញើលិខិតមកសូមអញ្ជើញលោកទៅជួបនឹងខ្ញុំ, ក្នុងកាលនោះ លោកត្រូវតែអញ្ជើញទៅ" ព្រះរាជកុមារធ្វើការគោរពគាល់ហាក់ដូចជាស្រឡាញ់អាចារ្យណាស់ រួចហើយសំពះដើរចេញទៅ ។ ក្រោយពីនោះមក ព្រះរាជកុមារបានវិលត្រឡប់មកដល់ក្រុងពារាណសី បានថ្វាយបង្គំមាតាបិតា សំដែងសិល្បៈដែលខ្លួនបានចេះចាំថ្វាយព្រះរាជា។ ទ្រង់សព្វព្រះរាជហឫទ័យ ដោយទ្រង់ល្មើយល់ថា អញនឹងបានឃើញរាជកុមារនេះសោយរាជ្យ នៅវេលាដែលអញមានជីវិតរស់នៅ លុះទ្រង់ល្មើយល់ហើយ ទ្រង់ព្រះរាជទានរាជសម្បត្តិចំពោះព្រះរាជកុមារក្នុងកាលនោះឯង ។ តាំងពីព្រះរាជកុមារបានសោយរាជ្យ

ក៏រលឹកនូវទោសដែលអាចារ្យវាយពាខ្នាប់, ទ្រង់ព្រះពិរោធគិតថា "យើងនឹងសំឡាប់អាចារ្យសងទៀតវិញ ទ្រង់បញ្ជាទូតឲ្យទៅអញ្ជើញអាចារ្យមក ៗ ឯអាចារ្យទិសាបាមោក្ខគិតថា ព្រះរាជកុមារឋិតនៅក្នុងតរុណវ័យនៅឡើយ យើងពុំអាចពន្យល់ឲ្យយល់ហេតុផលបានទេ; គាត់ក៏មិនអញ្ជើញមក លុះព្រះរាជកុមារបានឋិតនៅក្នុងមជ្ឈិមវ័យ ទើបគិតថា វេលានេះ យើងអាចនឹងពន្យល់ព្រះរាជកុមារឲ្យយល់បាន គាត់ក៏អញ្ជើញមក ហើយឈរនៅទៀបទ្វារព្រះរាជនិវេសន៍ រួចហើយឲ្យយកសេចក្ដីក្រាបបង្គំទូលថ្វាយថា ឥឡូវនេះ អាចារ្យអញ្ជើញមកដល់ហើយ ៗ ព្រះរាជាមានសេចក្ដីត្រេកអរ ឲ្យអញ្ជើញព្រាហ្មណ៍ចូលមក គ្រាន់តែទ្រង់ទតឃើញព្រាហ្មណ៍នោះមកដល់ ក៏កើតព្រះពិរោធមួយរំពេច ដេរព្រះនេត្រក្រហម ទ្រង់ត្រាស់ហៅអាមាត្យមកប្រាប់ថា នែអ្នកទាំងឡាយ! ក្នុងថ្ងៃនេះ ត្រង់កន្លែងស្នាមដែលលោកអាចារ្យវាយខ្ញុំពីមុននោះ ឥឡូវនេះ កន្លែងនោះរាចាប់ពេតឡើងវិញ, ប្រហែលជាលោកអាចារ្យ គាត់នាំយកសេចក្ដីស្លាប់មកជាមួយនឹងខ្លួនព្រលឹងផង ហើយមើលទៅ; គាត់នឹកថា អញមុខជានឹងស្លាប់ ជីវិតរបស់អញនឹងមិនមានតទៅទៀតទេ; លុះទ្រង់ត្រាស់ហើយក៏ពោលពាក្យជាគាថាតម្រាមដូច្នេះថា

អជ្ជាបិ មេ តំ មនសិ
យំ មំ ត្វំ តិលមុដ្ឋិយា

ពាហាយំ មំ គហេត្វាន
លទ្ធិយា អនុតាលបិ
ឆនុ ជីវិតេ ឆ រមសិ
យេនាសិ ព្រាហ្មណាគតោ
យំ មំ ពាហា គហេត្វាន
តិដ្ឋន្តំ អនុតាលយិ

ប្រែថា ម្នាលព្រាហ្មណ៍ លោកចាប់ខ្ញុំត្រង់ដើមដៃ លុះចាប់បាន ហើយ វាយខ្ញុំដោយបន្ទះឫស្សី ព្រោះតែលុយ ១ កាក់ ការវាយនោះ ដក់ នៅក្នុងចិត្តរបស់ខ្ញុំ ដរាបដល់សព្វថ្ងៃនេះ ។ ម្នាលព្រាហ្មណ៍ លោកមិន ស្តាយជីវិតរបស់លោកទេឬ ? ។

ពីមុនមិញ លោកចាប់ខ្ញុំត្រង់ដើមដៃ ហើយវាយ៣ខ្នប់ ឥឡូវនេះ លោកនឹងត្រឡប់មកកាន់សំណាក់ខ្ញុំ សូមលោកទទួលនូវផលនៃការវាយ នោះវិញ ។

លំដាប់នោះ អាចារ្យទិសាបាមោក្ខបានស្តាប់ព្រះសូរសៀងនៃព្រះបាទ ព្រហ្មទត្តដែលទ្រង់ត្រាស់តិះដៀលបន្ទោសដាក់ទណ្ឌកម្មចំពោះខ្លួនហើយ ទើប ពោលពាក្យជាគាថាតបថា ៖

អរិយោ អនរិយំ កុព្វំ ។

។ល។

ឥតិ ធំ បណ្ឌិតា ៖ រឿង ៖ ៗ

-សេចក្ដីប្រែដូចខាងដើម ៗ

លុះចប់គាថាហើយ ក៏ពន្យល់ហេតុផលថា ៖

បពិត្រមហារាជ! សូមព្រះអង្គទ្រង់ជ្រាប ដូចទូលព្រះបង្គំបាន ក្រាបទូលនេះចុះ ព្រះអង្គពុំគួរបង្ខំគៀរគុនដំណើរវាយប្រដៅញញាប់នោះ ទេ ប្រសិនបើ ទូលព្រះបង្គំពុំបានប្រដៅព្រះអង្គ ពុំបានថ្វាយការរក្សា ពុំបានហាមឃាត់អំពើអាក្រក់របស់ព្រះអង្គទេ នោះយូរៗទៅ ព្រះអង្គគង់ ហ៊ានលួចទំចំណីទាំងឡាយមានផ្លែឈើជាដើម ពីរបស់តូច ដល់របស់ធំ, ពីរបស់ទាប ដល់របស់ខ្ពស់, ពីរបស់ថោក ដល់របស់ថ្លៃ ហើយព្រះអង្គ ជាប់ព្រះរាជហឫទ័យក្នុងការកម្មសន្សំ ៗ ឡើងតាមលំដាប់ ដល់ហ៊ាន កាត់ផ្កាំងរបងយង លួចយករបស់មានវិញ្ញាណ ឥតវិញ្ញាណទ្រង់នឹង ទៅជាអ្នកមានកំហុសព្រោះទោសលួច ហើយរាជបុរសគេនឹងចាប់ព្រះអង្គ ថាជាចោរនាំទៅថ្វាយព្រះមហាក្សត្រ ៗ នឹងទ្រង់ត្រាស់បង្គាប់ឲ្យធ្វើទណ្ឌ-កម្មសមគួរតាមទោសនោះៗ, កាលបើដូច្នោះ ធ្វើម្ដេចឡើយព្រះអង្គនឹង បាននៅសោយរាជសម្បត្តិនេះ ឥឡូវ បែរជាទ្រង់បានទទួលព្រះរាជឥស្សរិយ-យសជាម្ចាស់ផែនដីនេះ មិនគឺបានដោយអាស្រ័យខ្ញុំព្រះអង្គទេឬ? ៗ

ឯអាមាត្យរាជបរិពារដែលនៅគាល់ជុំវិញ ក្រោយពីបានស្ដាប់សេចក្ដីដែល អាចារ្យទិសាបាមោក្ខដោះស្រាយហើយក៏បានក្រាបបង្គំទូលថា បពិត្រព្រះ សម្មតិទេព! ព្រះរាជឥស្សរិយយសរបស់ព្រះអង្គនេះ គឺជាសម្បត្តិរបស់

លោកអាចារ្យពិតមែន ។ ព្រះរាជាក៏ទ្រង់កត់ចំណាំនូវគុណរបស់អាចារ្យជាពិតមែន ទើបទ្រង់ត្រាស់ថា បពិត្រលោកអ្នកមានគុណ ! យើងសូមជូនឥស្សរិយយសទាំងអស់នេះ ចំពោះលោក សូមលោកទទួលរាជសម្បត្តិនេះចុះ ។ អាចារ្យប្រកែកថា បពិត្រមហារាជ ! ខ្ញុំព្រះអង្គ ពុំត្រូវការដោយរាជសម្បត្តិនេះទេ ខ្ញុំព្រះអង្គគ្រាន់តែទូលសារសព្វ សូមទ្រង់ជ្រាបតែប៉ុណ្ណោះ ។ ព្រះរាជាទ្រង់បញ្ជូនរាជទូតទៅកាន់ក្រុងតក្កសិលា ឲ្យនាំគ្រួសាររបស់លោកអាចារ្យមកជួបជុំ ទ្រង់នឹងព្រះរាជទានឥស្សរិយយស ដ៏ធំគឺតែងតាំងលោកអាចារ្យក្នុងឋានន្តរជាព្រះរាជបុរោហិត លើកដំកើងបុរោហិតនោះទុកដូចជាបិតារបស់ព្រះអង្គ ទ្រង់ឋិតនៅក្នុងឱវាទនៃបុរោហិតសព្វ ។ កាលទ្រង់សន្សំបុណ្យមានធ្វើទានជាដើម លុះអស់សាននៃព្រះជន្ម ទ្រង់បានទៅកើតក្នុងឋានទេវលោក ។

លុះព្រះបរមសាស្តា ទ្រង់សំដែងធម្មទេសនាប្រកាសសច្ចធម៌ទាំង ៤ ប្រការចប់ហើយ ភិក្ខុអ្នកក្រោធនោះ បានប្រតិស្ឋាននៅក្នុងអនាគាមិផល ពុទ្ធបរិស័ទដ៏សេសបានដល់នូវសោតាបត្តិផលខ្លះ សកទាគាមិផលខ្លះ តាមសមគួរដល់វាសនាបារមីរៀងៗខ្លួន ។ ឯព្រហ្មទត្តរាជកុមារ ក្នុងកាលនោះ គឺភិក្ខុអ្នកក្រោធក្នុងកាលឥឡូវនេះ ។ អាចារ្យទិសាបាមោក្ខ គឺអង្គតថាគតនេះឯង ។

មុននឹងបញ្ចប់ជាតកនេះ សូមសំដែងពីអរិយសច្ចដែលប្រែថា ប្រសើរ

ប្រពៃ ត្រឹមត្រូវ វិសេសវិសាល ដើម្បីពង្រីកសេចក្តីឲ្យរីកធូលាយឡើង ក្បែតអរិយសច្ចជាបទផ្ទុយនឹងអនរិយសច្ច ប្រែថា មិនប្រសើរ មិនប្រពៃ មិនត្រឹមត្រូវ មិនវិសេសវិសាល បន្តិចសិន ទើបបញ្ចប់ជាគត់ជាខាងក្រោយ ព្រោះអរិយសច្ចនឹងអនរិយសច្ចនេះ គ្រាន់តែជាបទ វិសេសគុណៈដោយនាមសច្ច ឬពាក្យនាមសច្ចនោះ ជាធម៌អាចឬជាបុគ្គលក៏ដោយ ដូចន័យក្នុងប្រយោគថា :

ទ្វេ មេ ភិក្ខវេ អន្តា បព្វជិតេន
ន សេវិតព្វា កតមេ ទ្វេ យោ ចាយំ
កាមេសុ កាមសុខល្លិកានុយោគោ
ហីនោ គម្មោ បោថុជ្ជនិកោ
អនរិយោ អនត្ថសញ្ហិតោ(១) ។
យោ ចាយំ អត្តកិលមថានុយោគោ ទុក្ខោ
អនរិយោ អនត្ថសញ្ហិតោ ។

ប្រែថា ម្នាលភិក្ខុទាំងឡាយ លាមកធម៌ទាំងពីរប្រការនេះ បព្វជិតមិនគួរសេពគប់ឡើយ ។ លាមកធម៌ទាំងពីរប្រការ តើអ្វីខ្លះ ? គឺការប្រព្រឹត្តព្យាយាមនូវកាមសុខ ក្នុងវត្ថុកាមមានរូបជាដើម ជារបស់ថោកទាប ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់

១– ធម្មចក្កប្បវត្តនសូត្រ ភាណវារៈ ទំព័រ ៦៨ ។

ព្រះអរិយៈ មិនមានប្រយោជន៍ ១ គឺការប្រព្រឹត្តរឿយៗនូវអំពើថោកទាប ធ្វើខ្លួនឲ្យលំបាកមានប្រព្រឹត្តសុខវត្តជាដើម ជារបស់នាំមកនូវទុក្ខ មិនប្រសើរ មិនមានប្រយោជន៍ ១ ៗ នេះអនរិយសត្វ ពិសេសដោយបទ កាមសុខល្លិកានុយោគៈ និងអត្តកិលមថានុយោគៈ

មួយទៀត មានប្រយោគថា អយមេវ អរិយោ អដ្ឋង្គិកោ មគ្គោ(១), ប្រែថា មគ្គមានអង្គ៨ប្រការ មានសម្មាទិដ្ឋិជាដើម ជារបស់ប្រសើរ ជាអរិយធម៌ នេះអរិយសត្វពិសេសដោយមគ្គមានអង្គ៨ប្រការដូច្នេះ ៗ ប្រយោគទាំងពីរនេះបង្អួលឲ្យឃើញថា អរិយសត្វ ជាបទវិសេសដោយធម៌អាថ៌ ៗ

ឯអរិយសត្វពិសេសដោយបុគ្គលដូចមានបទសុភាសិតថា :

ពុទ្ធា បច្ចេកពុទ្ធា
អថោបិ ពុទ្ធសាវកា
ក្លេសារីហិ អបេតត្តា
សព្វេ អរិយសម្មតា(២) ៗ

ប្រែថា ព្រះសព្វញ្ញុពុទ្ធ ព្រះបច្ចេកពុទ្ធ និងពុទ្ធសាវកទាំងឡាយ ឈ្មោះថា អរិយៈ ព្រោះឃ្លាតចាកសត្រូវ គឺកិលេស ៗ

---

១- ធម្មចក្កប្បវត្តនសូត្រ ភាណវារៈទំព័រ ៦៨ ។

២- អរិយវំសសូត្រ ភាណវារៈ ទំព័រ ៣០០ ។

នេះបង្ហាញឲ្យឃើញថា អរិយសព្ទជាបទវិសេសដោយបុគ្គល នៅមានឧទាហរណ៍ដទៃទៀតថា:

ទ្វេមា ភិក្ខវេ បរិយេសនា

អនរិយា ច បរិយេសនា

អរិយា ច បរិយេសនា(១)

ប្រែថា ម្នាលភិក្ខុទាំងឡាយ ការស្វែងរកមានពីរប្រការគឺ អនរិយបរិយេសនា ការស្វែងរកខុសទំនងមិនប្រសើរ មានការស្វែងរកជាតិ ជរា ព្យាធិ មរណៈជាអាទិ, អរិយបរិយេសនា ការស្វែងរកត្រូវទំនង ស្វែងរកប្រសើរ មានការស្វែងរកមោក្ខធម៌ព្រះនិព្វានជាទីបំផុតនៃជាតិ ជរា ព្យាធិ មរណៈ ១ ។

នេះបង្ហាញឲ្យឃើញថា អនរិយសព្ទនិងអរិយសព្ទទាំងពីរនេះជាបទវិសេសដោយធម៌អាទិ ។ ព្រោះមានន័យជាគោលអាងច្រើនបែបយ៉ាងនេះ ទើបពួកបណ្ឌិតជនទាំងសកលគេនិយមប្រើអរិយសព្ទនេះ, ស្ទើរតែគ្រប់ប្រយោគ គ្រប់ភាសាជាតិនៃប្រទេសនោះ ៗ ដូចមានពាក្យថា “លោកអ្នកនោះជាអរិយបុគ្គល អរិយសាវក អរិយជនអរិយធម៌ អរិយ-សីល អរិយវោហារ អនរិយវោហារ អរិយទ្រព្យ អារ្យប្រទេស អារ្យភូមិ ។ល។ ជាគុណបទនឹងនាមសព្ទ ដូចមានហើយនោះ ។

---

១- បាសរាសិសូត្រ ភាគ. ២១ ទំព័រ ១២៨ ។

## ពាក្យផ្ដើមហ៊ោះ

ក) បុគ្គលមានធម៌ខ្ពស់ប្រសើរលើសគេគឺ បានដល់នូវសោតាបត្តិមគ្គជាដើម ដរាបដល់អរហត្តផល ឈ្មោះថា អរិយបុគ្គល ឬមួយអ្នកប្រព្រឹត្តល្អខាប់ខ្ជួនក្នុងនិច្ចសីល ឧបោសថសីល មិនមានសៅហ្មង ទាំងមានកិរិយា មារយាទ មិនឆ្គាំឆ្គង ទាស់ខុសក្នុងពុទ្ធប្បញ្ញត្តិនឹងរាជប្បញ្ញត្តិ ផ្លូវលោក ផ្លូវធម៌ ក៏បានឈ្មោះថា អរិយបុគ្គលដែរ ។

ខ) អរិយសាវក អរិយជន សឹងមានគុណធម៌ដូចគ្នា មិនប្លែកគ្នាឡើយ ។

គ) អរិយធម៌ ធម៌ប្រសើរគឺ អដ្ឋង្គិកមគ្គទាំង ៨ ប្រការ មានសម្មាទិដ្ឋិជាដើម ឬធម៌របស់ព្រះអរិយៈ មានសុចរិតធម៌ជាដើម ។

ឃ) អរិយសីល សីលជាទីត្រេកអរនៃព្រះអរិយៈ គឺនិច្ចសីលទាំង ៥ ឧបោសថសីលទាំង ៨ អតិរេកសីលទាំង ១០ ចតុប្បារិសុទ្ធិសីលទាំង ៤ គឺ សីលដែលមិនធ្លុះធ្លាយ មិនពព្រុះពពាល សីលដែលអ្នកប្រាជ្ញសរសើរ សីលមិនជ្រោកជ្រាកដោយតណ្ហានិងទិដ្ឋិ(១) មានសេចក្ដីពិស្ដារដូចអរិយធម៌ដែរ ។

ង) អរិយវោហារ(២) សំឡេងពោលចរចាផ្អែមល្ហែមពីរោះពិសា របស់អរិយជន បានដល់វចីសុចរិតទាំង ៤ មានមិនពោលកុហកជាដើម ឬ

---

១ ២-មើលភាគ១៩ ទំព័រ ១៦១ ព្រះត្រៃបិដក ។

សុភាសិតផ្សេងៗដែលមានសារវ័ន្តដ៏ប្រសើរដោយកល្យាណវាចា មិនមានទោសសព្វអទ្រើ ។

ច) អនរិយវោហារ(១) សំឡេងពោលចរចាមិនផ្អែមល្ហែម មិនពិរោះពិសា មិនមែនជារបស់អរិយជន ផ្ទុយនឹងវចីសុចរិត ព្រមទាំងសុភាសិតផ្សេងៗ ។

ឆ) អរិយទ្រព្យ ទ្រព្យប្រសើរ ចោរលួចយកមិនបាន ភ្លើងឆេះមិនកើត ទឹកជន់ពន្លិចពុំបាន បច្ចាមិត្តដណ្តើមយកមិនបាន, បានដល់ទ្រព្យ ៧ ប្រការ មានសទ្ធាជាដើម ។

ជ) អារ្យប្រទេស ស្រុកកំណើត ទឹក ដី ទីនៅ ប្រទេសតូចធំ ដែលមានបែបបទរៀបរយល្អ មានថ្នល់ធ្យារទូលំទូលាយ មានមនុស្សច្រើនកុះករ សុទ្ធតែអ្នកមានទ្រព្យ អ្នកចេះដឹង ដូចប្រទេសឥណ្ឌាជំនាន់ពុទ្ធកាល នឹងកោះសិរីលង្កាជំនាន់សតវត្សទី៣ នៃពុទ្ធសករាជ គេតែងហៅថា អារ្យប្រទេស ។

ឈ) អារ្យជាតិ ជាតិអារ្យៈ ដូចព្រះបរមគ្រូជាម្ចាស់នៃយើង ព្រះអង្គជាអារ្យជាតិ ។

សេចក្តីបញ្ជាក់ថា ប្រទេសជាតិមាតុភូមិ ឬបុគ្គលដទៃក្រៅអំពីន័យ

---

១- មើលភាគ ១៩ ទំព័រ ១៣០ ព្រះត្រៃបិដក ។

ដូចអ្នកនេះហើយនេះ មិនមែនឈ្មោះថាអរិយៈទេ ។ ដូចរឿងព្រានសន្ទូចម្នាក់ក្នុងក្រុងសាវត្ថី ព្រានៈនោះបានឃើញព្រះបរមសាស្តាទ្រង់ត្រាស់សួរព្រះសារីបុត្តថា លោកៈឈ្មោះអ្វី?, ខ្ញុំព្រះអង្គៈឈ្មោះសារីបុត្ត ហើយទ្រង់ត្រាស់សួរព្រះមោគ្គល្លានថា លោកៈឈ្មោះអ្វី? ខ្ញុំព្រះអង្គៈឈ្មោះមោគ្គល្លាន ដូច្នេះជាដើម លោកគិតថានោះ សុទ្ធតែជាព្រះអរិយៈវិសេស ៗ ព្រានក៏នឹកថាប្រហែលជាព្រះបរមសាស្តាទ្រង់ត្រាស់សួរឈ្មោះអញដែរមើលៈទៅ ។ ព្រះសម្ពុទ្ធទ្រង់ជ្រាបចិត្តរបស់ព្រានៈហើយ ទ្រង់ត្រាស់សួរថានែ ឧបាសក! អ្នកឯងៈឈ្មោះអ្វី? ព្រានសន្ទូចឆ្លើយតបថា ខ្ញុំព្រះអង្គៈឈ្មោះអរិយៈ ។ ព្រះសម្ពុទ្ធទ្រង់បដិសេធថា នែឧបាសក! មិនមែនទេ មនុស្សប្រព្រឹត្តអំពើបាណាតិបាតដូចអ្នកយ៉ាងនេះ មិនមែនឈ្មោះថា អរិយៈទេ រួចហើយទ្រង់សំដែងគុណព្រះអរិយៈជាព្រះគាថាថា:

ន តេន អរិយោ ហោតិ
យេន បាណានិ ហឹសតិ
អហឹសា សព្វបាណានំ
អរិយោតិ បវុច្ចតិ(១) ។

---

១-ធម្មបទដ្ឋកថា អរិយពាលិសិកវត្ថុ ភាគ ៧ ទំព័រ ៨៤ ។

ប្រែថា បុគ្គលបៀតបៀនធ្វើសត្វឲ្យវិនាស មិនមែនឈ្មោះថា អរិយ ព្រោះការបៀតបៀននោះទេ ការមិនបៀតបៀនធ្វើសត្វឲ្យវិនាស ទើប ហៅថា អរិយៈបាន ។

ពាក្យប្រែ ព្រមទាំងសេចក្តីអធិប្បាយអំពីអរិយសច្ច និងឧទាហរណ៍ ប្រៀបធៀប ដែលនាំមកត្រួសៗនេះ គំល្មមសមគួរដល់វេលាតែប៉ុណ្ណេះ ។

បន្ទាប់អំពីនេះ សូមផ្សាយកុសលកម្ម ធម្មបណ្ណាការ ដ៏មានរស ប្លែកនេះ ចែកជូនចំពោះទេវនិករគឺសាធុជន និងទេវនិករគឺសាធុ មនុស្ស ព្រមទាំងមនុស្សនិករមានព្រះបរមក្សត្រជាប្រធាន ដរាបដល់ សត្វនិករ សូមឲ្យបានសម្រេចឥដ្ឋមនុញ្ញផលសមតាមប្រាថ្នា មាន សម្បត្តិព្រះនិព្វានជាអវសានកុំបីឃ្លាតឡើយ ។

---

# សុរពជាតក

(តមក)

លោក ជិង - វ៉ង ចម្លងពីសាស្ត្រស្លឹករឹត

កុហឹ វសតិ ព្រះអង្គទៅត្រង់ណា ? អញទៅដែលទេពុំគួរឡើយ, កឹ - គហេត្វា គន្តុំ អញគួរយកអ្វីទៅខ្លះ ? សិប្បំ ឧគ្គណ្ហិតុំ គួរអញរៀនសិល្បសាស្ត្រហើយសឹមទៅ , គិតស្រេចក៏ចេញពីព្រះនគរ ចូលទៅក្នុងព្រៃ ដើម្បីរករៀនសិល្បសាស្ត្រ បានជួបនឹងលំនៅនៃតាបសម្នាក់ ៗ តាបសនោះ ចេះសិល្បយ៉ាងពូកែ គោះបីយករបស់អ្វី ៗ មកដាក់ក្នុងត្រាជូ (ជញ្ជីង) របស់នោះក៏ក្លាយទៅជាមាស ដោយអានុភាពនៃត្រាជូនោះឯង ។ អាមាត្យនោះ ក៏ចូលទៅសំណាក់សូមរៀន លុះរៀនបានហើយ លាព្រះតាបសត្រាច់រកព្រះមហាក្សត្រ កាត់តាមជ្រោះជ្រលង ចូលទៅក្នុងព្រៃធំ បានឃើញស្រះមួយយ៉ាងធំ ក៏អង្គុយទៀបច្នេរស្រះនោះ ស្រាប់តែឃើញកិន្នរីមួយហើរមកតាមអាកាស ៗ កិន្នរីនោះលុះដល់ស្រះហើយ ចុះដោះគ្រឿងអាភរណៈចេញពីខ្លួន ដើរទៅទៀបដើមឈើមួយ ស្ងោះសម្បកយកមកស៊ី ស្រាប់តែប្រែក្លាយខ្លួនទៅជាមេដំរី ៗ មេដំរីនោះ ចុះលេងក្នុងទឹកស្រះទល់ល្ងាច ទើបឡើងលើច្នេរស្រះដើរទៅទាំសម្បកឈើផ្សេងទៀតស៊ី ក៏ក្លាយខ្លួនទៅជាកិន្នរីវិញ តែ

និយាយតំបេញ ទើបដើរទៅរកសម្បកឈើមួយទៀតខាំស៊ី, លុះខាំស៊ីនូវនេះ ស្រដៀងកំលេងបានដូចដើមហើយ ស្ទុះហើរទៅតាមអាកាសបាត់ទៅ ។ ឯអាមាត្យឃើញដូច្នោះ ក៏ដើរទៅស្ទោះសម្បកឈើទាំងនោះប្រកក្នុងថង់ឃាម ហើយត្រាច់តាមព្រះមហាក្សត្រទៅទៀត ចូលក្នុងព្រៃតូច ធំ ពុំទាន់ដល់ប្រទះឡើយ, លុះដើរទៅអស់ផ្លូវឆ្ងាយដាច់ស្រយាលជួបនឹងភូមិ ១ ដែលព្រះមហាក្សត្រអាស្រ័យនៅ កាលបើបានឃើញព្រះមហាក្សត្រហើយ ក៏ក្រាបថ្វាយបង្គំទូលសួរថា "ឥឡូវនេះ ព្រះអង្គទ្រង់-ស្គាល់សេចក្តីទុក្ខវេទនាក្រហល់ក្រហាយហើយឬ ?" ។ ព្រះបរមក្សត្រា-ធិរាជត្រាស់ថា "អញស្គាល់ហើយ" ។ – បើព្រះអង្គស្គាល់ហើយ សូមស្តេចយាងទៅនគរវិញ ។ – ម្នាលអាមាត្យ! យើងទៅពុំទាន់បានទេ ដ្បិតនៅជំពាក់មាសនាងផ្កាមាសចំនួន១ពាន់ដំឡឹងនៅឡើយ ។ ទើបអាមាត្យរកដុំថ្មមកថ្លឹង កើតជាមាសយ៉ាងច្រើនលើសពី ១ ពាន់ដំឡឹងនោះទៅទៀត រួចឲ្យទៅស្រីផ្កាមាស ហើយយកឧសថមកដាក់ក្នុងពាងទឹក ។ លុះស្រីផ្កាមាសផឹកហើយ ក៏ប្រែក្លាយទៅជាមេដំរីមកឈរនៅចំពោះព្រះភក្ត្រព្រះមហាក្សត្រ ។ ព្រះមហាក្សត្រត្រាស់ថា ម្នាលអាមាត្យ ចូរធ្វើឲ្យទៅជាមនុស្សដូចដើមវិញហោង ។ អាមាត្យក៏យកសម្បកឈើផ្សេងទៀតឲ្យស៊ី កើតជាស្រីដូចដើមវិញ តែស្រដីពុំបាន ។ ព្រះមហាក្សត្រប្រើឲ្យអាមាត្យធ្វើស្រីនោះ ឲ្យចេះនិយាយ

វិញ ៗ អាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព! បើធ្វើឲ្យស្រីនេះ ចេះស្រដីហើយ វានឹងចូលទៅក្រាបទូលព្រះមហាក្សត្ររបស់វា នឹងចាប់យើងយកទៅសម្លាប់ពុំខាន, ដូច្នេះ គួរយើងតែទៅមុន ៗ ស្តេចត្រាស់ថា ម្នាលអាមាត្យ! យើងនឹងមានពៀរពោរ ៗ អាមាត្យក៏យកថ្នាំមួយមុខទៀតទៅដាក់ចោលក្នុងពាងទឹក ហើយនាំព្រះមហាក្សត្ររបស់ខ្លួនរត់ទៅតាំងយប់ ពុំឈប់សម្រាកសោះ លុះព្រឹកទើបផុតខណ្ឌសីមានគរនោះ ៗ ឯស្រីផ្កាមាស លុះព្រឹកឡើងទៅដកទឹកក្នុងពាងនោះ ចេះនិយាយដូចដើមវិញ ទើបចូលទៅក្រាបទូលព្រះមហាក្សត្រខ្លួនថា ឥឡូវមានស្តេចមួយព្រះអង្គ ព្រាត់ខ្ចាត់មកពីនគរដទៃ ចេះសិល្បសាស្ត្រដូច្នេះ ៗ ព្រះមហាក្សត្រជ្រាបហើយ ក៏ត្រាស់ប្រើសេនាមាត្យ រៀបគ្រឿងសស្ត្រាវុធ ដេញតាមស្កាត់គេ ៗ ពួកសេនាមាត្យដេញតាមគេសព្វព្រៃព្រឹក្សា ទីងទិតម្យុងជនបទតូច ធំ ពុំឃើញ ក៏ត្រឡប់មកវិញ ៗ ឯព្រះបាទវេច្ចមាដេតកជននឹងអាមាត្យ ទំស្រូតកាត់ពុះពារចំណាយព្រៃទៅដល់នគរមួយ ចូលទៅអាស្រ័យលើសា-លាមួយ ៗ ឥស្សិ ឯនគរ ក្នុងនគរនោះ មានស្រីផ្កាមាសម្នាក់ មានរូបយ៉ាងស្អាត ឧស្សុជិយា ជាស្រីតីបុរសងងំភាំងភ្លួងគួរពេកពិលរមិលមើល ហើយបង្កើតនូវសេចក្តីស្នេហាចង់រួមភ័ក្ត្រ ៗ តែថា បើបុរសណាចូលទៅកាន់សំណាក់នាង ៗ ពារយកឈ្នួលជាប្រាក់ ១ ពាន់ដំឡឹងមុន

ហើយពុំបានដេកនៅអាស្រ័យដោយរសកាមគុណទេ , ដ្បិតនាងនោះ ធ្វើគ្រែពីរ ធ្វើម្ខាងមានយន្ត, បើបុរសឡើងទៅអង្គុយលើគ្រែយន្តនោះ រមែងក្ដាត់ធ្លាក់ទៅក្រោមផ្ទះ ពួកទាសីរបស់នាងទាំងប៉ុន្មាន កាលបើឃើញបុរសក្ដាត់ធ្លាក់មកដូច្នោះ ក៏ចាប់ចងដាក់ពាត់បណ្ដេញបញ្ចេញក្ខាម មួយរំពេច ៗ ដូនកាល មានបុរសខ្លះឡើងទៅលើគ្រែគ្មានយន្ត ៗ ឯស្រីផ្កាមាសនោះ វាឡើងលើគ្រែមានយន្ត ហើយក្ដាត់ធ្លាក់ទៅក្រោមផ្ទះ ពុំឡើងមកវិញឡើយ ៗ ហេតុនេះ ទើបបុរសផងទាំងពួង ពុំដែលសម្រេចសេចក្ដីប្រាថ្នារបស់ខ្លួនឡើយ ៗ ក្នុងថ្ងៃដែលព្រះបាទ វេទូមារជិតកជ ធ្ដុំនៅលើសាលានោះ, មហាជនទាំងឡាយ នាំគ្នានិយាយពីលំអរបស់ស្រីផ្កាមាសនោះ, ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យ ចង់ទៅរួមរក្សាជាមួយស្រីនោះ ទើបយាងទៅជាមួយអាមាត្យ ហើយត្រាស់ថា ម្នាលអាមាត្យ ! យើងចង់ទៅសំណាក់អាស្រ័យនឹងស្រីផ្កា-មាសនោះដ៏ពន្លឹក ៗ អាមាត្យទូលថា បពិត្រព្រះសម្មតិទេព ! សូមព្រះអង្គឈប់នៅទីនេះសិន ទូលព្រះបង្គំនឹងចូលទៅជាមុន ដើម្បីសង្កេតមើលកិរិយារបស់វា រួចសឹមព្រះអង្គយាងទៅជាខាងក្រោយ, ទូលដូច្នោះហើយ ក៏ក្រាបថ្វាយបង្គំលាទៅកាន់លំនៅរបស់ស្រីនោះ ៗ ស្រីផ្កា-មាស កាលបើឃើញអាមាត្យមកដូច្នោះ ស្ទុះទៅទទួលដោយរាក់ទាក់ នាំឡើងទៅបរិភោគខាទនីយភោជនីយាហារ, លុះអាមាត្យអង្គុយបាន

មួយស្របក់, នាងនោះទារប្រាក់ថ្លៃឈ្នួលក្ដាម ។ អាមាត្យក៏ឲ្យ
ប្រាក់១ពាន់កហាបណៈទៅនាង ហើយតៀនថា ម្នាលនាងអើយ !
មកយើងនឹងនាំគ្នាទៅល្វែងខាងក្នុង ។ នាងនោះទទួលថា សាធុ ។
ហើយនាំអាមាត្យចូលទៅក្នុងល្វែង នាងឲ្យអង្គុយលើគ្រែឥតយន្ត ឲ្យ
អាមាត្យអង្គុយលើគ្រែមានយន្ត, ឯគ្រែយន្តក្ដាត់ធ្លាក់អាមាត្យទៅក្រោម
ផ្ទះ ។ ស្រីជាទាសីទាំងឡាយ ក៏បណ្ដេញអាមាត្យចេញក្នុងមួយ
រំពេច ! ។ ទើបអាមាត្យទៅក្រាបទូលព្រះមហាក្សត្រថា បពិត្រព្រះ
សម្មតិទេព ! បើស្ដេចយាងទៅកាន់សំណាក់នាង សូមគង់លើគ្រែខាង
ស្ដាំ កុំគង់លើគ្រែខាងឆ្វេងឡើយ, ដល់នាងឡើងមកលើគ្រែខាងឆ្វេង
គ្រាយន្តនឹងក្ដាត់ធ្លាក់នាង, សូមព្រះអង្គចាប់ឱបកៀកកាន់នាងនោះឲ្យ
ខ្ជាប់ មនោរថ ទាបុរសស្រួជ នឹងបានសម្រេចទូលសេចក្ដីប្រាថ្នា
ហោង ។ ព្រះមហាក្សត្រស្ដេចស្ដាប់ពាក្យអាមាត្យហើយ ទ្រង់យាង
ទៅកាន់សំណាក់នាងនោះហោង ។ ស្រីផ្កាមាស ក៏ទូលថ្វាយគោជ-
នាហារ លុះទារយកទ្រព្យបានហើយ អញ្ជើញព្រះអង្គចូលក្នុងល្វែងផ្ទះ ។
ស្ដេចក៏គង់លើគ្រែខាងស្ដាំ ។ នាងនោះអង្គុយលើគ្រែខាងឆ្វេង ។
គ្រាយន្តក៏ក្ដាត់ធ្លាក់នាងនោះទៅ ។ ប៉ុន្តែ ស្ដេចចាប់ជាប់ទាញឡើងវិញ
កុំឲ្យធ្លាក់ឡើយ ហើយព្រះអង្គបានសម្រេចកាមរស នឹងស្រីផ្កាមាស
នោះ ។ ទើបនាងក្រាបទូលថា មហារាជ បពិត្រមហារាជអើយ !

តាំងពីខ្ញុំម្ចាស់កើតមក ពុំដែលរួមសំវាសជាមួយបុរសណាឡើយ, ខ្ញុំម្ចាស់ទើបតែស្គាល់ក្នុងថ្ងៃនេះ ជាមួយព្រះអង្គ, ព្រះមហាក្សត្រស្តេចនៅនឹងស្រីផ្កាមាសនោះអស់រយៈ ៧ ខែគត់ រហូតដល់ស្រីនោះមានគភ៌ ទើបស្តេចព្រះរាជទានព្រះទំរង់ ១ នឹងមាស១សែនដំឡឹង ហើយផ្តាំថា «ករទ្ធ ម្នាលនាងដំបំរើន ! បើកូនយើងប្រុស ចូរនាងឲ្យព្រះទំរង់នេះ ហើយឲ្យទៅរកអញ, បើកូនស្រីវិញ ចូរនាងបីបាច់រក្សាតាមត្រកូលចុះ», លុះផ្តែ ផ្តាំរួចស្រេចហើយ ព្រះរាជាទ្រង់យាងចូលទៅកាន់ព្រះនគរព្រះអង្គវិញជាមួយអាមាត្យ សោយរាជសម្បត្តិដោយទសពិធរាជធម៌ ហើយទ្រង់ដំកល់អាមាត្យនោះ ក្នុងដំណែងជាសេនាបតី ។

នាងបណ្ឌិតទេវី បាននាំឧទាហរណ៍មកក្រាបទូលព្រះបាទចន្ទរាជជាមហារាជ បពិត្រមហារាជ ! នាងហៅព្រះមហាក្សត្រនឹងចិញ្ចឹមអាមាត្យនោះ សូមទ្រង់ពិចារណាគំនិតមាយ៉ាង ឲ្យបានទៀងត្រង់មានស្វាមីភក្តិ ដូចព្រះបាទវេច្ចមាររាជចិញ្ចឹមអាមាត្យដូច្នោះ ។

ព្រះបាទចន្ទរាជ, លុះនាងនិទានថ្វាយដូច្នេះហើយ, ទ្រង់ត្រាស់ដណ្ដឹងសួរថា ម្នាលនាងបណ្ឌិតទេវី ! ចុះស្រីផ្កាមាសនេះ នាងបានកូនប្រុសឬស្រី ? ។ - បពិត្រព្រះសម្មតិទេព ! ស្រីផ្កាមាសនោះ បានកូនប្រុស ។ - កូនប្រុសនោះ មានប្រការដូចម្តេចខ្លះ ? ចូរនាងនិយាយតទៅទៀត យើងនឹងស្តាប់ផង ។ សា ច ទេវី

នាងបណ្ឌិតទេវី នាំទិវាទមកក្រាបទូលតទៀតថា :

បពិត្រក្សត្រថ្លៃប្រសើរអើយ ! ស្រីផ្កាម៉ាស់នោះ លុះមានគភ៌គ្រប់ខែមាសហើយក៏ប្រសូតកូន ១ ។ ព្រះរាជកុមារនោះ កាលបើចំរើនធំឡើង បានអាយុ ១៥ ឆ្នាំ ទើបចូលទៅទៀបមាតាសួរថា អម្មបពិត្រអ្នកម្តាយ ! កោ មយ្ហំ បិតា អ្នកណាជាបិតាខ្ញុំ ? ។ –ម្នាលកូនសំឡាញ់ ! បិតាអ្នកពុំនៅទីនស្រុក នេះឡើយ គឺព្រះបាទវេច្ចមាជិតរាជ ស្តេចសោយរាជ្យនៅនគរឈ្មោះឯណោះ ។ ព្រះរាជកុមារសួរថា បពិត្រអ្នកម្តាយ ! អ្នកម្តាយនៅស្រុកនេះ ម្តេចក៏បិតានៅស្រុកឯនាយ យល់ខុសប្រពៃណី ខ្ញុំពុំជឿឡើយ ។ តាតបិយបុត្ត ម្នាលកូនសំឡាញ់ម្តាយអើយ ! បិតានៃបាជាព្រះមហាក្សត្រសោយរាជ្យនៅនគរមួយ ស្តេចត្រាច់ប្រពាតព្រៃជាមួយនឹងអាមាត្យម្នាក់ ហើយចូលកន្លៃព្រៃធំ-តូច ពុះពារវង្វេងផ្លូវពបមកដល់នគរពារាណសី ស្តេចបានមកជាស្វាមីនៃម្តាយ, កាលបើម្តាយមានគភ៌ ស្តេចទ្រង់លាទៅ ទ្រង់ទុកចិញ្ចៀនព្រះទំរង់មួយនៅទីនេះ ហើយទ្រង់ផ្តាំថា បើកូនប្រុសឲ្យយកចិញ្ចៀននេះទៅតាមព្រះអង្គ បើកូនស្រីឲ្យម្តាយចិញ្ចឹមរក្សាតាមប្រពៃណី ស្តេចឲ្យតាំងទ្រព្យ ១ សែនជំឡឹងផង ម្នាលកូន ! បើបានចង់ស្គាល់បិតា ចូរបាយកព្រះទំរង់នេះទៅជាសំគាល់ហោង ។ ព្រះរាជកុមារ ស្តាប់ហើយមានចិត្តត្រេកអរ

ទទួលយកព្រះទេវធនុនិងទ្រព្យ ១ សែនដំឡឹង ក្រាបថ្វាយបង្គំលា ធ្វើប្រទក្សិណ ៣ ជុំ ឯគាគោរ ចុះចាកត្រឹហាំតែម្នាក់ឯង វង្វាវង្វំវិចរទៅ សព្វទៅក្នុងព្រៃតូច-ធំ លុះដល់ស្រុកមួយ ចូលទៅសំណាក់នឹងមេស្រុកនោះ ។ រីមេស្រុកនោះជាអាចារ្យនៃមហាចោរចាំងពួន លុះឃើញព្រះរាជកុមារមានមាស ១ សែនដំឡឹង មានចិត្តចង់បានក៏ស្រដីថា· ម្នាលមាណព ! ទៅបានរៀនសិល្បសាស្ត្រចោរឬទេ? ។ ព្រះរាជកុមារប្រាប់ថា ខ្ញុំពុំបានរៀនទេឡើយ ។ មហាចោរក៏និយាយថា យោ យោ ចោរសិប្បំ ន ជានាតិ អ្នកណាមួយពុំចេះសិល្បសាស្ត្រចោរហើយ សោ សោ យត្ថ គច្ឆតិ អ្នកនោះ ទោះនឹងទៅក្នុងទីណា ៗ មានទ្រព្យដល់ ១ សែនដំឡឹងក្តី ក៏នឹងបាត់អស់ហោង, ហេតុនោះ ចូរបារៀនសិល្បសាស្ត្រសិន ។ ព្រះរាជកុមារទទួលថានឹងរៀន ។ ឯមហាចោរថា បើទៅរៀនចូរទៅឲ្យមាស ១ សែនដំឡឹងនេះមកយើងចុះ ។ ទើបព្រះរាជកុមារលើកមាស១សែនដំឡឹងជូនមហាចោរជាស្នាន់ ហើយរៀនសិល្បសាស្ត្រនោះលុះរៀនចេះហើយ ទើបលាអាចារ្យចេញអំពីស្រុកមហាចោរ ទៅដល់នគរនៃព្រះវរបិតា ចូលទៅសំណាក់អាស្រ័យនឹងផ្ទះជូនចាស់ម្នាក់ជាអ្នកឥតកូនចៅ ។ រីព្រះរាជកុមារនោះនៅតែពេលថ្ងៃ ពេលយប់ ចុះពីផ្ទះដើរត្រាច់ផ្គត់សព្វច្រកល្ហក រកលួចមាសប្រាក់ខ្ជីរគ្រឿងប្រដាប់

សំពត់អាវនៃអ្នកស្រុកមកលាក់ទុកក្នុងទី១ លុះព្រឹកឡើងចូលមកអាស្រ័យនឹងផ្ទះដូនតាសវិញ ។ តាដាច់ ជូនកាលព្រះរាជកុមារឡើងលួចលើផ្ទះរាជបុរស នូវផ្ទះអាមាត្យមន្ត្រីសេដ្ឋីតូចធំ បានទ្រព្យប្លែកៗយកទៅទុកនៅទីដដែល ។ អ្នកស្រុកទាំងអស់ អស្ចារ្យក្នុងចិត្តថា តាំងពីមុនមក ពុំដែលមានចោរកំណាច ឥឡូវនេះ មានចោរមកពីឯណា គិតពិចារណាគ្នារកចោរពុំឃើញឡើយ ទើបនាំសេចក្ដីទុក្ខទៅក្រាបបង្គំទូលព្រះរាជាថា បពិត្រមហារាជអើយ ! តាំងពីដើមរៀងពបជពបមក ពុំដែលមានចោរក្នុងព្រះនគរឡើយ ឥឡូវមានចោរកំណាច ឡើងលួចមាសប្រាក់អ្នកស្រុកអស់រលីងជាម្ដង ។ ព្រះមហាក្សត្រទ្រង់ព្រះសណ្ដាប់ហើយ ក៏ស្ងៀមនៅ ។ លំដាប់តមកអ្នកនគរទាំងអស់ ទៅប្រាប់មហាមាត្យសព្វៗថ្ងៃ ។ មហាមាត្យបាននាំសេចក្ដីទុក្ខទៅក្រាបទូលព្រះមហាក្សត្រាធិរាជ ។ ព្រះអង្គទ្រង់ឲ្យមហាមាត្យរកចាប់ចោរនោះឲ្យបាន ។ មហាមាត្យក្រាបទូលថា ចាប់ពុំបានឡើយ ត្បិតចោរនោះចេះសិល្បសាស្ត្រពូកែណាស់ ។ ទើបស្ដេចឲ្យហៅអស់ពលយោធាមកហើយ មានព្រះបន្ទូលថា ចូរប្រើស្ដែនពលគ្នាចាំពិតក្តីរក្សាសព្វច្រកល្ហកក្នុងភូមិតូចធំ ព្រមទាំងថ្នោះជ្រលងដងផ្លូវនឹងព្រៃតូចធំ ស្កាត់ចាប់ចោរនោះឲ្យបាន ។ រីពលយោធាទទួលព្រះបន្ទូលហើយ ក៏ផ្លាស់គ្នាចាំគយឃ្លាំមើល ដូចព្រះបន្ទូលនោះ ។

រីឯដូនចាស់ឮគេថា ព្រះមហាក្សត្រឲ្យចាប់ចោរដូច្នោះ ក៏ស្រដីទៅកាន់ព្រះរាជកុមារថា ម្នាលកុមារ! អ្នកកុំដើរលេងយប់ព្រលប់ឡើយ ត្បិតព្រះមហាក្សត្រត្រាស់ឲ្យគេចាប់ចោរ ក្រែងរាជការយាមចាប់ចៅថាជាចោរ នឹងធ្វើទោសដោយទូអំណាចរាជអាជ្ញា ។ ព្រះរាជកុមារតបថា យាយនេះគាត់ពុំដឹងគំនិតអញឡើយ ហើយក៏ស្ងៀមនៅហោង ។ ព្រឹកកាលណោះមានអាមាត្យម្នាក់ចេញទៅឃ្លាំមើល លុះដើរទៅដល់ផ្ទះជាងកាត់សក់ ឮជាងកាត់សក់ពីរនាក់និយាយគ្នាថា មានក្មេងម្នាក់មកទិញស្លាម្លូយើង វាជាចោរដឹង ? ។ អាមាត្យឮហើយ ក៏ចាប់យកជាងកាត់សក់ទាំងពីរ-នាក់មកពិចារណាសួរថា បើស្គាល់ក្មេងនោះនៅផ្ទះឯណា ? ម្តាយឪពុកឈ្មោះអ្វី ? ។ ឯជាងកាត់សក់ភិតភ័យឆ្លើយថា ខ្ញុំពុំស្គាល់ទីឋានផ្ទះសំបែងមាតាបិតាក្មេងនោះឡើយ ។ ទើបអាមាត្យនិយាយថា "បើដូច្នោះ ខ្លួនអ្នកឯងហ្នឹងហើយជាចោរ ហើយនាំអ្នកទាំងពីរឡើងទៅគាល់ព្រះមហាក្សត្រក្រាបទូលតាមដំណើរ ។ ឯសម្តេចព្រះមហាក្សត្រា-ធិរាជទ្រង់មានព្រះបន្ទូលថា ហៃហោកមាត្យ ! រីជាងកាត់សក់ទាំងពីរនេះបើមិនមែនចោរក៏ខុសស្មើចោរ ត្បិតគេ ចោរពុំបាន, ហៃចៅហោកមាត្យ ! មិនដឹងទេឬ ? យំ យំ ចោរឯង គង្វាលតាំ រត់អ្វីដែលចោរលួចយកទៅ, ឯម្ចាស់របស់ដេញជិតតាមទៅ, រីចោរក៏ភិតភ័យទំលាក់ចោលរបស់នៅក្នុងភូមិណាក្តី ឃុំណាក្តី, ម្ចាស់របស់ឃើញតែទ្រព្យ ចាប់ចោរមិនបាន

ត្រូវម្ចាស់ក្អមនោះគេចោរឲ្យ បើគេមិនបានម្ចាស់ក្អមនោះជាចោរហោង; ព្រះអង្គមានព្រះបន្ទូលដូច្នោះហើយ ទើបផ្តាំអស់សេនាពលហានថា ហៃសេនាទាំងពួង! ចូរអ្នកកល់គ្នា រៀបអស់គ្រឿងសស្ត្រាវុធចេញទៅគេឲ្យឃើញ បើប្រទះវាហើយ វាតតាំងចប្រាំង ត្រូវសម្លាប់វាចោលចេញ ។ គោ ច ឯអស់សេនាពលហានទាំងឡាយទទួលព្រះរាជឱង្ការហើយ ចេញទៅដោយផ្លូវទីទៃ ៗ ក្នុងរាត្រីនោះ ៗ រីឯក្អមសេនាបតីពេញទៅដោយមនុស្សម្នាកាន់គ្រឿងសស្ត្រាវុធគ្រប់ដៃ ១ ហើយដុតភ្លើងភ្លឺទាលប្រាលផ្លៅ ៗ ព្រះរាជកុមារ លុះឃើញមហាជនអ្នកយាមដុតភ្លើងដូច្នោះ ទើបចូលទៅជិតមហាជន ហើយដណ្តឹងសួរថា ហៃបងប្អូនទាំងពួងអើយ ! ហេតុដូចម្តេចក៏អ្នកទាំងពួងប្រុងប្រៀបរៀបការពារច្រើនដូច្នេះ ៗ រីអស់សេ-នាពលហានទាំងអស់ប្រាប់ថា យើងនឹងចាប់ចោរ ៗ ព្រះរាជកុមារសួរថា ចោរច្រើនឬចោរតែម្នាក់ ? ៗ - ចោរតែម្នាក់ទេ, ប៉ុន្តែចោរនោះ វាជាអ្នកមានដំរេះប្រាជ្ញា ៗ ឯព្រះរាជកុមារនោះប្រាប់ថា តាតា ហៃអ្នកទាំងឡាយអើយ ! កាលខ្ញុំដើរមក ខ្ញុំឃើញចោរម្នាក់រាងតូចខ្ពស់ ប្រមាណប៉ុនខ្ញុំនេះឯង លុះវាឃើញខ្ញុំ វាដេញមក ទើបខ្ញុំរត់ចូលមកទីនេះ ៗ ឯអស់សេនាពលហានទាំងពួងសួរថា វានៅឯណា? ៗ -នោះឯណោះ ' លុះឮដូច្នោះ, មហាជនទាំងឡាយក៏ស្ទុះរត់ទៅចាប់ចោរនោះ ៗ រីព្រះរាជកុមារក៏លួចទ្រព្យរបស់មហាជនទាំងនោះ ហើយវិលមកផ្ទះវិញ ៗ មហាជន

ទាំងឡាយវិលមកមិនឃើញទ្រព្យរបស់ ក៏ពោលប្រាប់គ្នាទៅៗថា សំពត់អញបាត់ហើយ, ខ្លះថា អាវអញបាត់ហើយ ប្រាកដជាកុមារកំឡោះនេះឯងជាចោរ ទើបបបួលគ្នាដើរទៅរក ក៏ពុំឃើញ ៗ មុខ និរាស ក្នុងថ្ងៃព្រឹកឡើង អស់សេនាពលទាហានទាំងនោះ ឡើងទៅគាល់ព្រះមហាក្សត្រាធិរាជទូលតាមដំណើរ ៗ ព្រះមហាក្សត្រទ្រង់ត្រាស់ថា យើងប្រាប់ថា ឲ្យចាប់ឲ្យបាន ហេតុអ្វីក៏មិនចាប់វាមក ទើបហៅហោរាមកដណ្ដឹងសួរថា ថ្ងៃនេះ តើចោរវានៅទិសឯណា ? ៗ ហោរក្រាបទូលថា បពិត្រព្រះសម្មតិទេព! ថ្ងៃនេះ វានឹងមកនៅខាងទិសឧត្តរ បើទៅរកនឹងជួបវានៅខាងស្រះធំ ៗ លំដាប់នោះព្រះមហាក្សត្រទ្រង់បង្គាប់ឲ្យសេនាយោធាទៅចាំយាមមើលនៅមាត់ស្រះធំ ៗ សេនាពលទាហានកាន់ គ្រឿងសស្ត្រាវុធដោយខ្លួនទៅៗ ហើយបបួលគ្នាទៅចាំយាមមើល នៅមាត់ស្រះនោះឯង ។ ឯព្រះរាជកុមារពុំដឹងថាមហាជនទៅយាមមើលនៅមាត់ស្រះនោះទេ កាន់ផ្លែកន្ទុតព្រៃដើរទៅអង្គុយកក្បែរមាត់ស្រះ រួចដាក់ គ្រឿងប្រដាប់ក្បែរខ្លួន ៗ ឯសេនាយោធាទាំងឡាយឃើញព្រះរាជកុមារអង្គុយកុកដូច្នោះ បបួលគ្នាកាន់គ្រឿងសស្ត្រាវុធចុះទៅ ឆ្មក់គ្នាចោមរោមជុំជិតប្រាថ្នានឹងចាប់ព្រះរាជកុមារ ៗ ឯព្រះរាជកុមារ លុះឃើញមហាជនទាំងពួនចោមរោមដូច្នោះសួរថា ហៃសេនាទាំងឡាយអើយ! ហេតុអ្វីមកទាំងឡាយកាន់គ្រឿងសស្ត្រាវុធមកដូច្នេះ? ៗ យើងទាំងឡាយមកចាប់អ្នក

ឯងជាចោរ ។ អ្នកណាទៅប្រាប់អ្នកទាំងឡាយថា ខ្ញុំជាចោរ? ។ – ពុំមានអ្នកណាមកប្រាប់យើងទេ ។ – បើគ្មានអ្នកណាមកប្រាប់ ហេតុអ្វីក៏មកចាប់ខ្ញុំថាជាចោរវិញ, ហៃអ្នកទាំងឡាយ! ធម្មតាចោរ ឃើញមនុស្សកាន់គ្រឿងសស្ត្រាវុធច្រើនយ៉ាងនេះ រមែងដែលចូលមកនៅកណ្ដាលគ្រឿងសាស្ត្រាវុធដូច្នេះទេ ។ ពួកមហាជនជឿតាម ពុំបានចាប់ព្រះរាជកុមារនោះឡើយ ហើយដោះសំពត់ នូវគ្រឿងប្រដាប់ចេញពីខ្លួនអស់រលីង ។ ឯព្រះរាជកុមារ លុះដើរចេញពីមហាជនបានបន្តិច ក៏ត្រឡប់ចូលមកស្រែកប្រាប់ថា ហៃអ្នកទាំងឡាយ! ខ្ញុំដើរចេញទៅពីនេះប្រទះនឹងចោរ វាដេញខ្ញុំ ។ ស្ទុះរត់មក ។ ឯមហាជនជឿថា ពិតមែន ខំស្ទុះរត់ដេញ បោលទាំងសំពត់ខោអាវនូវគ្រឿងសស្ត្រាវុធនានា ខ្លះបានកាន់យកទៅ ខ្លះយកទៅមិនទាន់ ។ ឯព្រះរាជកុមារ ក៏រើសយកទ្រព្យរបស់ដែលគេបោលនោះ ហើយរត់ទៅ ។ រីមហាជនរកចោរពុំឃើញ ប្រមូលគ្នាវិលមកវិញ បាត់ទ្រព្យរបស់អស់រលីង ទើបស្គាល់ជាក់ថា មាណពនេះជាចោរ ហើយឡើងទៅក្រាបទូលព្រះមហាក្សត្រាធិរាជតាមដំណើរ ។ ព្រះអង្គទ្រង់ត្រាស់ឲ្យហៅលោកមកផ្ដាំងសួរថា តាតំ ទិសំ គច្ឆតិ ថ្ងៃនេះ តើចោរវាទៅទីណា? ។ លោកក្រាបបង្គំទូលថា ថ្ងៃនេះ ចោរវាទៅទិសបូព៌ ។ សម្ដេចព្រះមហាក្សត្រាធិរាជ ទ្រង់ត្រាស់បង្គាប់ជាងប្រម៉ោកឲ្យយកសំពត់

យ៉ាងច្រើនទៅបោកឯទន្លេ ហើយហាលពោលទូរមាត់ទន្លេនោះឲ្យសេនា ពលហានឃ្លាំមើល ៗ វេលាប្រមោកទាំងឡាយ ទទួលព្រះរាជឱង្ការ ហើយវិលមកផ្ទះ; លុះព្រឹកឡើង នាំគ្នាយកសំពត់ទៅប្រមោកឯទន្លេទិស បូព៌ានគរ លុះបោករួចហើយ ទើបហាលថ្ងៃឲ្យពលហានចាំរក្សា សា-យណ្ហ ពេលល្ងាចត្រជាក់ ពពួកពលហាននាំគ្នាទៅសាសំពត់បត់វេច ទុកជាគំនរ ហើយដំនុំគ្នាជាមួយមហាជនថា អតិសាយណ្ហ ពេល នេះ ល្ងាចណាស់ហើយ ហេតុពុំមកឡើយ មកយើងនាំគ្នាទៅផ្ទះវិញ ៗ កាលនោះ ព្រះរាជកុមារមកដល់ ចូលទៅកណ្ដាលជំនុំមហាជនសួរថា ហៃអ្នកទាំងឡាយ! នែ៎ ពហុកណ្ហា តា រវេចសំពត់អំច្រើន ម្ល៉េះ! ខ្ញុំសូមលើកមើលជូនប្រស្រាល ថាតែប៉ុណ្ណោះ ក៏ចាប់សំពត់លើ លើស្មាដើរទៅ ៗ ឯមហាជនដេញចាប់មិនបាន សឹងនឿយអស់កម្លាំង រៀងៗខ្លួន ត្រឡប់មកជំនុំគ្នាដោយប្រការផ្សេងៗ ៗ ព្រះរាជកុមារយក សំពត់ទៅលាក់ទុកមួយកន្លែង ហើយផ្លាស់សំពត់ស្លៀកដទៃទៀត រួច ចូលមកកណ្ដាលជំនុំមហាជននោះ ៗ ចំណែកខាងសេនាយោធាដែលកំ-ពុងអង្គុយជំនុំគ្នានោះ ដាក់គ្រឿងអាវុធទៅឆ្ងាយៗពីខ្លួន ៗ ព្រះរាជកុមារ បានឱកាសក៏រើសយកគ្រឿងអាវុធហើយរត់ទៅ ៗ ដូចជាពេលនោះ ព្រលប់ទៅហើយ ពួកយោធាពុំអាចតាមទៅបាន នាំគ្នាចូលទៅគាល់ សម្ដេចព្រះមហាក្សត្រាធិរាជ ទូលតាមដំណើរ ៗ កាលនោះ ព្រះរាជា ទ្រង់មានព្រះបន្ទូលថា នែ៎ ពាលា ឧទ្ធា ពួកសេនាពលហានអើង

នេះធោតលួងខ្លាំងណាស់ ទើបព្រះអង្គត្រាស់បង្គាប់សេនាទាហានឯទៀត ឲ្យហៅចោរចូលមកគាល់ ហើយដណ្ដឹងសួរថា អាគាំ ថ្ងៃស្អែកនេះ តើចោរពាំនៅទិសណា ? ។ ចោរក្រាបបង្គំទូលថា ស្អែកនេះ ចោរពាំនៅទិសឯត្បូង ។ ទើបព្រះអង្គត្រាស់ប្រើសេនាបតីថា ស្អែកនេះ ត្រូវចេញទៅចាប់ចោរឲ្យបាន ។ ទើបសេនាបតី គុំអស់សេនាយោធា នាំគ្នាចូលទៅក្នុងដងព្រៃចាំឃ្លាំមើលតាំងពីព្រឹកដរាបដល់ថ្ងៃត្រង់ ពុំឃើញចោរមក ហើយសេនាបតីនោះនៅពីលើទឹក, សេនាយោធានៅក្រោមទឹក ។ លុះដល់ក្ដៅថ្ងៃ សេនាបតីក៏ដោះអស់គ្រឿងប្រដាប់ចេញពីខ្លួនចុះទៅងូតទឹកផុំកាយ ។ កាលនោះ ព្រះរាជកុមារឃើញជាក់ថាសេនាបតីដោះគប់គ្រឿងប្រដាប់ហើយ ក៏រើសយករបស់ទាំងអស់រត់ទៅតាមច្រាំងទន្លេ លុះជួបនឹងពួកយោធានៅខាងក្រោម ស្រែកប្រាប់ថា គោះគ្នា ហៃអ្នកទាំងឡាយដំចំណេ! ឥឡូវ សេនាបតីជាម្ចាស់ខ្ញុំអ្នកពល់គ្នា កំពុងចំបាប់នឹងចោរចូរអ្នកទាំងអស់ស្ទុះទៅជួយ ឆាប់! ឆាប់! ។ ពួកយោធាស្ដាប់ហើយ គិតថាពិតមែន ក៏ស្ទុះរត់ទៅចោលអស់ដាវលំពែងទួរគ្រឿងសាស្ត្រានានា ។ ព្រះរាជ-កុមារក៏រើសយកទ្រព្យនោះរត់ទៅ ។ ឯសេនាបតី ឃើញយោធារត់មកដូច្នោះសួរថា ហេតុអ្វីក៏នាំគ្នារត់មកដូច្នេះ ? ។ – មានមាណពម្នាក់ប្រាប់យើងទាំងអស់គ្នាថា លោកកំពុងចំបាប់នឹងចោរ ។ ទើបសេនាបតី វិលមករកគ្រឿងប្រដាប់ពុំឃើញក៏ប្រាប់គ្នាថា, បុរសដែលទៅប្រាប់យើងនោះ

ប្រាកដជាចោរហានលួចរបស់ទ្រព្យអស់ទៅហើយ បបួលគ្នាទៅរក
ក៏ពុំឃើញចោរ, លុះល្ងាចត្រជាក់ ចូលទៅគាល់ព្រះមហាក្សត្រាធិរាជ
ទូលតាមដំណើរ ។ សម្តេចព្រះមហាក្សត្រាធិរាជ ទ្រង់មានព្រះបន្ទូលថា
ពុំមានអ្នកណាអាចចាប់ចោរបានសោះ បើដូច្នោះ អញនឹងចាប់ខ្លួនឯង
ទើបត្រាស់ដណ្តឹងហោរាថា ម្នាលហោរា! ក្រែនេះ ចោរទៅទិស
ណា? ។ ហោរាទូលថា យប់នេះទៅទិសបស្ចិម ។ កាលនោះ ព្រះ
មហាក្សត្រទ្រង់ព្រះតម្រិះឃើញឧបាយកលមួយ ទើបហៅស្រីពេស្យា
ម្នាក់មកផ្តាំថា ហៃនាងពេស្យាផ្កាមាស! ចូរនាងទៅរកបុរសចោរនោះ
លួងលោមដោយនូវកាមគុណកុំឲ្យវាចេញពីផ្ទះបាន អញនឹងឲ្យសេនា
យោធាទៅចាប់តាមក្រោយ ។ ស្រីពេស្យា ទទួលព្រះរាជឱង្ការហើយ
ទៅរៀបចំផ្ទះ ប្រដាប់ខ្លួនចេញទៅរកចោរ លុះឃើញហើយ ក៏នាំមកផ្ទះ
បបួលគ្នាត្រេកអរដោយកាមគុណ តាំងពីបឋមយាម រហូតដល់មជ្ឈិម-
យាម លុះទៀបភ្លឺស្រាងៗ ព្រះរាជកុមារនោះ ប្រុងក្រោកចេញទៅ ។
នាងពេស្យាឃើញដូច្នោះ ក៏ស្ទុះទៅឱបរឹតឃាត់ថា សូមអ្នកឈប់សិន ។
ព្រះរាជកុមារ ត្រាស់ថា ហៃនាងពេស្យា! អញក្រហល់ក្រហាយពុំសប្បាយ
ក្នុងខ្លួនសោះ នឹងទៅដំរះកាយ រួចហើយវិលមកវិញ ថាដូច្នោះក៏
ក្រោកឡើង ។ នាងដើរតាមទៅ ។ កាលបើព្រះរាជកុមារដើរទៅ
ដល់មាត់អណ្តូងហើយ, នាងក៏ទៅដល់ដែរ ។ រំពងដ៏ធំសម្រាប់

យានទឹកក៏ដាច់ធ្លាក់ទៅ ដូច្នោះទើបព្រះរាជកុមារនិយាយនឹងស្រីពេស្យា ថា ម្នាលនាង! អញពុំមានអ្វីនឹងយានទឹកឡើយ ចូរនាងគុន្ទយកន្ទ សំរែកខាងជងយាននេះ ៗ ស្រីពេស្យាក៏ធ្វើតាមបង្គាប់ ៗ ព្រះរាជ កុមារក៏យកឈើខ្ទាស់ចុងយានទឹងមាត់អណ្តូងជាប់ ៗ ឯស្រីពេស្យា នោះ ដូចជាគេបង់ព្យួរគេងគោង ៗ នៅនឹងជងយាន ៗ ព្រះរាជ កុមារក៏ដើរបាត់ទៅ ៗ ទើបនាងស្រែកហៅឲ្យអ្នកភូមិជួយ ៗ អ្នកភូមិ ចេញមករកចោរពុំឃើញសោះ ទើបនាំគ្នាទៅដោះនាងពីជងយាននោះៗ ព្រឹកឡើង ពួកសេនាពាហានដែលចោមរោមផ្ទះស្រីពេស្យានោះ រកចោរ នឹងស្រីពេស្យាពុំឃើញឡើយ បបួលគ្នាវិលទៅវិញ ៗ កាលនោះ ស្រី ពេស្យា ចូលទៅគាល់សម្តេចព្រះមហាក្សត្រាធិរាជ ក្រាបទូលតាម ដំណើរ ៗ ព្រះរាជាបានជ្រាបហើយ ត្រាស់ថា បើអ្នកឯណាពុំអាច ចាប់ចោរបាន បើដូច្នោះ មានតែអញចេញទៅចាប់វាម្តងដោយផ្ទាល់ដៃ ត្រាស់ដូច្នោះហើយ ទ្រង់ហៅហោរាមកដណ្តឹងសួរថា : ម្នាលហោរា យប់នេះតើចោរពោះទៅទិសណា ? ៗ ហោរាក្រាបទូលថា បពិត្រព្រះសម្មតិ-ទេព! យប់នេះ ចោរពោះទៅកណ្តាលនគរ ៗ សម្តេចព្រះមហាក្សត្រាធិរាជ ទ្រង់ជ្រាបហើយក៏ស្ងៀមនៅ, លុះវេលាព្រលប់ ទ្រង់សោយព្រះក្រយា ស្ងោយរួចហើយ ក៏ប្រដាប់ព្រះអង្គទ្រង់ព្រះខ័ន លីលាយាត្រាក្នុងរាត្រី តែមួយព្រះអង្គឯង ក្រវែលឃ្លាំមើល ព្រះរាជកុមារនោះ វែកខ្ទល់ក្នុង

កន្ត្រៃ ពពាយនាយផ្ទោយផ្ទូរផ្ទាថា មម បូរី រិរកាយហ្វាជ អ្នកទាំង
ឡាយ ចូរទិញនូវខ្ញុំ ៗ កាលនោះព្រះរាជា ស្ដេចឃើញហើយត្រាស
សួរថា ហៃចៅមាណព ! ហេតុអ្វីបានជាចៅរែកនូវលក់អាំងក្រត្រ ? ៗ
ទើបព្រះរាជកុមារថា ហៃអ្នកធំអើយ ! ខ្ញុំលក់នូវអាំងក្រត្រនេះ ត្បិតមនុស្ស
ទាំងឡាយទិញជាមាសខ្លះ ជាប្រាក់ខ្លះ ជាចំណៀខខ្លះ ៗ ព្រះរាជា
ត្រាស់ថា អញទៅផងបានឬទេ ? ៗ ព្រះរាជកុមារទូលថា បើអ្នកធំទៅ
ជាមួយនឹងខ្ញុំ បានជា២នាក់ដូច្នេះ មនុស្សទាំងឡាយ គេមិនទិញជាមាស
ជាប្រាក់ឡើយ គេដូរជាស្រូវអង្ករវិញ ដូច្នេះអ្នកធំកុំទៅឡើយ ៗ ភាជំ
គមិស្ហ្រមិ ម្ហាលមាណព ! ធ្វើម្ដេចអញនឹងបានទៅផង ៗ ទើបព្រះ
រាជកុមារទូលថា បើអ្នកធំចង់ទៅ សូមអ្នកធំចូលក្នុងស្បោងស្បែកនេះ
ចុះ ខ្ញុំរែកទៅ មហាជនគេមិនដឹងជា២នាក់ទេ ហើយគេអាចទិញនូវជា
មាសជាប្រាក់បាន ៗ ព្រះរាជាទ្រង់ព្រះតម្រិះថា អញនឹងទៅលមើល
មានមនុស្សទិញមែនឬទេ ? ហើយព្រះអង្គស្គាល់ជាក់ថា បុរសនេះប្រា-
កដជាចោរហោង ទើបព្រះអង្គដាច់ព្រះទ័យចូលក្នុងស្បោងនោះ ៗ ឯព្រះ
រាជកុមារ លុះព្រះមហាក្សត្រចូលក្នុងស្បោងហើយ, ក៏គិតថាអ្នកនេះ
មិនមែនពស្ត្រឡើយ គិតដូច្នោះហើយ ចងរូបមាត់ស្បោងយ៉ាងណែន
ព្យួរទុកនៅកន្ទេនមួយ ហើយរត់ទៅ ៗ ឯសម្ដេចព្រះមហាក្សត្រត្រាដករាជ
ព្រះអង្គនៅក្នុងស្បោងនោះ លុះដល់ព្រឹកឡើង មហាជនទាំងឡាយ

ឃើញស្បោងព្យួរនៅទីងរបងដូច្នោះ ក៏កើតសង្ស័យថា ស្បោងនេះប្រាកដជាចោរយកមកចងព្យួរទុកពុំបានដោះយកទៅ ។ កាលនោះអស់ពួកសេនាយោធា និយាយគ្នាថា ឥឡូវព្រះមហាក្សត្របាត់ទៅហើយ ទើបនាំគ្នាចេញទៅរកសព្វច្រកល្ហកទាំងពួងពុំឃើញឡើយ ឃើញតែស្បោងព្យួរនៅទីងរបង ក៏គិតគ្នាថា ព្រះមហាក្សត្រប្រហែលជាចោរចាប់ពួនឲ្យចូលក្នុងស្បោងនេះប្រាកដហោង, ទើបសេនាបតីដើរទៅជិតសួរថា នរណានៅក្នុងស្បោងនេះ ? ។ ព្រះមហាក្សត្រឆ្លើយថា អញ ។ សេនាបតីដឹងថា ព្រះមហាក្សត្រទ្រង់ពិតហើយ ក៏ឲ្យនាំដំរីមក លើកស្បោងដាក់លើខ្នងដំរីនាំចូលទៅក្នុងព្រះរាជវាំង ហើយស្រាយស្បោងនោះ ។ ព្រះរាជាបានយល់មុខសេនាបតីហើយ មានព្រះបន្ទូលថា ម្នាលអ្នកទាំងឡាយ ! ចោរនោះ ត្រុណា ចេះ នៅក្នុងនៅឡើយ វណ្ណៈផ្កា មានរូបឆោមល្អ តំ ជាធិសព្វមិ អញស្គាល់ខ្ទង់ហើយ មជ្ឈិមកសមៈយ ក្នុងពេលថ្ងៃត្រង់ អញនឹងទៅកាត់ក្បាលវាឲ្យបាន លុះមានព្រះបន្ទូលដូច្នោះរួចហើយ ស្តេចឡើងទៅលើប្រាសាទផ្ទំលើអាសនា ; លុះតើនឡើងចេញទៅប្រថាប់នៅព្រះដំណាក់ ត្រាស់ហៅហោរាថា អញនឹងទៅតាំងទិសណាទើបប្រទះចោរ? ហោរាក្រាបបង្គំទូលថា ថ្ងៃនេះ ចោរវានឹងមកនៅទិសឧត្តរ ។ គុំ ស្រុទ្ធា ព្រះរាជា លុះជ្រាបហើយ លីលាចុះចាកព្រះរាជវាំង ឡើងប្រថាប់លើ

សេះឆ្ពោះទៅទិសឧត្តរ ដរាបដល់មហានទី ទ្រង់បរសេះទៅតាមមាត់ទន្លេ ក៏ទតឃើញព្រះរាជកុមារនោះ ស្លៀកខ្មៅ ដណ្តប់ខ្មៅ អង្គុយស្ទូចត្រី ទើបចុះពីខ្នងសេះទៅគង់ក្រោយខ្នងព្រះរាជកុមារ ។ ឯព្រះរាជកុមារ កាលបើឃើញព្រះមហាក្សត្រគិតថា អយំ បុរិសោ បុរសនេះ ប្រាកដជាបិតាអញហោង ។ កាលនោះ ព្រះមហាក្សត្រាធិរាជ ទ្រង់មានព្រះបន្ទូលថា ហៃកុមារ ! អ្នកចូរឲ្យសន្ទូចមកអញនឹងស្ទូចលមើល ។ ព្រះរាជកុមារ ក៏ថ្វាយសន្ទូចទៅព្រះរាជា ។ ព្រះអង្គស្ទូច, ត្រីពុំស៊ីសន្ទូចឡើយ ។ ទើបត្រាស់ថា ម្នាលកុមារ! អញស្ទូចត្រី ពុំស៊ីសន្ទូចសោះ ។ ព្រះរាជកុមារក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ! សូមព្រះអង្គដោះគ្រឿងប្រដាប់ចេញពីព្រះអង្គ ហើយទ្រង់ព្រះពស្ត្រខ្មៅនៃទូលព្រះបង្គំវិញ ទើបត្រីវាស៊ីសន្ទូច ព្រោះព្រះអង្គទ្រង់ធ្នមអម្ពរដូច្នេះ ត្រីវាពុំហ៊ានស៊ីសន្ទូចទេ ។ ឯសម្តេចព្រះមហាក្សត្រាធិរាជ ព្រះអង្គជ្រាបហើយគិតថាមែន ទើបដោះគ្រឿងប្រដាប់ចេញពីព្រះអង្គ ហើយហុចឲ្យទៅព្រះរាជកុមារនោះ ។ ព្រះ-រាជកុមារ ក៏ដោះខោ-អាវខ្មៅថ្វាយទៅព្រះមហាក្សត្រ ។ ព្រះរាជាព្រះអង្គទ្រង់ព្រះពស្ត្រខ្មៅគង់ស្ទូចត្រី ឯត្រីក៏ស៊ីសន្ទូច ។ កាលនោះ ព្រះរាជកុមារទ្រង់ធ្នមអម្ពរព្រះមហាក្សត្រ ទ្រង់ព្រះខ័ន ឡើងគង់លើខ្នងសេះ ហើយញាក់សេះ ឲ្យចូលទៅក្នុងព្រះបរមរាជវាំង លុះដល់ហើយ

(នៅមានត)

## ផ្នែកអក្សរសាស្ត្រ

# រឿងព្រេងនិងរឿងបុរាណប្រទេសជប៉ុន

លោក ហ៊យ-ប៊ុគា ប្រែរៀបរៀង

---

## រឿងព្រះនាងបែនតែន និងនាគអេណូស៊ីម៉ា

អេណូស៊ីម៉ា ជាដីមួយកន្លែង ជិតនៅជិតទីក្រុងយូកូហាម៉ា ជាទីមានទេសភាពគួរចង់ដើរលេងកំសាន្តពន់ពេក ។ ដីនេះ ពីដើមជាកោះមួយ, តែឥឡូវនេះ ទៅជាជ្រោយមួយ ដោយទឹកសមុទ្រស្រកស្រុតទៅ នៅតែផ្នូកខ្សាច់ ។ បើគេមើលពីចម្ងាយ, អេណូស៊ីម៉ា ដូចជាសុនខមួយធំកំពុងដេក ប្រមុះបែរចំមកដី ។ កោះនោះ មានពណ៌ខៀវខ្ចីបិតនៅកណ្ដាលសមុទ្រដែលមានពណ៌ផ្ទៃមេឃ, មានព្រៃស្រោងស្រោងដុះនៅលើកោះ ហើយមានផ្លូវដើរខ្វាត់ខ្វែង ។ នៅទីខ្វះ ត្រង់កន្លែងដែលគួរពិតពិលមើលមើល គេឃើញគេហដ្ឋានមានដាំដើមតែជាច្រើន ដែលពួកអ្នកទៅទស្សនាកិច្ចឈរនៅលើកំទួល ក្រឡេកមើលលំអនៃទេសភាពដ៏ប្រសើរវាំងនោះ ។

នៅលើកោះនោះ មានភោជនាគារជាច្រើន ដែលមានភោជនការីប្រសប់ខាងធ្វើម្ហូបអាហារមានរសជាតិឆ្ងាញ់ពិសាប្លែកៗ គឺមានលៀសសមុទ្រ ក្ដាម បង្កងជាដើម, មានវាណិជ្ជដ្ឋាន ដែលលក់វត្ថុសម្រាប់

លំអផ្សេង ៗ ដាំសុទ្ធតែខ្យង សម្រាប់ជាអនុស្សាវរីយ៍នៃអ្នកធ្វើដំណើរទស្សនា ។

គេមិនអាចទៅអេណូស៊ីមា ហើយចៀសវាងមិនទៅគោរពព្រះនាងទេវធីតាបែនតែន ដែលបិតនៅក្នុងគុហាមួយជាបូជនីយដ្ឋាននោះទេ ។

ក្នុងចំណោមអាទិទេព៧អង្គ, ព្រះនាងបែនតែនជាទេវធីតាមួយអង្គ, ឯអាទិទេព៦អង្គក្រៅពីនេះ ជាបុរស ។

ហេតុដូចម្ដេច បានជាពួកទេសចរតាមកោះអេណូស៊ីមា បានសំដែងកតញ្ញូតាធម៌ចំពោះព្រះនាងបែនតែន ? ។

កាលពីសតវត្សរ៍ ទី ១៤ កោះនេះមិនទាន់ផុសចេញពីទឹកសមុទ្រទេ មានតែគុហាមួយដែលទឹកសមុទ្រព័ទ្ធជុំវិញ ។ នៅទីនេះ មានរូងនាគមួយដែលមាននាគកាចសាហាវគួរឲ្យស្រប់ស្រែងអាស្រ័យនៅ ។ នាគនោះមានរូបធំសម្បើមអស្ចារ្យ ប៉ុនប្រុសប់ ចាំងហែលទឹក ចាំងលូនក៏លឿនផង មានមាត់ធំ ប្រកបដោយធ្មេញស្រួចជាច្រើន ហើយពេញចិត្តខាំស៊ីកូនក្មេងណាស់ ។ នាគនោះ តែងហែលតាមមាត់សមុទ្រ កាលណាឃើញកូនក្មេងចុះទៅមុជទឹក ឬដើរលេងតាមមាត់សមុទ្រ វាហែលទៅចាប់ទាញកូនក្មេងនោះមកត្របាក់ស៊ីតែម្ដង ។

ម្ល៉ោះហើយ នៅតាមភូមិនោះ មានតែមនុស្សកាន់ទុក្ខដោយបាត់ក្មេង មានតែមាតាយំទួញ បិតាសោកសង្រេងដោយបាត់កូន..

ហើយតែងមានមនុស្សក៏យកជាទីទន្ត ចំពោះកូនក្មេងឯទៀត ដែលត្រូវជាចំណីនៃពស់នាគរាជនេះ ទៅអនាគត ។

ព្រះនាងមេទនៃ ទ្រង់មានព្រះរាជបំណងចង់បំបាត់នូវសេចក្តីទុក្ខព្រួយនៃប្រជាពស្រុះនៅភូមិនោះ ទ្រង់ជាទេវតានៃសុភមង្គល ទ្រង់មានព្រះបំណងចង់ឲ្យសត្វទាំងអស់បានសុខស្រួលគ្រប់ៗគ្នា , អំពើនេះមិនត្រឹមតែអ្នកស្រុកក្រទេ សូម្បីអ្នកកាចសាហាវដូចយ៉ាងពស់នាគរាជដែលស៊ីសាច់មនុស្ស ក៏ព្រះនាងមានព្រះបំណងដូច្នោះដែរ ។

ថ្ងៃមួយ នៅលើគុហាដែលពស់នាគរាជនោះស្ថិតនៅ មានពពកអណ្តែតត្រសែតពីលើ, ព្រះនាងទ្រង់គង់នៅលើពពកមួយដុំ ហើយទទព្រះសិរសាដែលមានទ្រង់ព្រាយមូលក្បំ មានព្រះនេត្រតូចល្អ មានព្រះឧស្ឋតូច ផ្ទង់សងការបាញ់ទៅលើ ។

តាមធម្មៈនៃព្រះនាងទេវតា ដ៏ពុំកម្រើកខ្លាំង, គុហានៃពស់នាគរាជកំពុសចេញពីទឹកសមុទ្រ ។ នៅជុំវិញគុហានោះ មានដីត្តជុំវិញមានព្រៃឈើដុះស្រោងស្រាង ទេរគឺជាកោះអេណូស៊ីមា ដែលផុសចេញពីទឹកសមុទ្រ ។

ពស់នាគរាជស្ថិតនៅចំពីមុខគុហា បានទស្សនាដោយចាប់អារម្មណ៍យ៉ាងអស្ចារ្យ នូវទេវតាដែលគួរឲ្យស្រប់ស្រៀង ។

ព្រះនាងទ្រង់មានព្រះភក្ត្រស្រស់ញញឹម យាងទៅកាន់គុហាមាន

ព្រះសវនីយ៍ទៅកាន់ពស់នាគរាជនោះថា «អ្នកឯងស្ថិតនៅក្នុងទីនេះតែម្នាក់ឯងមិនអផ្សុកទេឬ ? គ្មានជីវិតណាមួយ រស់នៅដោយឥតមានសេចក្ដីស្នេហានោះទេ ! តើអ្នកឯងចង់ធ្វើសមរសជាមួយនឹងខ្ញុំឬ? យើងនឹងរស់នៅសុខសប្បាយជាមួយគ្នា បើយើងមានកូន អ្នកឯងមុខជាស្រឡាញ់កូននោះក្រៃលែង ... អ្នកឯងលែងអញ្ជើញទៅបរិភោគសាច់កូនក្មេងទៀតហើយ ។

ពស់នាគរាជឮហើយ ក៏ព្រមធ្វើសមរសជាមួយព្រះនាងវៃនកែន តាំងពីថ្ងៃនោះមក ជីវភាពអ្នកទាំងពីរបានឋិតនៅសុខសប្បាយ ដូចព្រះនាងវៃនកែនមានព្រះសវនីយ៍ទៅកាន់ពស់នាគរាជដូច្នោះ ។

តាំងពីនោះមក ជនជាតិជប៉ុនតែងគោរពបូជាព្រះនាងវៃនកែនជាទេព្វ ព្រោះយល់ថា ព្រះនាងមានព្រះរាជហឫទ័យប្រកបដោយសេចក្ដីករុណា ប្រទាននូវសេចក្ដីសុខសប្បាយដល់ប្រជារាស្ត្រទាំងប្រុសទាំងស្រីនៅទីនោះ។

រឿងព្រះនាងវៃនកែន នឹងពស់នាគរាជចប់តែប៉ុណ្ណេះ ។

រឿងដែលបានពណ៌នាមកហើយគឺ រឿងស្ពានពិភពលោក១, រឿងចុះទៅឋាននរក ១, រឿងព្រះនាងសុរិយាទេវីទ្រង់ព្រះពិរោធ១, រឿងអាទិទេពស៊ុសាណូ នឹងពស់នាគរាជក្បាលប្រាំបី ១ រឿងអ្នកនេសាទអ៊ុរ៉ាស៊ីម៉ាតារ៉ូ ១ រឿងព្រះនាងវៃនកែន នឹងពស់នាគរាជអេណូស៊ីម៉ា ១;

រឿងទី ៦(១)នេះ គឺអ្នកនិពន្ធបានដកស្រង់យកពីសាសនាស៊ិន្តូ ។

## អ្វីជាសាសនាស័ង្តូ ?

សាសនាស៊ិន្តូ បើតាមគេសួរជនជាតិជប៉ុនថាជាការគោរពជីដូនជីតា ឬ ជាជាតិពិធីមានរបៀបច្រើនបែបច្រើនយ៉ាង សម្រាប់គោរពបូជាជីដូនជីតាដែលធ្វើមរណភាពទៅហើយ ។

ចំពោះការឲ្យន័យខាងលើ សាសនាស៊ិន្តូជាសាសនានៃប្រជាជាតិ ឬថាជាលទ្ធិនិយម ដូចអ្នកទស្សនវិទូម្នាក់បានពោលថា ៖

"មនុស្សជាតិមានអ្នកស្លាប់ ច្រើនជាងអ្នករស់"

ព្រោះហេតុដូច្នេះ ប្រជាជាតិដែលមានបំណងចង់រក្សាទុកនូវឯក-ភាពរបស់ខ្លួន និងត្រូវរស់នៅជាសមូហភាពជាទន្ទឹម ជាមួយនឹងមនុស្សពីអតីតកាលដែលបានជួយឧបត្ថម្ភឲ្យមាតុប្រទេសបានចំរុងចំរើនរុងរឿង ។

តែបើតាមពិនិត្យឲ្យជាក់លាក់ៗ សាសនាស៊ិន្តូ មិនមែនត្រឹមតែការគោរពបូជាជីដូនជីតាប៉ុណ្ណោះទេ គឺជាលទ្ធិអាថ៌កំបាំងមួយ លំបាកនឹងយល់ពន់ពេក ដែលកម្លាំងធម្មជាតិបញ្ចេញរូបកាយជាអាទិទេព ហើយបញ្ជាក់ថា មានពង្សាវតារពីបុរាណកាលមក ដែលស្ថាបនានូវសត្វតិរច្ឆាន

១ រឿងទី១ ដល់ទី ៨ ក្នុងសាសនបណ្ឌិតបានចុះផ្សាយក្នុងទស្សនាវដ្ដីកម្ពុជសុរិយាក្នុងឆ្នាំ ១៩៥៨ រួចហើយ ។

មួយ ជាអ្នកបង្កើតជនជាតិជប៉ុនតមកទៀត ។ ចំពោះទេវតានៃសាសនាស៊ីនតូដែលមានជាច្រើនហ្មឺនរូប គេបានឃើញទេវតាព្រះធរណី ១ ស៊ុរិយាទេវី ១ ជាដើម ។ គឺព្រះនាងស៊ុរិយាទេវីនេះឯង ដែលជាបុព្វហេតុឲ្យស្ថាបនានូវព្រះរាជសន្តតិវង្ស " មិកាដូ " ដែលពីដើមសុទ្ធតែព្រះរាជជននីសោយរាជសម្បត្តិនៅប្រទេសជប៉ុន ។

នៅមានការគោរពសត្វតិរច្ឆានដូចជា សេះ ស្វារ ឆ្កែ កណ្តុរ មាន់គក ដែលជាកេតនភណ្ឌនៃទេវតានីមួយៗ ទេវតានៃសាសនាស៊ីនតូ ។ ក្រៅពីនេះ នៅមានការគោរពរុក្ខជាតិ ភាសាជប៉ុនហៅថា "តូរេអ៊ី" ជាបាវចនានៃព្រះសង្ឃស៊ីនតូ គឺដំបងដែលខាងចុងមានរំយោលក្រដាសជាច្រើន ។ រំយោលក្រដាសនេះ គេហៅថា "តូរេអ៊ី" ខ្លះហៅថា "សាកាគី" ដែលដុះនៅពីលើខ្នងទ្វារគុហានៃព្រះនាងអម៉ាតេរ៉ាសូ ។

## ពាក្យថា ស៊ីនតូបានសេចក្តីដូចម្តេច ?

បើតាមភាសាចិន ពាក្យថា ស៊ីន ឬ ស៊ិន ប្រែថា ខ្មោច វិញ្ញាណក្ខន្ធ ផលញ្ញាណនៃខន្ធ ពលភាពធម្មជាតិ ។ ពាក្យថាតូ ឬ តាវ ប្រែថា ផ្លូវ មគ្គ លទ្ធិ: ព្រោះហេតុនោះ ស៊ីនតូ ឬស៊ិនតាវ ប្រែថា ផ្លូវទៅកាន់ទេវតា ឬផ្លូវទៅកាន់ស្ថានសួគ៌ ។

បើតាមប្រវត្តិនៃសាសនាស៊ីនតូដោយសង្ខេបថា សាសនាស៊ីនតូនឹង

ព្រះពុទ្ធសាសនាមានបញ្ញាសីលដូចគ្នា ពិតមែនតែមានសភាពខុសគ្នាស្រឡះ ជាច្រើនកន្លែង ។

## បញ្ញាសីលនៃកាមី ឬសាសនាស៊ីងតូនោះគឺៈ

១– បើកាលណាគេចង់គោរពកាមី (ជាទេវតាប្រទេសជប៉ុន គឺជាព្រះមហាក្សត្រផែន ឬ វរជន ដែលបានរស់នៅក្នុងប្រទេសជប៉ុនពីអតីត-កាល) គេត្រូវតែមិនបរិភោគសាច់គោ សាច់ជ្រូក សាច់សត្វសាហាវ ដូចជាសិង្ហ ខ្លាជាដើម ។

២ · ស្ត្រីមិនត្រូវអនុញ្ញាតឲ្យបង្ហាញកក្រាចំពោះកាមី ក្នុងពេលដែលខ្លួនព្យាយាមធ្វើសេចក្តីបរិសុទ្ធខាងកាយ វាចា ចិត្ត, នារីត្រូវតែមិនឲ្យនិទ្រា ឬបរិភោគអាហារជាមួយស្វាមី , ម្ហូបអាហារត្រូវយកទៅចំអិនទៅលើជើង-ក្រានពិសេស មិនត្រូវយកទៅចំអិនទៅលើជើងក្រាន ដែលសម្រាប់ចំអិនម្ហូបអាហារស្វាមីឬញាតិសន្តានរបស់នាងជាដាច់ខាត , នាងត្រូវនិទ្រានិងបរិភោគអាហារនៅកន្លែងមួយដោយឡែក ទាល់តែសេចក្តីបរិសុទ្ធបានសម្រេចជាអវសាន ។ នេះជាកាតព្វកិច្ច ជាការចាំបាច់ ត្រូវតែស្រីបំពេញទៅថ្ងៃដែលធ្វើខ្លួនឲ្យបរិសុទ្ធស្អាត ចៀសវាងនូវមន្ទិលសៅហ្មង, ព្រោះថា ថ្ងៃនេះគេទុកជាថ្ងៃមិនបរិសុទ្ធនៃជីវភាព ជាថ្ងៃដែលពួកកាមីមិនពេញចិត្ត ។

៣-កាលណាស្រីប្រសូតកូន ត្រូវធ្វើត្រណមដូចខាងលើទាល់តែដល់កំណត់នៃការធ្វើសេចក្តីបរិសុទ្ធស្អាតជ្រះស្រឡះ ទើបចេញពីត្រណមនេះបាន ។

៤- បើបិតា បុត្រា ឬញាតិសន្តាននៃបុគ្គលណាទទួលអនិច្ចកម្ម បុគ្គលដែលកាន់ទុក្ខនោះ មិនត្រូវមកបង្ហាញខ្លួនចំពោះមុខកាម៉ ឬមហាមន្ត្រី ដែលខ្លួននៅក្រោមអំណាចអស់រយៈវេលា ៤០ថ្ងៃ ។

៥-បើមានអ្នកណាប្រមាថមើលងាយខ្លួន ឬគ្រាន់តែមានបំណងចង់ប្រមាថខ្លួន, ខ្លួនត្រូវទៅកាន់លោកកាម៉ ហើយសូមអនុញ្ញាតសម្លាប់ ឬធ្វើទណ្ឌកម្ម អ្នកដែលប្រមាថ ឬបំណងនឹងប្រមាថនោះ ។

បញ្ចសីលនេះ មានសភាពខុសស្រឡះពីបញ្ចសីលនៃព្រះពុទ្ធសាសនា ។

## បញ្ចសីលនៃព្រះពុទ្ធសាសនាមានដូចតទៅនេះ៖

១- វៀរចាកមិនសម្លាប់សត្វដោយខ្លួនឯង ឬប្រើគេឲ្យសម្លាប់ ។

២- វៀរចាកមិនលួចយកទ្រព្យសម្បត្តិអ្នកដទៃ ដែលគេមិនបានឲ្យ ដោយកាយ ឬដោយវាចា ។

៣- វៀរចាកមិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

៤- វៀរចាកមិនពោលពាក្យកុហក ។

៥ វៀរចាកមិនសេពសុរានិងមេរ័យ ។

លទ្ធិស៊ីនតូនិងព្រះពុទ្ធសាសនា ពិតមែនតែមានសភាពខុសគ្នា, ប៉ុន្តែ ក្នុងសតវត្សរ៍ទី៩ មានបណ្ឌិតខាងសាសនាស៊ីនតូម្នាក់នាម ជិនស៊ុ-ក្កូដៃស៊ី និងគូប៉ូដៃស៊ី បានប្រមូលលទ្ធិទាំងពីរឲ្យទៅជាសាសនាតែមួយ ហៅថា "សណ្ដូស៊ីនតូ ឬរីយូប៊ូស៊ីនតូ", ទៅតាមនៃសាសនាទាំងពីរទៅជាអរះលោកិតិស្វរៈ ។

នៅក្នុងព្រះវិហារស៊ីនតូនិងតែព្រះពុទ្ធសាសនា លោកកាមីនិងព្រះសង្ឃព្រះពុទ្ធសាសនា ចេញចូលបានតាមចិត្តដូចគ្នាឥតប្រកាន់ ។

លុះដល់សតវត្សរ៍ទី១៨ មានការចាប់កំណើតឡើងជាថ្មីនូវសាសនាស៊ីនតូដ៏បរិសុទ្ធដោយអំណាចពួកជាតិនិយម និងអ្នកស្នេហាមាតុប្រទេស ដែលនាំឲ្យកើតការបដិវត្តន៍ក្នុងឆ្នាំ ១៨៦៨ ។ ក្នុងពេលនោះ សន្តិវង្ស មិកាដូ ក៏បានឧប្បត្តិឡើងនៅប្រទេសជប៉ុន, ព្រោះចង់ចោលព្រះពុទ្ធសាសនា យកសាសនាស៊ីនតូជាសាសនារបស់រដ្ឋ ។ ការបដិវត្តន៍នេះ បានយកសាសនាស៊ីនតូពីបុរាណ និងសម័យបច្ចុប្បន្នមកចម្រាញ់បញ្ចូលគ្នា ។

# អ្វីហៅថាកាមី ?

កាមីគឺជាទេវតានៃប្រទេសជប៉ុន, ទេវតាទាំងអស់មាន ៧ រូប មាន ទេវតា កុនិ-កូតូ-តាជី ជាដើម និងទេវតា អ៊ីសាណាគី និងអ៊ីសាណាមី ជាជីដូនជីតានៃជាតិជប៉ុនជាខាងចុង ។

ទេវតាទាំងពីរ យើងបានពណ៌នាក្នុងរឿង "ចុះទៅស្ថាននរក និងរឿងស្ថាបនាពិភពលោក" រួចហើយ ។ នៅទីនេះ យើងសូមពណ៌នាដោយសង្ខេប ។ ក្រោយដែលព្រះនាង អម៉ាតេរ៉ាស៊ូ មានចិត្តទោមនស្សនឹងព្រះរៀមស៊ុសាណូ ក៏ចូលទៅលាក់ខ្លួនពួនអាត្មានៅក្នុងគុហា ដោយឧបាយនៃទេវតាឯទៀត ក៏ទ្រង់បានចេញពីគុហាមក, ទេវតាស៊ុសាណូក៏បានទៅជួយសង្គ្រោះនាងកញ្ញាឲ្យរួចពីចំណីពស់នាគរាជ ។ ការសមរសនៃទេវតាស៊ុសាណូនិងនាងកញ្ញា ក៏បដិសន្ធិទេវតា អូណាមុស៊ី ជាស្តេចក្រាញ់សោយរាជ្យនៅនគរអ៊ិដស៊ុម៉ូ ។

ពេលនោះ ទេវសភាបានជំនុំសម្រេចថា រាជសម្បត្តិនៃប្រទេសជប៉ុន ត្រូវថ្វាយទៅព្រះរាជនត្តា (ចៅ) នៃព្រះនាង អម៉ាតេរ៉ាស៊ូ ជាទេវតាខាងព្រះអាទិត្យមាននាមថា នីនីគី ។ នីនីគីនេះ ជីដូនទ្រង់បានព្រះរាជទាននូវវត្ថុពិសិដ្ឋ៣យ៉ាងគឺ: សិលាពិសិដ្ឋ ១ ព្រះខ័នរាជ្យ ១ កញ្ចក់ ១, ដោយមាន ទេវតា អាមីណូកូយ៉ាន ជាអ្នកដង្ហែ ចុះពីមហាមេឃមកប្រតិស្ឋាននៅ

កំពូលភ្នំ តាកាជិហូ នៅជិតទីក្រុង ហ៊ិយូគា មកសោយរាជសម្បត្តិក្នុងប្រទេសជប៉ុន, ទ្រង់បានធ្វើព្រះរាជសមរសនឹងនាងកញ្ញាមួយរូប នៅទីក្រុងសាត់ស៊ូម៉ា ។

ព្រះរាជនត្តានៃព្រះបាទនិនីគី ទ្រង់ព្រះនាម ជិម្មុតេណ្ណូ ទ្រង់បានចេញពីទីក្រុងសាត់ស៊ូម៉ា ធ្វើព្រះរាជដំណើរទៅកាន់ខាងជើងប្រទេស បានស្ថាបនាព្រះរាជអាណាចក្រមួយ ដែលមានរាជធានីនៅទីក្រុង យ៉ាម៉ាតូ ។ ព្រះរាជនត្តានៃព្រះបាទនិនីគីនេះ ជាព្រះរាជាធិរាជប្រទេសជប៉ុនជាបឋម សោយរាជសម្បត្តិ ពី ៥៨៥ ទៅ ៦៦០ឆ្នាំ មុនគ្រិស្តសករាជ ។

---

# រឿងមរណមាតា

លោក ប៉ី-សុវណ្ណ ចម្លងពីសាស្ត្រាស្លឹករឹត

---

## បទកាកគតិ

នមាមិហំ អតិវន្ទំ សុសម្ពុទ្ធោ លោកនាថ វរញ្ញាណោ ញាណុត្តមោ តម្បញ្ញុទំ ។ នមក្ការធម្មោ គុណាតិយុត្តោ យថាទីបំ ទីបោលោក វិយយានំ សុគម្ភីរំ វិយឆាក ។ នមក្ការំ សង្ឃគុណំ សតិន្ទ្រិយា អនុត្តរំ ខេត្តំជនា លោកបុញ្ញា សទាសោត្ថិ ។

ខ្ញុំលុតលើកករ កំបង់ទូនអរ ទូនអញ្ជលី ខមក្លាក កាយាវន្ទី បង្គំជិនស្រី ឪរនាថគតវ៉ ។ ព្រះអង្គជាមកុដ ត្រៃភពបំផុត ផ្កាលផ្កាញ់មាក ប៉ាក់បប្ខូបខ្ទាច អំណាចមហិមា ទ្រង់ត្រាស់ធម្មា ព្រោសប្រាណសព្វសត្វ ។ វ៉ង់វន្ទា សត្វទាវ ទឹកគុណពុទ្ធរត្ន មៈនោវន្ទា ចិន្តាគិតក្តាត់ គោរពប្រណិប័តន៍ ប្រ-ណំម្យវន្ទា ។ រំលឹកព្រះគុណ ព្រះត្រាស់ពីមុន អម្បាលខ្សាច់ព-សុធា ប្អូនសម្លុទ្រធំ ហើយខ្ញុំវន្ទា ទឹកគុណពុទ្ធា ក្នុងបច្ចុប្បន្ន ។ កាលបានត្រាស់ត្រាប់ ប្រាជ្ញាសព្វជ្ញ ព្រោសសត្វអនន្ត អនេកសន្ធិយា ដែលជាបុថុជ្ជន សិនលុះបានបុណ្យ អរហន្តសោតា ។

បង្គំពង្សពុទ្ធ ឯអនាគត សាងបារមីតា នឹងត្រាស់ឯក្ដក អនេកសង្ខេយ្យ
ហើយខ្ញុំវន្ទា ព្រះធម៌បរមត្ថ ។ ប្រាំបីម៉ឺនបួន ពាន់ពេញជាខ្ទួន ជាយាន
នាំសត្វ ដូចការកេត្រា សុវណ្ណាភយរ័ត្ន បើកបានឆ្លងកាត់ វដ្ដសង្សារ ៗ
បង្គំសង្ឃសុទ្ធ សាងសីលស្រគត់ សង្រួមកាយា ជាស្រែបុណ្យប្រាន
នាំប្រាណលោកា ដាក់ដល់ថ្កល់មហា អម្រឹតនិព្វាន ៗ ដោយតេជះខ្ញុំ
បានថ្វាយបង្គំ ត្រៃរ័ត្នថ្កើងថ្កាន ប្រកបដោយអង្គ បញ្ចង្គប្រតិស្ឋាន
ប្រសើរសូមមាន មង្គលសួស្តី ។ សូមឈ្នះទុក្ខភ័យ ឧបទ្រពចង្រៃ អន្តរាយ
អប្រិយ សូមឈ្នះលោភោ ទោសោតិរ័យ មោហោគុំបី មានមកដល់
ជិត ៗ បង្គំគុណគ្រូ គុណគាប់ពិរូឡ្ហ(១) ប្រដៅប្រៀនប្រិត ប្រៀបប្រើ
ប្រាជ្ញប្រាយ សុះសាយប្រសិទ្ធិ ធម៌អាថ៌ចូលចិត្ត ចាកបាបនានា ។ ហេតុ
នោះខ្ញុំនឹក ព្រះគុណល្ងាចព្រឹក សព្វទិនទិវ៍ នឹកគុណប្រធាន មែនមាន
ករុណា មាតាបិតា ជាងមានគុណគាប់ ។ គុណមហាក្សត្រា នោះ
ខ្ញុំពណ៌នា សរសើររៀបរាប់ គុណញាតិសន្តាន ព្រៀងលានគួរគាប់
មានគុណគំនាប់ ធ្ងន់ក្រៃមហិមា ។ កាលក្មេងសេចក្តី លោកទ្រពី
ចិញ្ចឹមរក្សា ចំណីចំណុក បញ្ចុកគោក្តា ថែទាំរក្សា លាងមូត្រលាង
លាមក ៗ ឈឺថ្កាត់កាលណា លោកៈមើលរក្សា ព្រួយប្រាណកើតទុក្ខ
អត់ទាំងភោជនា ភោក្តាពុំសុខ អង្គុយមើលមុខ មើលមិនឃ្លាតឃ្លា ៗ
ព្រះគុណធ្ងន់ក្រៃ ធ្ងន់ក្រកថ្លៃ កម្រឧបមា ធ្ងន់ក្រៃធារធំ ទើបខ្ញុំពណ៌-

---

១ គុណសព្ទភាសាមគធៈ ប្រែថា ដែលធំទូលាយ ។ អានថា ពិរូ ។

នា សរសើរស្បូត្រសា សូត្រសព្វល្ហួចព្រឹក ៗ ព្រះគុណប្រាំបី ប្រ-
ការពិសី ពិសេសអធិក មនោរាំងា ចិន្ដាខ្ញុំទឹក ខ្ញុំគិតលើក មិនលោះ
ទិវា ៗ ពុទ្ធសាសនំ ទ្វេសហស្សំ ចតុស្សតា - ធិកានិវី - សតិស្សា
មាសឯកា អតិក្កន្តំ ៗ អដ្ឋរស ទិនវារេ សុក្រុបញ្ចំ សុក្កបក្ខ អា-
សាឡ្ហមាសំ គិម្ហទានំ ចមសកា ៗ បច្ចុប្បន្នំ អនាគតំ គតកាលា
ទ្វេសហស្ស បញ្ចសតា សំវច្ឆរា សត្តតិឧត្តំ ៗ ឯកាទសោ មាសទិ-
នោ ទសទិនំ ពុទ្ធសាសនា អវសេសំ បរិបុណ្ណំ កវិស្សន្តា ៗ
អហំនាម នាមឥន្ទ- បញ្ញាភិក្ខុ មនោរម្យ ចិត្តការព្យា សោម-
នស្សា ជាទិច្ចនិរន្តរ៍ ៗ គិតតែងកាព្យ កាលពុទ្ធសាសនា កន្លងពីរ
ពាន់ បួនរយម្ភៃ[១] ឆ្នាំនៃខែខាន់ បានមួយខែស្បាន់ ថ្ងៃកន្លងត្រូវ ៗ
បានប្រាំបីដន់-ដប់បច្ចុប្បន្ន ចូលកន្លងឆ្នាំត្រូវ ខែអាសាឡ្ហមុន គិម្ហន្តរដូវ
លើកខែនោះត្រូវ អាសាឡ្ហពីរដង ៗ កន្លងថ្ងៃ៩កើត កបកាលឯទៀត
ថ្ងៃសុក្រៈសាគៈហាង សាសនាខាងខាន់ ពុំទាន់កន្លង ពីរពាន់ប្រាយផង
ប្រាំរយវស្សា ៗ ចិតសិបប្រាំបួន ឯខែខាងធ្នូ ដប់មួយមាសា ថ្ងៃ
ខាងដប់ថ្ងៃ គិតតែគណនា ធំរួគ្នាត្រូវជា វស្សាប្រាំពាន់ ៗ មហា-
សករាជគ្រប់ ឯកសហស្សនព្វន្ត[២] កំណត់កំណាន់ ចុល្លសករាជ ឯងអាច
គ្រប់គ្រាន់ ឯកគោ[៣]ផាក់ស្បាន់ គ្រិនព្វគណនា ៗ រីដើមនាមនោះ

---

១– ព. ស. ២៤២០ ។ ២– ម. ស. ១៧៩៩ ។ ៣– ច. ស. ១២៣៩ ។

ឈ្មោះអ៊ុកបំពោះ(១) មាតាបិតា សន្មតនាមឲ្យ តាមដោយមេត្តា លុះដល់ជន្មា បានពីរដណ្ដប់ ៗ ធ្វើការមន្ទិល ប្រសើរនិមិល គោរសេក់គ្រាន់គ្រប់ នាំមកបួសរៀន ប្រិតប្រៀនលុះចប់ ជួបចូលគម្រប់ ម្ភៃពីរវស្សា ៗ បានឧបសម្បទ លោកគ្រូគិតកាត់ គិតគូរនាមា ឲ្យត្រូវដោយខាត មារយាទកិរិយា ឥន្ទបញ្ញា(២) គិតគុប្រពៃ ៗ សំណាក់សាសនា ជួបចូលវស្សា គំរប់ម្ភៃ ប្លាយពីរវស្សា ចិន្ដាគិតគៃ គិតលើកដោយន័យដោយឧទ្ធារគាថា ៗ ក្រែងខ្ញុំលើកលោះ ពាក្យពុំចំពោះ ខាតខុសត្រង់ណា សូមលោកដ៏មាន ញាណប្រាជ្ញា មេត្តាករុណា តម្រង់ឲ្យផង ៗ កុំលោកតិះដៀល គួសកៀងផងនៀល កុំសើចឡើយមោង ផ្សិតទើបរៀនរ៉ះ ត្រេកត្រេះផ្គួង លៃលកលើកម្ដង ពាបតិចប្រាជ្ញា ៗ ព្រោះផ្សិតចិត្តបង់ យកអានិសង្ស ទើបខំបញ្ញា ជាគ្រឿងសំណាន់ ប្រាំពាន់វស្សា ក្នុងព្រះសាសនា សម្ដេចជិនស្រី ៗ ទីងពណ៌នាទិ- ពានគម្ពីរ សារសេច្ចបាលី ឈ្មោះចេតនា- ពុទ្ធាសេចក្ដី សម្ដេចជិនស្រី ត្រាស់ទ្រង់ទេសនា ៗ

---

១-២ លោកអ្នកនិពន្ធរឿងនេះ ជាភិក្ខុ នាមដើមឈ្មោះ អ៊ុក នាមឆាយា ឥន្ទបញ្ញា បួសបាន ២២ វស្សា ។

ថ្ងៃនពីក្សត្រី ព្រះនាមនាងស្រី មរណមាតា នាងសាងជាទី ជនទីគគាំ សពេជ្ញសាស្តា ចមចៅលោកនាថ ៗ កាលនាងរង្គាត់ អន្ទោលក្នុងវដ្ត សង្សារយកជាតិ មានកម្មបុរាណ តាមប្រាណពុំឃ្លាត កើតទុក្ខក្នុងជាតិ នោះគួរអនិច្ចា ៗ ចូរជនស្តៃស្តាប់ យកទុកជាច្បាប់ ខ្លួនអាត្មា គិតកើតកម្មពៀរ វេរៈវៀរបាណា គួរគិតអនិច្ចា សម្តេចក្សត្រីៗ នាងមានបាបធ្ងន់ បាបក្រាស់ពេកពន់ ពេកពុំប្រណី នាងយកជាតិជា កូនមហាសេដ្ឋី នោះនាងកាលី សម្លាប់មាតា ៗ ឯអគ្គក្សត្រី នោះនាង កាលី កាចកិនហិង្សា ស្ងោរនឹងប្រេងក្តៅ នាងនៅវេទនា លុះក្ស័យ ជន្មា ដោយពៀរបុរាណ ៗ ហេតុនេះសម្តេច សាស្តាសពេជ្ញ សម្តាធិញ្ញាណ សំដែងជាតក ទុកឲ្យបាន ស្តាប់ហើយឲ្យមាន សង្វេគអនិច្ចា ៗ កាលព្រះទ្រង់ញាណ ស្តេចគង់សម្រាន្ត នៅ ព្រះវិហារ នាមឈ្មោះវេឡុវ័ន សោភ័ណជាតិជា ទីមៀបនគរ រាជគ្រឹះបុរី ៗ ស្តេចគែងបិណ្ឌបាត ប្រោសសត្វសង្វាត សព្វថ្ងៃប្រក្រតី គែងទេសន៍ខ្ញុំនាន ប្រោសប្រាណប្រុសស្រី សព្វទិនរាត្រី ពុំលោះទិវា ៗ មានកាលមួយថ្ងៃ មហាថេរប្រពៃ ទ្រង់ព្រះនាមា ឈ្មោះអនុរុទ្ធ វិសុទ្ធបញ្ញា លោកចូលសមា- បត្តិបានសុខុម ៗ នៅក្នុងគុហា ឈ្មោះ ខន្ធមូលកា បពិតធេងធំ លុះចេញសមា- បត្តិជាសុខុម ហើយព្រះអគ្គរ- ពឹងដោយទិព្វញាណ ៗ មៀនមើលកំណើត សព្វសត្វកាលកើត

ក្នុងសង្សារស្ថាន ខ្លះសោតឲ្យត ស្រេចស្រុកឡើងបាន សួគិសុខពាក

ស្ថាន ជាតិជាមនុស្សា ៗ ខ្លះសោតរំលាង រលង់ខ្នួខាង ជាមនុស្ស

លោកា អន្ទោលជាតិទៅ ស្ថិតនៅចតុក- បាយបាបវេទនា ជាទុក្ខពេក

ពន់ ៗ ចាប់ប្រដិសន្ធិ ជាមនុស្សប្រុសស្រី កល់រូបជាតិជន យល់

ថ្ងៃកពីគ្នា ហាក់មហាធ្វល់លន់ មហាថេរគយគន់ ហើយគិតសង្ស័យ ៗ

ជារូបសព្វសត្វ ចាំនព្ទុនទៀងពាក់ ថេរបិតសព្វថ្ងៃ ហើយពុំទៀងវិញ

នពេញធ្វល់ក្រៃ ព្រះមហាថេរថ្ងៃ ព្រួយព្រះចិន្តា ៗ វិតក្កដូច្នោះ ហើយ

ទើបក្រោកដោះ ឡើងពាកអាសនា លីលាទៅស្រង់ ជ្រះអង្គអាត្មា

រួបចរលីលា ឆ្ពោះទៅវេឡុវ័ន ៗ លុះដល់មត់បាទ នទអង្គអភិវាទ

ព្រះមកុដសោភ័ណ ហើយមកអង្គុយ គង់ដោយខែត្រទំណូ កំណត់

កំណាន់ រួបពាកទោសា ៗ ប្រាំមួយបទខ្ចែក ពុំខ្ពស់ទាបពេក ពុំជិត

សោះសា ពុំធ្ងាយលន់លាក លង់ពាកអាសនា ពុំក្រោយរុញរា ពុំចំ

ភ័ក្ត្រត្រង់(១) ៗ ថ្វាយវន្ទនា ស្រេចហើយទូលថា បពិត្រព្រះអង្គ

អម្ចាស់ទ្រង់លក្ខណ៍ ដូនភ័ក្ត្រវរវង្ស ក្រាបទូលសូមទ្រង់ ប្រោសប្រាណ

---

១— ទំនៀមការអង្គុយគាល់ព្រះពុទ្ធ ត្រូវឲ្យរួចចាកទោស ៦បទ គឺ ១ មិនខ្ពស់ពេក, ២-មិនទាបពេក, ៣- មិនជិតពេក, ៤– មិនឆ្ងាយពេក, ៥– មិនក្រោយពេក, ៦មិនចំព្រះភ័ក្ត្រពេក ។

ករុណា ៗ ខ្ញុំទូលព្រះគុណ ធ្លល់នឹងមហាជន ប្លែកផ្សេងពីគ្នា ខ្លះកើត មកមាន រូបប្រាណសោភា ប្រកបប្រាជ្ញា ចេះថ្លាស់យល់ឈ្វេង ៗ ប្រកបស័ក្តិយស បុណ្យថ្កើងខ្ពង់ខ្ពស់ ចិញ្ចាចចំពេង ទិឃាយុកា ជន្មាអង្វែង កម្លាំងលើសលែង លើសលោកទាំងឡាយ ៗ មានតេជ តេជៈ តេជោតបៈ ជាសុខសប្បាយ មិនមានរោគា ដករបៀតកាយ បានទ្រព្យទាំងឡាយ មិនដែលបង់បាត់ ៗ ខ្លះកើតមកមាន ពេករូបរឹត ប្រាណ កំព្រាកំព្រាត់ ត្រមោចត្រមង់ ឯកឯគ្គខាត់ក្អាត់ ក្រីក្រសម្បត្តិ សម្បូរមិនល្អ ៗ គគ្រាតគគ្រិះ កុនក្មាយឆ្អាបឆ្អេះ សំឡេងឡេៗ អាក្រក់ ទាំងរាង ដូចពាងក្រឡ មាត់ជំប្រហ ប្រហាបសៀញស្វាញ ៗ អ្នកផង មើលយល់ រូបភាពទុពិល ស្អុះស្អាប់ក្នាន់ក្នាញ់ មិនមានមេត្តា ករុណា ស្រឡាញ់ ពុំពិតពុំពេញ ពន់ពោះស្នេហ៍ស្នាល ៗ បើហៅពោលស្តី ទៅកាន់ប្រុសស្រី តេពងតេចាល តេជនតេរិះ តេវេះមិនស្នាល មើល មកមមាល មមើតតភ័យ ៗ ជនតាំនោះណា លុះអស់ជន្មា ជិវិត ក្សិណក្ស័យ ហើយចាប់ជាតិជា មនុស្សវិស័យ ក្រកូលអាស្រ័យ ពុំដូច គ្នាទេ ៗ សម្តេចកគរ៉ ទ្រង់ស្តាប់ព្រះមហា អនុវ្រទូលថៃ ស្តេច បើកព្រះឱស្ឋ ទ្រង់ប្រោសប្រាណប្រែ ទេសនាថាឯ ជនតាំពួកនោះ ៗ លុះកាលក្ស័យដល់ បើបានសានផល ពីមុនមកស្មោះ ផលានិសង្ស ទ្រទ្រង់ចំពោះ កាលក្ស័យទៅនោះ បុណ្យនាំចិត្តទៅ ៗ ចាប់បដិសន្ធិ

សោយសុខនៅទី សួគ៌ឋានទិព្យនៅ បើបានធ្វើបាប ដរាបរៀងទៅ
បាបកម្មនោះនៅ នាំចិត្តចេតសិក ៗ វិញ្ញាណអាត្មា ចូលក្នុងចុក- បាយ
បាបភទ្ទឹក រងទុក្ខរងភ័យ សន្ធៃសន្ធឹក សព្វថ្ងៃស៊ីផឹក តែខ្ទុះនិងឈាម ៗ
ហៃហាអនុរុទ្ធ បុគ្គលរំលត់ ជីវិតៈទៅតាម ភវតណ្ហា ប្រាថ្នាវិមាន
វិលវល់រូបនាម ដោយក្តីប្រាថ្នា ៗ ហេតុនោះកំណើត កំណត់សត្វកើត
ក្នុងសង្សារ ប្រែប្រួលរូបថ្មក ចម្លែកពីគ្នា តាមកម្មវេរា នាំនាំ
វិញ្ញាណ ៗ ជាមនុស្សជាតិមុន លុះលាញជីពជន្ម កើតជាតិរប្លាន
ជាតិមុនខ្សត់ទ្រព្យ ត្រឡប់ជាបាន ចាប់ជាតិៈទៀតមាន សម្បត្តិមហិមា ៗ
សម្តេចសព្វញ្ញូ ជាព្រះបរមគ្រូ លើសលើលោកា ព្រះអង្គសំដែង
ធម៌ថ្លែងទេសនា ត្រាស់ថាហៃហា អនុរុទ្ធតេរអើយ ៗ បើបុគ្គលណា
តាំងចិត្តនិង- ការកម្មដ្ឋានហើយ តម្កល់ក្នុងចិត្ត ប្រព្រឹត្តរឿយៗ ពុំគិត·
ហាត់នឿយ ដោយចិត្តមោហោ ៗ ដើមថាកេសា លោមានខា ទន្តាតៈចា
តម្កល់ចិត្តថ្នាក់ កើតកាត់មោហោ អាចនាំរូបោ បៀសបាបទុក្ខា ៗ
ដូចនាងមរណៈ មាតាៈសាកៈ នាងកាវនាថា ហទយំ ៗ តាំងក្នុងចិត្តា
កើតឡើងបានជា មានចិត្តទិព្វល្អ ៗ នោះមនុស្សយោរយោដ ចិត្តចង់
ប្រមាថ អង្គនាងកម្រ តេជៈធម៌ថ្លៃ ប្រពៃបវរ មានចិត្តទិព្វល្អ ដូចបាន
ពណ៌នា ៗ សម្តេចភគវន្ត ទ្រង់មានព្រះបន្- ទូលទៀងទេសនា

ប៉ុណ្ណោះស្ងៀមស្ងប់ បញ្ឈប់ពុទ្ធដីកា ព្រះអនុរុទ្ធា ទុនក្រាបក្រួញប្រាណ ។ បង្គំទូលថា បពិត្រព្រះមហា ករុណាសូមទាន សំដែងជាតក ទៀនទុក្ខ ប្រោសប្រាណ យើងខ្ញុំឲ្យបាន វិត្ថារពិស្តារ ។ ព្រះដ៏មានបុណ្យ ទទួល និមន្ត ទ្រង់មានពុទ្ធដីកា នាំអតីតនិ· ទានពីវាសនា មរណមាតា ជាតកកន្ទង ។ ហៃបាអនុរុទ្ធ- ត្រូវអើយចូរផ្គត់ សោតាចាំចង គេរកល្បាន់ខាំង កំបាំងរំលង មានក្សត្រជាច្បង ចមទៅភាព ។

## បទព្រហ្មគីតិ

ទឹងថ្លែងតែងដោយដាន កាលនោះមានក្សត្រសោភា ស្តេចទ្រង់ ព្រះនាម ព្រះបាទវិមលធម្មរាជ ។ ឯកអគ្គឥតមហេសី ព្រះចក្រទ្រង់ អំណាច អស់ក្សត្រផងទ្វីបខ្វាច សឹងចូលមកថ្វាយបង្គំ ។ ឯនាមនគរ ឈ្មោះវិទេហៈដ្ឋរាជរម្យ ជាស្តេចឯករាជ្យធំ លើសទាំងស្តេចរយឯកា ។ ស្តេចគង់លើប្រាសាទ កែវស្អាងស្អាតវែងជ្រះថ្លា ទាំងប្រាំសុវណ្ណ រៀង រាយគ្នាយ៉ាងប្រណីត ។ សឹងស្រស់ខ្ពស់ត្រដួច រស្រាងស្រៀវស្រួច ស្រៀបពីចិត្រ ដាំត្បូងសព្វបូពិធ វិត្ថរលេចមានរស្មី ។ ភ្ញីច្ចេកៗគ្រប់ លម្អតាមល្អះរៀងរង្សី មានក្មេងក្លូវគេត្រី ដំប្រគំសព្វវេលា ។ មន្ត្រីចតុស្តម្ភ ទៀនគាល់ជុំច្រើនត្រៀបត្រា ស្រីស្នំបរិវារ ច្រើនអនេកអនន្តក្រៃ ។

(នៅមានត)

# រឿងព្រេង

## ចែងអំពីអ្នកប្រើគំនិតខុសនាំឲ្យមានទុក្ខដល់ខ្លួន

លោក អ៊ុន-អេង លេខាធិការ នៃក្រុមព្រឹក្សាព្រះរាជអាណាចក្រ រៀបរៀង

---

ក្នុងកាលកន្លងទៅហើយ មានបុរសម្នាក់ ជាអ្នករកស៊ីលក់ដូរមានធនធានគ្រាន់បើ, គាត់មានកូនប្រុស៤នាក់ មានអាយុគ្រប់ការទាំងអស់ ។

ក្រោយពីពេលដែលប្រពន្ធអនិច្ចកម្មទៅ គាត់ទ្រាំនៅជាពោះម៉ាយ ពុំយកប្រពន្ធទៀតទេ នៅជាមួយនឹងកូនប្រុសអស់១ឆ្នាំ មានការលំបាក ដោយខ្វះស្រីមេផ្ទះជាអ្នកចំអិនអាហារ នឹងជួយមើលថែទាំរបស់ទ្រព្យ កំប៉ិកកំប៉ុកក្នុងផ្ទះ, គាត់ក៏រៀបការប្រពន្ធឲ្យកូនច្បង ហើយយកកូនប្រសារស្រីមកនៅជាមួយ ចែកទ្រព្យអស់ ១ ចំណែកឲ្យដាច់ស្រឡះទៅកូនច្បងរួចទៅ ។

លុះរំលង ១ ឆ្នាំក្រោយមកទៀត ក៏រកប្រពន្ធឲ្យកូនទី ២ ចែកទ្រព្យ ១ ចំណែកឲ្យដូចគ្នា ។

តមក គាត់រៀបការកូនទី៣ ចែកទ្រព្យ ១ ចំណែកឲ្យទៀតៗ ដល់ឆ្នាំជាគំរប់ ៤ ក៏រៀបការឲ្យកូនទី ៤ ចែកទ្រព្យ ១ ចំណែកទៀតដែរ ។ នៅសល់តែផ្ទះ ១ ខ្នងពុំបានចែក គាត់ទុកនៅទាំងអស់គ្នា ។

ដែលគាត់ចែកទ្រព្យរបស់ឲ្យអស់រលីងពីខ្លួនដូច្នោះមកពីគិតថា ឲ្យស្រឡះខ្លួនគាត់, ហើយនៅទំនេរស្ងៀម, ចាំឲ្យកូនរកស៊ីចិញ្ចឹមវិញ រហូតដល់ស្លាប់ ប៉ុន្តែ គំនិតគាត់គិតខុសស្រឡះ ។

កាលដែលគាត់នៅជាមួយកូនប្រុស ៤ នាក់ កូនទាំងនោះស្រឡាញ់បងប្អូនណាស់ ពុំបានបែកចិត្តគំនិតពីឪពុកនិងបងប្អូនឡើយ ។

លុះបានប្រពន្ធមករៀងខ្លួនហើយ ក៏បែកចិត្តគំនិតផ្សេងៗពីគ្នា នៅរួមជាមួយគ្នាពុំសូវបានសុខ ចេះតែស្កៀបរមាស់, បន្តិចពាស់នេះ បន្តិចពាស់នោះ, ក៏នាំគ្នាចុះចេញពីផ្ទះកំណើត ទៅរកសង់ផ្ទះនៅទីទៃពីគ្នាទាំងអស់ ចោលតាឪពុកពោះម៉ាយ ឲ្យនៅតែឯកោអនាថា ។

នាកាលកូនទាំង ៤ នាក់ ទើបនឹងចុះចេញពីផ្ទះឪពុកថ្មីៗ នៅហុចបាយ ហុចចំណីតាឪពុកបន្តិចបន្តួចរាល់ៗថ្ងៃ, លុះមានកូនខ្ចីគ្រប់គ្នា ជួនពេលប្ដីរវល់ដើរជួញទៅស្រុកឆ្ងាយ ភរិយានៅផ្ទះអាងតែប្ដីមិននៅ អាងមានកូនខ្ចីផង, ក៏បង្អង់ជូនបាយទឹកឪពុកក្មេក ដោយមេខ្លះគិតថា ប្រហែលប្អូនគេឲ្យហើយ, មេខ្លះគិតថា បងឯណោះគេឲ្យហើយ កូនប្រសា នាំគ្នាគិតដូច្នេះតែរៀងខ្លួន យូរៗថ្ងៃទៅ តានោះអត់បាយ ១ ពេលក៏មាន, ២ ពេលក៏មាន ។

លុះដល់វេលាប្ដីមកពីរកស៊ីវិញដឹងរឿងនេះ បានស្ដីបន្ទោសប្រពន្ធ នាងភរិយាដោះសាថា កូនឈឺ ខ្លះថា ខ្លួនពុំនៅ រវល់ទៅជួយញាតិ

ជិតខាង ស្រេចតែមេប្រពន្ធវាដឹកមុខ ; ប្ដីតាមវាទាំងអស់ ។

ចំណែកតាពោះម៉ាយ អត់បាយគ្មានសំពត់អាវស្លៀកពាក់ ដល់ថ្នាក់ដើរសុំទានគេបរិភោគ រីឯខ្ទមវេទនាពន់ពេក បើទីលក់ផ្ទះ១ចាស់ទ្រាំទ្រា ពុំបានថ្ងៃប៉ុន្មានផង ហើយគ្មានជ្រកនៅផង ។

កាលណោះ មានបុរសម្នាក់ នៅកំឡោះ មានចិត្តសប្បុរស ហើយជាអ្នករៀនសូត្រចេះដឹងច្បាប់ទំលាប់ស្គាល់គុណទោសច្រើន , ផ្ទះនៅភូមិជិតគ្នា ដើរមកឃើញតានោះវេទនាដូច្នោះ មានចិត្តអាណិតក្រៃពេក ក៏សាកសួរថា „លោកតា ! ខ្ញុំធ្លាប់ឃើញលោកតាពីដើម ជាអ្នកមានគ្រាន់បើ ឳពុកម្ដាយខ្ញុំក៏ធ្លាប់ទីពឹងលោកតាខ្លះដែរ ម៉េចក៏ឥឡូវនេះលោកតាវេទនាខ្លាំងម្ល៉េះ , ក្រែងលោកតាមានកូនប្រុស ១ ដល់ទៅ៤នាក់ដែរ ម៉េចក៏កូននោះ វាមើលចំណាំមិនថែទាំលោកតាសោះ ក្រែងទ្រព្យរបស់លោកតាមានសល់ទុកខ្លះដែរឬ ? បានជាលោកតាមិនយកទៅទិញគ្រឿងបរិភោគប្រើប្រាស់ ?” ។

តាចាស់នោះប្រាប់ទៅវិញថា „ឱហ្ន៎ ! លោកចៅអើយ ! លាក់បាំងអីពីដើមតាមានទ្រព្យគ្រាន់បើពិតមែន , ប៉ុន្តែតាអាណិត-ស្រឡាញ់កូនខ្លាំងពេក ក៏ចែកឲ្យវាគ្រប់គ្នាអស់លើងពីខ្លួនទៅ គិតថាចាំឲ្យវាចិញ្ចឹមតាវិញ , ឥឡូវពួកវា មានប្រពន្ធហើយថែមទាំងមានកូនទៀត វាឃើញឯងអស់ទ្រព្យលើងពីខ្លួន វាឥតនឹកនារកតាសោះ វាតាមតែប្រពន្ធទាញទៅចូលក្នុងរន្ធក្ដាម ក៏វាចូលដែរ , ខ្លួនតាសព្វថ្ងៃឈឺផង នៅតែម្នាក់

ឯងម៉ង់១ វេទនាជាបំផុត ដេកសម្រុកតែមកក្អកជោកខ្នើយអស់ ហើយ បាយព្រឹកជាបាយល្ងាច នឹងធ្វើការរកស៊ីក៏មិនកើតពីព្រោះចាស់ជរា គ្រាន់តែដើរស្ទើរតែមិនរួចទៅហើយ ។ ដូចលោកចៅឃើញស្រាប់ តាដេកចាំតែដល់ថ្ងៃស្លាប់ទេ ” ។

ចៅកំឡោះលាន់មាត់ថា “យីអើ! កូនតាមានចិត្តអាក្រក់ដល់ម៉្លឹងហ្ន៎ះ បើអ៊ីចឹងលោកតាកុំភ័យ, ខ្ញុំមានឧបាយមួយ ធ្វើឲ្យលោកតាបានសុខកាយសប្បាយចិត្តដូចពីដើមវិញ, លោកតាធ្វើតាមខ្ញុំ ឲ្យលោកតារកពាងមានមាត់តូចល្មម១ ដុះអាចម៍នឹងនោមដាក់ឲ្យពេញហើយរកកំណាត់សំពត់ចងរុំបិទមាត់ឲ្យជិត, ដីកកប់ក្នុងដីជិតជើងសសរទ្រូងផ្ទះ, ហើយបើមានអ្នកណាដើរមក ឲ្យលោកតានិយាយប្រាប់គេថា “ខ្ញុំនៅសល់កំណប់ប្រាក់.មាស១ពាងកប់ទុក ពុំទាន់ចែកឲ្យកូនណានៅឡើយ ចាំមើលកូនណាចិត្តបាន ដឹងផល, បើខ្ញុំរៀបស្លាប់នឹងប្រគល់ឲ្យទៅកូននោះ” លោកតានិយាយប្រាប់មនុស្សដែលជួបកុំខាន, ក្នុងរវាងប៉ុន្មានថ្ងៃ-ខែខាងមុខនេះ កុំឲ្យលោកតាដើរទៅសុំទានគេទៀត, ចាំខ្ញុំយកបាយទឹកមកជូនពិសាកុំឲ្យព្រួយ ” ។

តាចាស់ ក៏តាំងធ្វើតាមចៅចិត្តសប្បុរសទាំងអស់ ។ លុះបានប្រហែល ៤ ថ្ងៃ សំដីតានោះ បានដឹងដល់កូនប្រុសនិងកូនប្រសាទាំង ៨ នាក់, វាមានចិត្តលោភចង់បានកំណប់តែរៀងខ្លួន, ក៏នាំគ្នា

យកបាយ ទឹកម្ហូបចំណីផ្លែឈើទុំខ្ចីគ្រប់មុខ ទាំងសារុង-អាវ ក្រមា យកមកផ្គាប់ផ្គង់ជូនតាឥតពុករៀងរាល់ថ្ងៃ ពុំមានខានថ្ងៃណាមួយឡើយ, តាចាស់បានសះជាពេក មានសាច់ឈាមស្រស់បស់ មានកម្លាំងពលំ, សប្បាយកាយសប្បាយចិត្ត តាំងពីថ្ងៃនោះមករហូតដល់អស់អាយុ ។ លុះតាស្លាប់ហើយ កូនក៏នាំគ្នាធ្វើបុណ្យអធិកអធ័មតាមទំនៀមរួចស្រេច ។

ចៅកូនទាំង ៤ នាក់ ទាំងភរិយាគិតនាំគ្នា គាស់ពាងកំណប់ចែកគ្នា, ប៉ុន្តែក្រែងចែកមិនស្មើភាគនាំឈ្លោះប្រកែកគ្នា ក៏ទៅអញ្ជើញគ្រូម្នាក់ឲ្យមកជួយចែក, លោកនោះទទួលព្រម, ប៉ុន្តែគាត់ឮថា កំណប់មាសប្រាក់ ច្រើនដល់ទៅ ១ ពាង, គាត់ចង់បាន ១ ចំណែកដែរ, ហើយគាត់គិតក្នុងចិត្តថា គាត់ធ្វើមចំណែកត្រូវបានច្រើនជាងកូនចំណែកផង, គាត់ក៏ដើរត្រូតរះមកដល់ផ្ទះកំណប់ភ្លាម, តាំងយកកួយធំមួយមកវុជួតក្បាលធំទើងមើង ធ្វើឲ្យខូងកណ្តាល ដូចគេទូលជើងចានផ្កា, ក៏តាំងអង្គុយពែនភ្នែនលើថ្ពួដីពបរលើង ធ្មេចភ្នែកសម្រួមស្មឹងស្មាធិ៍ ឈមមុខត្រង់ទៅទិសខាងកើត, ហើយគាត់ប្រាប់ចៅទាំង៤នាក់ ឲ្យទៅគាស់យកពាងកំណប់មក ប៉ុន្តែ គាត់ហាមកុំឲ្យទាន់អាលស្រាយមាត់ពាងក្រែងខុសគ្រូណាម ចាំគាត់បង្គាប់ លុះយកពាងមកដល់ហើយគាត់ឲ្យចៅទាំង ៤ នាក់ ឈរគ្រប់ទិសទាំង ៤ ធ្មេចភ្នែកយកដៃទាំងអស់គ្នាចាប់លើកពាងទ្រសួយប្រទូលលើក្បាល ហើយសឹមស្រាយចំណងមាត់ពាង, នាំគ្នាផ្អៀងមាត់ពាងស្រោចកំណប់មកលើក្បាលគាត់

បើកំណាប់ផ្ទុសធ្លាក់ទៅទិសណាប៉ុន្មាន ៗ ត្រូវបានទៅអ្នកឈរកំណាន់
ទិសនោះ ៗ កំណាប់ណានៅសល់ទើះលើឆ្ពួតក្បាលគាត់ ត្រូវបានជា
រង្វាន់លោកគ្រូទាំងអស់ ៗ

ចៅទាំង ៤ នាក់ ក៏ចាប់ធ្វើតាមបង្គាប់លោកគ្រូមិនហ៊ានឲ្យល្អៀង
ខាងកិរិយាទាំង ៤ នាក់ ឈរកាន់កញ្ជើរៀងខ្លួនចាំកើប ៗ

ក្នុងពេលដែលបែកកំណាប់នោះ, មានអ្នកស្រុកជិតខាងទៅចាំ
មើលដែរ ៗ

និមិត្តតែគេលើកពាងប្រទូលរួច ស្រាយមាត់ពាងផ្អៀងចាក់ឈ្មូរមក
"ទឹកម៉ាំត្រាំលាមករប្រេនខួប" ហូរឆស្រោចលើក្បាលលោកគ្រូពេញកំពុង
ហើយខ្លាតបាចសាចចេញទៅគ្រប់ទិស ប្រឡាក់ប្រឡូសពាសពេញមុខ
មាត់ទីងសារ៉ុង អាវ ហូតដល់នាងប្រពន្ធទាំង ៤ នាក់ លោកគ្រូបាន
ចំណែកច្រើនជាងគេ, ជំនិនដោះខ្លួរ ក៏ថាមិនត្រូវ គេឃើញលោកគ្រូ
ស្រមុំវ ៗ បាត់មុខបាត់រូបរាងអស់ ទំរោកឡើងសោះកគ្រោះ ខ្ញាសអស់
ពួកបរិសទដែលឈរចាំមើល ពួកបរិសទក៏ផ្អើលរត់ចេញប្រជេញគ្នា
ទៅផ្ទះរៀងខ្លួន; ទើបលោកគ្រូស្រែកដេរកែសំឡូទៅចៅទាំង ៤ នាក់
នឹងនាងកិរិយាថា "ខ្មោចមេដែន អាដែងទាំងអស់គ្នា អា-មេបានធ្វើបាប
ខ្មោចឪពុកវាច្រើនណាស់ហើយមើល. ទៅ បានជាកំណាប់មាស-ប្រាក់

អន្ទកយក្លាយទៅជាអាចម៍-នោមប្រឡាក់ខ្លួនអញអស់ដូច្នេះ យី! ខ្មោចអាផេះ មេផេះ ៗ

លោកគ្រូនឹងកូនសិស្សនាំគ្នាតក់ហ័ស លោកចំលាក់ខ្លួនទៅទទេ្ទ ប្រង៍ ចំលានបាចអស់ ១ម៉ោងម្នាក់ ៗ រួចនាំគ្នាឡើងទៅផ្ទះរៀនខ្លួន; បានសេចក្ដីក្ដៅក្រហាយស្ដាយក្រោយ ខ្មាសគេគូទ-ទៅ ៗ

ល្ងោយអំណោយបានទុក្ខ
ភ្លេចឪពុកបានស្អុយ
គ្រូល្មោភបានរួយ
រោមសំអុយពេញខ្លួន ៗ

រឿងនេះ បានផលល្អ អាក្រក់យ៉ាងណា ៗ សូមជនប្រុស-ស្រី ចាស់ក្មេង គប្បីសំគាល់ទុកជាគតិទៅ ៗ

# រឿងហង្សយន្ត

( តមក )

លោក អ៊ឹម-ភន ចម្លងពីសាស្ត្រស្លឹករឹត

---

## បទកាកគតិ

នាងធ្វើជាភ្ញាក់ ដឹងស្មារតីជាក់ ស្ទុះចេញម៊ីម្មា នាងធ្វើងឹងណាស់ ខឹង

ព្រះពជា នាងនាថបរបា ហាក់មិនមេត្រី ៗ ថាអង្គឹកល អញមិនដែល

យល់ ដូច្នេះតើអ្វី ប្រុសម្ដេចចិត្តធំ យល់ពុំដឹង មកចាំងរាត្រី ទឹងដេក

ពុំបាន ៗ អញ្ជើញស្ដេចទៅ ស្រុកទេសលំនៅ នគរក្សត្រក្សាន្ត កុំបីព្រះ

អង្គ ផ្សះផ្សងនៅស្ថាន នេះនាំរំខាន ពុំបានទេណា ៗ

## បទព្រហ្មគីតិ

ស្ដេចត្រាស់ស្ងួនវិលវិង ថាព្រះលឹងមាសស្នេហា កុំអាលទៅពុំងា

ទឹងទឹងបងណានាងអើយ ៗ ចូរប្អូនមាសស្ងួនស្ដាប់ បងនឹងប្រាប់ដំណើរ

ឡើយ ឲ្យប្អូនមាសត្រាណត្រើយ ដឹងរាយរាប់ដើមបងមក ៗ កាលបង

នៅនាយណា ព្រះបិតាអ្នកឲ្យយក អស់បុត្រីពន្ទុក ស្ដេចមួយរយនឹងមួយ

ណា ៗ សឹងមានរូបពិសី ហាក់ដូចស្រីទេពស្ងួតា ទឹងឲ្យជាពន្ធិតា

បងពុំយកដល់មួយឡើយ ៗ បងព្នានាមប្អូនទៅ ល្បីព្នាទៅដល់បងហើយ

ព្រលឹងមាសបងអើយ បងជាទុក្ខពីថ្ងៃនោះ ៗ បងអត់ចាំងអាហារ ពីថ្ងៃ

កាលបងព្នាឈ្មោះ ប្អូនទៅដល់បងនោះ បងជាទុក្ខពន់ពេកក្រៃ ៗ

បងផ្អូកចង្គិះចិត្ត ពុំភ្លេចគិតដល់មួយថ្ងៃ ដំរិតបងនេះស្ទើរក្ស័យ ដៀត
តែបងក្ខុឈ្មោះប្អូន ៗ ពីព្រះអង្គក្សត្រថ្ងៃ ព្រួយព្រះទ័យ ជាទុក្ខធ្ងន់ ទើប
ស្តេចឲ្យធ្វើយន្ត ហង្សមាសមួយឲ្យបង ៗ បងបានហង្សយន្តនោះ
បងកើតហោះមកតាមរកប្អូន សូនស្នេហ៍ស្ងួន ឲ្យបានដូចចិត្ត
ចិន្តា ៗ ឥឡូវបងមកដល់ ប្អូនមិនមិលមាសពុំឆ្ងា ម្តេចឡើយនាងមកជា
ឲ្យបងវិលវិងទៅហោង ៗ គួរតែប្អូនស្នេហ៍ស្និទ្ធ នាងអាណិតអាសូរបង
អាសូរដៀតប៉ុនប៉ង ស្ទះស្នែងមករកប្អូនពៅ ៗ គួរតែប្អូនស្រីស្រួល
នាងទទួលយកបងទៅ ជាប្តីនាងប្អូនពៅ សឹងសម្បូរស្តេចដូចគ្នា ៗ
បើប្អូនអាសូរបង កាលនេះម្តងដូចប្រាថ្នា គុណប្អូនមាសស្នេហា ធ្ងន់
អនេកពេកក្តាត់ហោង ៗ បងដូចកលពស់ខាំ ប្អូនជាថ្នាំលាយលាបបង
ស្រាកស្រាន្តជម្ងឺផង មានប្រការនោះម្តេចមិញ ៗ បងនឹងសងគុណធ្ងន់
នាងស្រីគន់ប្អូនសំឡាញ់ ឲ្យថៃឲ្យថ្លៃវិញ ព្រោះនាងមានគុណនឹងបង ៗ
នាងស្តាប់ព្រះឧង្កា ហើយនាងទាចទូលវិងស្នង ខ្ញុំអរព្រះអង្គហោង
សង្ហាតមកត្បិតតែខ្ញុំ ៗ ខ្ញុំទនប្អូនដូចព្រាត្យ ទ្រង់ផលាបរិបូណ៌ពុំ
មានម្ចាស់រក្សាសម ស្តេចនឹងបេះឯងពុំបាន ៗ បើទ្រង់សព្វព្រះ-
ទ័យ សូមមាសថ្លៃទ្រង់ទៅថ្កាន ក្រាបទូលមហាក្សត្រក្សាន្ត ជាព្រះ-
បិតាមាតា ៗ បើពីរអង្គក្សត្រថ្ងៃ សព្វព្រះទ័យទ្រង់ករុណា ខ្ញុំ
ប្អូនឥតបើថា ពុំប្រកែកប្រកួតឡើយ ៗ ស្តេចឆ្លើយស្នងវិញថា

ហៃប្អូនក្លាមាសបងអើយ កុំថាដូច្នោះឡើយ ស្ងួនតែត្រូវសង្កាកល ៗ ខ្លួនប្អូនគឺដូចផ្កា ចន្ទន៍ក្រស្នាវិសេសសល់ ដើមដុះឥតគេយល់ ពីដើរតែផ្កាល្ងល្ងើយ ៗ បើបងបានក្លិនផ្កា ស្រេចហើយណាមាសបងអើយ ឯដើមពុំគ្រឡើយ បងកេឃើញទេណា៎ហោ ៗ បើយើងទាំងពីរនាក់ បានរួមរ័ក្សមួយលំនៅ សឹងបងនឹងប្អូនពៅ យើងត្រិះរិះគិតផងគ្នា ៗ ទាំងនេះទុកអារបង បងនៅរក-រង់ជានា លែងតែពៅពុំឆានាន់ចូលចិត្តព្រមនឹងបង ៗ ទើបនាងសង្ស្រៃ ថាគាប់ចៃព្រះអង្គហោង យកខ្លួនជានារង អស់ប្រការទាំងនេះណា ៗ គឺមោះខ្ញុំមិនភ្លាយ ខ្ញុំមិនដោយព្រះពជា ពាក្យប្រុសរែងមាយា ពុំសត្យាទៀងដល់មួង ៗ ខ្លួនប្អូនដូចព្រឹក្សា មានសាខាជាបង្គង់ ព្រះអង្គដូចឃ្មុំផង ទំផ្ញើហើយៗហើរទៅ ៗ ឯឈ័មិញឥតការ ខ្លួនសារទំនេរនៅ ប្រ-ដូចខ្លួនប្អូនពៅ ជាមេម៉ាយប្រាកដហើយ ៗ ក្រែងបងបោះបង់ទៅ ឲ្យនាងនៅឯងឥតត្រើយ ព្រលឹងមាសបងអើយ បងនាងនឹងរស់មួយបានខហេតុតៀតបង់ស្នេហា ប្អូនណាស់ណាពន់ប្រមាណ ទើបបងបោះបង់ហេខសង្ហាកមកឲ្យបានដល់ ៗ ចិត្តបងស្រឡាញ់ហៅ ដូចសំពៅស្រឡាញ់ខ្យល់ ស្ទាប់សេកីគាប់កល បងពុំគិតស្តាយអាត្មា ៗ ខ្លួនបងនេះដូចគ្រុឌ ប្អូនប្រាកដដូចនាគា បានដៃគ្រុឌហើយណា៎ ពុំដែលលែងនាគនោះហោង ៗ ឥន្ទ្របង់ដូចខ្លួនខែង នាងប្អូនឯងដូចមាន់ផង ខ្វែងឆាប

បានហើយហោង ពុំដែលបង់ចោលម្បៀតសល់ ៗ ខ្លួនបងដូចកលធ្លា ខ្លួន
ប្អូនក្បាលដូចគណ្ឌរ កាលបើបានគាប់គល ក្តីមាត់ផ្កានោះមែនមិញ ៗ
ឯផ្កាពុំដែលទ្រើម ពុំដែលផ្អើមទីងលែងចេញ ប្អូនអើយឯអង្គរញ ចង
ចបមាដូរធ្លោះហោង ៗ សូមប្អូនមាសបណ្តូល នាងកាសូរប្រណីបង
ស្បៀដូចក្តីបំណង ណាំព្រលឹងមាសបងអើយ ៗ ត្បិតបងកំព្រាសល់
ឥតឯយល់អ្នកណាឡើយ មានតែប្អូនឯងហើយ សូមប្អូនមាសមេប្រ-
ណី ៗ កាលបងនៅស្រុកនាយ មានអ្នកម្តាយស្ងួនបេតី មកកាយ-
មានប្អូនស្រី បងនឹងផ្ញើខ្លួនលើហោ ៗ គោះបីបងគាប់ខុស ចងស្តាប់
រស់លើប្អូនពៅ ត្បិតបងស្រឡាញ់ហៅ ស្នើខ្លួនមួយរួមជីវ ៗ បើសិន
បងលេបបាន ដោយចិត្តក្បាន្តដូចចំណី បងនឹងលេបប្អូនស្រី សោះ
ប្អូនមាសមានសង្ស័យ ៗ នាងស្តាប់ព្រះភូមី នាងនារីពេញព្រះទ័យ
ទើបនាងសងស្រាម ថាគាប់ចៃព្រះពជា ៗ ចេះបន្ទូលពីរោះ តែតង់ពោះ
ពុំដូចថា ឯអង្គប្អូនទោះណាំ មិនស្រែបស្រួលដោយព្រះអង្គ ៗ ពាក្យ
ប្រសរើងប្រែក្លាយ អកប្រោយល្អងលោមចង់ បានហើយបោលបោះ-
បង់ ឲ្យតែស្រីអសារសល់ ៗ ប្អូនគិតប្អូនជញ្ជីង ប្អូនពឹងហើយប្អូន
យល់ ចំណោរទៅទីងទល់ ទុក្ខម្នាកឯងឃើផ្សាក្រៃ ៗ កុំព្រះអង្គបាំខ្ញុំ
ឡើយខ្ញុំពុំដោយក្បត្រៃថ្ង អញ្ចើញទៅគ្រងផ្ទៃ ក្រោមព្រះអង្គឯនាយ
ណាំ ៗ ក្បែណានោះព្រះចមបក្រ ធ្វើជាអាក់អន់ចិន្តា ខ្ញាល់នឹងរដោយា

បន្ទូលបកក៏ពុំមេត្រី ៗ ថាអញអន្ទឹកល អស្ចារ្យសល់ពុំដូច ប្រឡាញ់តែ
ថ្លៃស្រី ពុំគិតគេក្តីគេទន្ទា ៗ គេទឹងគេបណ្តោញ មិនស្រឡាញ់ខ្លួនឡើយ
ណា គិតគាប់គួរយាត្រា ក្រឡាប់ទៅគូរគាប់ក្រៃ ៗ ស្តេចទិតចូលដិតខាង
ជិតដល់នាងនាថថ្លាថ្លៃ ទើបស្តេចត្រាស់ថាហៃ ប្អូនព្រលឹងមាសស្នេហា
បងនឹងសូមថើបទៅ បងនឹងទៅឥឡូវណា សោះតែស្រណោះគ្នា ឥត
បុណ្យគូនាងឡើយ ៗ ស្តេចកៀកព្រះស្មុង រំពេចផងពុំលង់ឡើយ
ឯនាងនាថខ្មាសហើយ ដាក់ព្រះហស្តចេញវិញណា ៗ ស្តេចថាហៃ
ប្អូនគន់ កុំទុជនទឹងបងក៏ ដៃជិតប៉ុណ្ណោះណា គេទឹងក្តៅក្រហាយអ្វី ៗ
នាងស្តាប់ព្រះវៀមហើយ នាងពុំឆ្លើយស្នងព័ទ នាងខ្មាសព្រះភូមិ ទុន
សញ្ចប់ពុំចរចា ៗ ព្រះអង្គថាហៃទៅ បងនឹងទៅឥឡូវណា កោតតែនាង
ប្អូនភ្ញា មិនអាសូរបងជាស្តេច ៗ បងលាប្អូនទៅហោង ទីងទៅត្រង់បុត្រី
ស្តេច សឹងមានរូបស្រស់ស្រេច នាំងរយឯកអង្គនារី ៗ អង្គបងអភ័ព្វហើយ
មាសបងអើយបងនៅថ្វី នៅនេះខ្មាសប្អូនស្រី ឥឡូវបងទៅគាប់ក្រៃ ៗ ខ្លួន
បងឥតទ្រព្យ ប្រសើរជាឲ្យប្អូនថ្លៃ មានតែពាក្យនេះនៃ បងផ្គួផ្គាប់ព្រះ
ប្អូនស្រី ៗ ចាំពីថ្ងៃនេះទៅ កុំប្អូនពៅមាសមានប្តី ស្មួនបួសជានាងជី នោះ
ប្រសើរពេកក្តាត់ណា ៗ អម្បាលបងជាក្សត្រ ក៏ប្អូនគេនមិនស្នេហា ហើយ
ប្អូនរកឯណា ឲ្យសមគួរនឹងប្អូនស្រី ៗ បងនឹងលាប្អូនទៅ សូមនាងនៅឯក
ឥន្ទ្រីយ សោះព្រួយចិត្តប្អូនស្រី នាងកណ្តែនក្បែកតែបង ៗ ប្អូននៅឯង

ឯណាយ ឲ្យសប្បាយចិត្តទៅហោង កុំមាសមេតិតបង បងមិនបានមកវិញ
ឡើយ ៗ ទៅណា នាងប្អូនណា បងនឹងលាប្អូនទៅហើយ ក្សណនោះព្រះ
ត្រាណត្រើយ ស្តេចដោះឡើងយានយាត្រា ៗ ឯនាងនាថនិមិល នាង
ទូលយល់ព្រះពជា ស្តេចចាកនាងណា នាងចាប់ដាយព្រះពស្ត្រថ្ងៃ ៗ
វិឯព្រះរាជា ធ្វៀងនត្រានទំពែ ទូលយល់នាងប្អូនថ្ងៃ ចាប់ព្រះពស្ត្រព្រះ
ពជា ៗ ក្សណស្តេចថ្ងៃដាក្នារ់ ប្រែព្រះភក្ត្រមកម្ចាស់ ទូលយល់នាង
ធីតា ចាប់ព្រះពស្ត្រដ៏ះក្ខារកោង ៗ ទើបស្តេចបន្ទូលថា ហៃប្អូនក្ខា
មាសស្នេហ៍ស្នង ប្អូនវិនប្អូនស្ងួបបង នាងបណ្តោញឲ្យបងទៅ ៗ ឥឡូវ
នេះតើមាន បើខុសខានពាក្យអ្វីទៅ កាលបងលាប្អូនទៅ កំស្ងួនស្មៀម
ពុំស្រដី ៗ ឥឡូវស្រាប់តែមក កើបអួសយកសំពត់ពី បង្កើះបងវិញវិ
នាងអាសូរបងសិនក៏ ៗ សំពត់នេះថ្លៃខ្ពស់ ដែលព្រះហស្តព្រះមាតា អ្នក
ត្បាញឲ្យបងណា កុំឲ្យបាត់ណានាងអើយ ៗ នាងស្តាប់ព្រះពជា វាជាយា
ឥតបម្លើយ នាងខ្ទាសព្រះត្រាណត្រើយ ថ្វាយបង្គំព្រះរាជា ៗ ក្សណនោះ
ព្រះភូមី យល់ប្អូនស្រីវេទ្នា ស្តេចគង់ចុះម្ចាស់ ប៉ថ្នាក់ថ្នមព្រះប្អូនស្រី ៗ
ដាក់លើទកកែន ពីអន្ទ្យត្រមៈមត្រី ទើបនាងនាថទេវី បង្គំទូលព្រះ
រាជា ៗ បពិត្រស្ងួមព្រះអង្គ បន្ទាប់លែងគ្រាណា អាសូរខ្ញុំប្អូនជា
ខ្ញុំបាទព្រះបាទបង ៗ ក្សត្រីនូវក្សត្រា ស្និទ្ធស្នេហាឥតឯហ្ង ពីរ
ពន្យព្រះអង្គហោង រួមបន្ទំសុខសួស្តី ៗ ស្តេចលោមវាជាយោ

រាជធីតាអគ្គមហេសី ប្អូនអើយបងមកឥ- ឡូវនេះយូរណាស់ហើយណា ៗ
បងចង់បបួលទៅ ក្រឡាប់ទៅផ្ទាំងកាក ស្រុកបងឯណាយណា ចូរប្អូនទៅ
ទៅនឹងបង ៗ នាងស្ដាប់ព្រះឧត្ដារ ទើបនាងនាថទូលវិងស្នង បពិត្រខ្ញុំ
នេះហោង មានព្រះអង្គជាអម្ចាស់ ៗ តែមោះព្រះបិតា ខ្ញុំមាតាមានគុណ
ណាស់ សោកសង់ដកពោស់ តាមតែទ្រង់ព្រះករុណា ៗ ស្ដេចស្ដាប់
នាងនាថទូល ព្រះអស្សូវរជាយា ក្សត្រខ្ញូវក្សត្រា ជ្រុំក្រសាល
ព្រះហឫទ័យ ៗ លុះមាន់រងាវណា ស្ដេចលោមលាព្រះប្អូនថ្លៃ មាស
អើយឥឡូវនៃ ហៀបនឹងព្រឹកហើយណាទៅ ៗ ឧប្អូនមាសស្នេហា ឥ.
ឡូវណាចូរនាងទៅ បងនឹងលាប្អូនទៅ ហើយបងនឹងវិលវិញណា ៗ
សម្ដេចព្រះភូមិ ជួមប្អូនស្រីរតនំពុំងា មហេសីស្មតិសោភា ស្ដេចដាក់
លើទកតែន់ ៗ ស្ដេចថើបព្រះក្រា ព្រះកជាផ្ដុំតាំងគ ស្រេចហើយ
ស្ដេចឡើងបិត លើហង្សយន្ត គិចហៀវហោះ ៗ លុះដល់ដើមព្រឹក្ស
ព្រះកជាចង់យន្តនោះ ហើយព្រះចៅចុះ លីលាទៅនានាព្រាហ្មណ៍ណា ៗ
ព្រាហ្មណ៍យល់ព្រះភូមិ ព្រាហ្មណ៍ព្រឹទ្ធសោមនស្ស ស្រឡាញ់ព្រះកជា
ស្មើគលកូនបង្កើតនៃ ៗ ហើយស្ដេចតែងទៀងទៅ គាល់ព្រះចៅចម
ក្សត្រថ្លៃ ប្រក្រតីសព្វ ១ ថ្ងៃ ពុំដែលដាច់ខានមួយណា ៗ លុះជួប
ចូលកាត្រី ព្រះភូមិទៅនិទ្រា នឹងនាងនាថជាយា ជាប្រក្រតីដូច្នោះ
ហោង ៗ ស្ដេចនៅលង់ទៅណា នាងធីតាទ្រង់គភ៌ផង ទសមាសា

ហើយហោង នឹងប្រសូតរាជបុត្រា ។ ពុំលង់ឡើយជ្រាបទៅ ដល់ព្រះចៅព្រះបិតា ក្សណៈនោះព្រះរាជា ឲ្យអញ្ជើញបុត្ររត្ន ។ ទើបនាងនាថនារី ចុះចាកពីប្រាសាទថ្កាត់ ទៅគាល់ពីរពង្សក្សត្រ ព្រះបិតានូវមាតា ។ ឯព្រះបិតាគន់ យល់សុដង់នាងខ្មៅណា ស្ដេចជ្រាបជឿជាក់ជា រាជ-បុត្រីនាងទ្រង់គភ៌ ។ ស្ដេចក្រោធក្រៃក្រាក់ក្រ ហើយចំអត់ផ្ទៃក្រសាលមាក់ហើយជាពុំខ្វល់ ស្ដេចពុំឲ្យនាងដឹងឡើយ ។ ក្សណៈនោះនាងទេវីលាជនទីជនកហើយ ទើបនាងនាថត្រាណត្រើយ វិលទៅឋានប្រាសាទណា ។

បធាំផោល

កាលនោះព្រះចៅបញ្ចាល៍ ជ្រាបឆ្លើយណា ស្ដេចខ្វល់ពន្ទឹកតោកក្រៃ ។ ហាក់ដូចអគ្គិវិស័យ ឆេះក្នុងព្រះទ័យ រន្ធត់ចំប្រប់អង្គា ។ ទើបទ្រង់ព្រះចិន្តាថា កូនអញនេះណា អង្គឹទងអ្នកដទៃ ។ សម្ទនិកូនព្រាហ្មណ៍នោះនៃ មានរូបប្រពៃ ប្រសើរលើសលែងអ្នកផង ។ បើឈ្មោះគួរអញនឹងល្បង យកចំណោះលង ល្អងតាប់ឡបាទហោងណា ។ ទើបស្ដេចយកគ្រឿងអាលា ចូងបន្ទូលក្រស្នា ហើយលាយនឹងជាតិហាគ្គុល ។ មានសេពីដោរសោតសល់ ពុំវាំងមណ្ឌល កំល្មោងក្រអូបល្មួងល្មើយ ។ ដាក់ក្នុងប្រអប់មាសហើយ ទើបក្សត្រត្រាណត្រើយ ត្រាស់ប្រើសាវ៉ៃជម្ងួយណា ។ យកទៅថ្វាយរាជធីតា សៅវ៉ៃជម្ងួម៉ា ទទួលប្រអប់មាសរៃ ។ យកពីព្រះហស្ត

ក្សត្រថៃ ស្រាប់ស្រេចហើយនៃ សារដែលបង្គំក្រាបលា ។ ទៅទូល វិរាជធីតា សារថៃទូលថា បពិត្រព្រះរាជក្សត្រី ។ សម្តេចព្រះវិរជធនី ស្តេចស្តេចជាត សួរប្រើខ្ញុំមកនេះណា ។ ឲ្យយកគ្រឿងព្រះមាលា ប្រសើរថ្លៃថ្លា មកថ្វាយព្រះអង្គឯងនៃ ។ ព្រះរាជបុត្រីតេជថៃ នាង ស្តាប់សារថៃ ស្រេចនាងទទួលយកហោង ។ សារថៃក្រាបលាវិលផង ថ្កានព្រះបង្គំប្រសប់ប្បន ដំណាព្រះវរបិតា ។ បពិត្រសម្តេចរាជា វិរាជធីតា កំថ្វាយបង្គំវន្ទិយ ។ មកព្រះនរនាថនរបតី ស្តេចស្តេចជាត សួរអស់ តាំងពីក្រស្តេចផងណា ។ ស្តេចស្តាប់សារថៃទូលថា ហើយព្រះរាជា ស្តេចត្រេកអរសោមនស្សក្រៃ ។

វិកាលកត្រីនោះនៃ ព្រះបាទជៀសជ័យ ស្តេចទឹកដល់វេលាយា ។ ស្រេចទើបព្រះបាទក្សត្រា ស្តេចលីលា ព្រះបាទក្សត្រថៃដើរទៅ ។ ដល់ដើមឈើធំទីក្បែរនៅ ទើបព្រះចមទៅ ស្តេចឡើងដល់ហន្សយន្ត ណា ។ ស្រេចហើយព្រះបាទក្សត្រា ស្រាយយន្តមន្តា ស្តេចគង់ ហន្សយន្តហោះដល់ ។ ប្រាសាទប្រសើរសួស្តីសល់ ហើយព្រះទស ពល ស្តេចចុះពីហន្សយន្តណា ។ ទើបស្តេចយាងយាសយាត្រា ចូល ទៅដល់នាក្រឡាបន្ទំក្សត្រី ។ ក្បែណានោះព្រះរាជទេវី វិរកែនមហេសី នាងយកគ្រឿងព្រះមាលា ។ លាយលាបឲ្យព្រះរាជា វិរាជធីតា ពុំដឹងជាគេឲ្យកល ។ ស្រេចស្តេចផ្ទុំលក់សួស្តីសល់ ទឹងហៀបលុះដល់ ទៅមានអាការហើយណា ។ ស្រេចទើបព្រះបាទក្សត្រា ផ្តែផ្តាំជាយា

ប្អូនអើយទឹងព្រឹកហើយហោង ៗ បងទឹងលីលាទៅផ្គួង ចាំយប់ឯង
ហោង បងមកកាន់ព្រះប្អូនស្រី ស្ដេចលោមនាងអគ្គមហេសី ស្រេច
ព្រះចក្រី ស្ដេចថ្នមព្រះប្អូនស្នេហា ៗ ថើបថៃអស់ព្រះអង្គា ស្រេច
ស្ដេចលីលា ដើរចេញមកដល់យន្ដហោង ៗ ស្រាប់ស្រេចស្ដែង
ស្ដេចឡើងគង់ លើហង្សហោះផ្សង ក៏លុះដល់ដើមព្រឹក្សា ៗ ស្ដេច
ចងហង្សយន្ដមីមា ហើយមហាក្សត្រា· ធាកជះស្ដេចមកដល់ហោង ៗ
ស្ដែងស្ដេចបត្រាចវ៉ឹងផ្គួង ត្រាចដោយគន្ទង ទៅដល់ផ្ទះព្រាហ្មណ៍
ព្រឹទ្ធិ ៗ ព្រះអង្គយកព្រះពស្ដ្រថ្មី មកទទូរពើ ព្រះសិរ្សដល់ព្រះបាទា ៗ
ហើយផ្ទៃតែឯកអង្គា លក់សូន្យក្ដាត់ណា លុះព្រះអាទិត្យឧទ័យ ៗ
រះតិបុភ្ញាប្រពៃ រឿងរះខ្ពស់ក្រៃ ព្រះអង្គពុំភ្ញាក់ឡើយណា ៗ ក្សណា
នោះព្រះចៅបញ្ចាល តើនបាកទិត្រា ស្ដេចចេញពីកដរេងរតន៍ ៗ
មន្ត្រីគង់គាល់ច្រើនក្ដាត់ ទើបព្រះមហាក្សត្រ ត្រាស់ប្រើអាមាត្យមួយ
ណា ៗ ទៅហៅកូនព្រាហ្មណ៍ហោព ក្សណនោះអមច្ចា ក្រាបលា
សម្ដេចជៀសជ័យ ៗ ខ្មីឃ្មាតសង្វាតវ៉ៃ រត់ធាប់ៗក្រៃ ទៅដល់
ផ្ទះព្រាហ្មណ៍ហោក ៗ ថ្លែងពីព្រះរាជអាជ្ញា ព្រាហ្មណ៍ប្រាជ្ញគិតថា
កូនអញនេះតើធ្វើអ្វី ៗ ឲ្យហៅយល់អគ្គិក្ដិ ទើបព្រាហ្មណ៍ព្រឹទ្ធិ
ចរចូលទៅជាសំបុត្រា ៗ ព្រះអង្គតើនបាកទិត្រា ព្រាហ្មណ៍យល់អង្គា ដ៏
ប្រាលរន្ទាលធ្ងួនផ្អៅ ៗ ទើបព្រាហ្មណ៍ឲ្យព្រះចមចៅ ស្ដេចលីលា

ទៅ ស្រះស្រង់ជីវៈគាត្មា ។ ព្រះអង្គស្រង់ព្រះគង្គា ដុសសព្វកាយា
ស្រេចបរិបូណ៌ហើយនៃ ។ នៅខាងព្រះកាមាថ្ងៃ សម្តេចជៀស្នជ័យ
ស្តេចដុសពុំសព្វឡើយណា ។ ទើបស្តេចទ្រង់ព្រះពស្ត្រា ស្រេចស្រាប់
មីម្មា រលះរលាំងទៅថ្កាត់ ។ លុះដល់មណ្ឌលពេទរត់ម ថ្វាយ
បង្គំក្សត្រ ព្រះចៅបញ្ចាលន់របតី ។ ទើបស្តេចត្រាស់ប្រើមន្ត្រី មើល
សព្វឥន្ទ្រិយ ក្រែងមានដិតជាតិហិង្គុល ។ អាមាត្យមើលព្រះទសពល
គន់សព្វក្សិណយល់ បន្តិចខាងព្រះកាមា ។ អាមាត្យក្រាបទូលរាជា
សម្តេចចេស្តា ជ្រាបដាក់ដូរច្នោះហើយនៃ ។ ស្តេចទ្រង់ក្រោធពន់ពេក
ក្រៃ បន្ទូលថាហៃ ពេជ្ឈឃាដទាំងអស់គ្នា ។ គ្នាយើងរួសផាប់មីម្មា
ទោមពេមចាប់វា កំណាចនេះចងឲ្យខ្ជាប់ ។ ហើយនាំទៅពិឃាត
ផាប់ យកវាសម្លាប់ ឥឡូវកុំយូរឡើយណា ។ ពេជ្ឈឃាដក៏
សោតមីម្មា ទោមចាប់រាជា បានហើយរុំចងខ្ជាប់ក្រៃ ។ ស្រេចហើយ
នាំចេញរ៉ៃ ។ ខ្ពោះសំដៅព្រៃ ប៉ុនប៉ងពិឃាដប្រុកជ ។ រីឯសម្តេច
ពន្យុត ទង្គរបរិសុទ្ធ បានលុះនៃដៃពេជ្ឈឃាដ ។ ស្តេចសែនសោយ
សោកសង្វេគ អាណិតអនាថ តែព្រះអង្គឯងឯកា ។

បទកាកគតិ

កាលនោះពោធិ - សត្វសាងបារមី វិវត្តមោ ទៀងទល់ទុក្ខា
ឯកានាថា ទុពិលឯកោ ថ្លែនថ្លីងពុំបាន ។ ព្រះទស្សថ្លាថ្លែង ទ្រង់ព្រះ

កន្សែង ពិលាបប្រះប្រាណ ជាឱអញអើយ ម៉្លេះហើយពុំបាន វិល
វិលទៅឋាន មាតាបិតា ៗ ឱអ្នកមានគុណ គុណគាប់មហាធ្ងន់
ធ្ងន់ពេកក្តាត់ណា ម៉្លេះសមកូនក្ស័យ ជីវិតជន្មា ឯកអង្គឯងអា. សោក
សោះសូន្យសល់ ៗ កូនមកស្រុកឆ្ងាយ ពោលអ្នកជាម្តាយ កំព្រា
ទុំពិល មកស្លាប់អសារ ឥតការឥតកល នៅនាមណ្ឌល ដែនដីស្រុក
ឆ្ងាយ ៗ ឱអញអភ័ព្វ ម្តេចក៏មកស្លាប់ ស្លាប់បង់អ្នកម្តាយ បង់
អ្នកឪពុក បង់ស្រុកឯទាយ ដៀតចិត្តពាយមាយ ស្រើបដោយតណ្ហា ៗ
មកស្នេហ៍ប្រពន្ធ បង់អ្នកមានគុណ ចាំងពីអង្គា មកដល់នគរ បវរ
បញ្ចាល់ បានបុត្រក្សត្រា ជាគូសម្ពន្ធ ៗ ឱទ្រូងអញអើយ ឥឡូវម្តេច
ឡើយ មុខនឹងខ្ទុកធ្ងន់ តែគួរតោកយ៉ាក លំបាកពេកពន់ តែធ្វើទីន
បុណ្យ អំណាចណាស់នៃ ៗ ឱអ្នកម្តាយផ្តាំ នោះមិញកូនចាំ ជា
អចិន្ត្រៃយ៍ ឥឡូវនេះណា វេរពៀរភ័យ មកដល់នាថ្ងៃ នេះឯងហោង
ណា ៗ សមអ្នកចាំងពីរ តែនឹងខតមើល មើលផ្លូវបុត្រា គិត
ស្មានកូនប្រុស រូបសស់សុខស- ប្បាយបានល័ណ ក្រឡាប់វិល
ទៅ ៗ មិនដឹងជាកូន ក្សិណក្ស័យសោះសូន្យ ប្រាសព្រះចមចៅ
ម៉្លេះព្រះមាតា បិតាអ្នកនៅ សង្រេងក្តាត់ទៅ ទន្ទឹងបុត្របាត់ ៗ ឱ-
អនិច្ចា ខ្លួនអើយកំព្រា ត្រមោចប្រាសព្រាត់ មកស្លាប់អសារ កណ្តាល
ព្រៃស្ងាត់ ស្លាប់ម្តេចដូចសត្វ ដោយដីចេ្ចះណា ៗ បើម៉្លូវទីនស្លាប់ ឡ្យ

មានតំនាប់ នៅស្រុកតិចណា ព្រះជនកព្រដេនទី ក្សត្រក្សត្រា ប្រជាប់ប្រជា លើកសពក្សត្រថៃ ។ ដល្បរកូនស្លាប់ ឯកអង្គអគ័ត្តកណ្ដាលទ្រូងព្រៃ កូនយកប្រឹថពី ដែនដីនេះនៃ ជាមឈូសមាសមៃនិទ្រាទៅហោង ។ កូនយកអាកាស ជាពិតានមាស ថ្លៃថ្លៃកន្ទង់លើកសពអាត្មា កាលគ្រានេះមួង តាមវេការង បៀសពុំបានណា ។ កូននឹងយកព្រះ សុរិយោរៃនរ ពីបូពិទិសា អាស្រ័យរស្មី ជាភ្លឺរន្ទាលើកសពសង្ការ កូនកាលនេះមួង ។ កូនយកប្រឹក្សា ជាកំនីននណាបិទបាំងប្រពៃ កូនយកសព្វសត្វ ស្រង៉ាត់កូនព្រៃ កូននឹងអាស្រ័យទុកជាភ្ញៀវផង ។ ជាតួរ្យតន្ត្រី ប្រគំប្រក្រតី លើកសពកូនហោងតាមកម្មវេរា កាលគ្រានេះមួង កូវកូននឹងរង តាមវិបាកបាន ។ ទតអ្នកណា នឹងអាចយាត្រា វិលវឹងទៅប្កាន ទូលព្រះបិតា មាតាឲ្យបាន ជ្រាបថាកូនមាន ទុក្ខទោសដល់ស្លាប់ ។ បានអ្នកទឹងមកប្រយោជន៍ទន្ទូវក រៀបចំប្រដាប់ លើកសពកូនជា បុត្រាធាប់ៗ បរិបូណ៌ដោយច្បាប់ ដូចអស់ក្សត្រផង ។ ទអម្ចាស់ថៃ ចាប់ដើមពីថៃ នេះឯងហើយហោង ពុំបានយល់កូន សោះសូន្យនេះមួង សមអ្នកនឹងរង ទុក្ខទោមនស្ស ។ សម្ដេចភូមី ថ្លៃថ្លៃនឹងឲ្យញាតិ មាតាបិតា ការណិកអនេក ពន់ពេកណាស់ណា ហើយព្រះរាជា ឲ្យញទៅប្អូនស្រី ។ ទនាងបទុម កេសរឧត្តម វរាជក្សត្រី ម៉ែសមបងបង

ប្អូនសង្វាតេ ថ្ងៃនេះឯងឥឡូវណាប្អូនអើយ ។ ឱមាសស្នេហ៍ស្និទ្ធ
បងបានដូចចិត្ត ចិត្តចិន្តាហើយ លើកអ្វីប្រែប្រាស ប្អូនមាសត្រាណ-
ត្រើយ ព្រលឹងបងអើយ បងប្រណីណា ។ ឱប្អូនបណ្តាច់
បណ្តូលស្នួតសាច់ សាច់សង្វាត ស្រឹតទៃតែមួយ ជាត្រួយទយា បង
ចង់យកជា អយិអគ្គមហេសី ។ ម្តេចឡើយមកប្រាស ព្រាត់ព្រលឹង
មាស នាគ្រានេះវិញ ហេតុបាបបងឯង ពីព្រេងជាតិ តាមទាន់ឯងឥ-
ឡូវនេះហោងណា ។ អញថាក្សិណក្ស័យ ជីវិតប្រល័យ ប្រាសព្រះ
ប្អូនភ្ញា ឱអាសូរពៅ នាងទៅកំព្រា សមនាងទងជា មេម៉ាយឯង-
ហោង ។ បងមហាប្រណី អាសូរប្អូនស្រី មាសមិត្តឥតធ្ងន់ សមពៅ
សោយសោក អមោក្ស្តាតហោង ចាំតែឈ្មោះបង ខ្លួនមិញមិន
យល់ ។ ឱយើងទាំងពីរ ធ្លាប់នៃងប៉ិតថេរ មូលមួយមណ្ឌល ស្រ-
ឡាញស្នេហ៍ស្និទ្ធ អប់ចិត្តអស់គល បាបអ្វីមកផ្តល់ ឲ្យបងបង់មេ ។
ឱអគ្គប្អូនមាស ថ្ងៃបងនឹងប្រាស លែងបានផ្តាំផ្ដែ ប្រាសម្តេចសោះសូន្យ
បងប្អូនមាសស្នេហ៍ ពុំបានផ្តាំមេ មកមរណ៍អសារ ។ បងគិតទៅគ្រប់
គ្រប់ហើយនៃងថប់ ថប់ប៉ប្រការ ថប់មួយផ្សិតប្រាស ប្អូនមាសត្រកាល
អាសូរអសារ នៅឯងកំព្រា ។ បងថប់មួយគ្តី គិតព្រះជនទី ជនកជក
ចាស់ហើយនៃងប្រាស ទិពសុបុត្រា សមអ្នកទងជា ទុក្ខឯងធ្ងន់ក្រៃ ។ ថប់
មួយសោតហោង ឯកឯងអគ្គបង នេះណាទងក្ស័យ ជីវិតប្រែប្រាស ប្អូន

មាសថ្លើមថ្លៃ ប្រាកដនាថ្ងៃ នេះឯងហោងណា ៗ ស្តេចទ្រង់ព្រះក- ន្សែង
សោកស្រើតន់ វរាជជាយា អាណិតអនាថ សល់ខ្ទាតសោកា
ដោរដេលនេត្រា ពុំស្បើយឡើយហោង ៗ ក្សណានោះក្សត្រី វរាជ-
ទេវី អនុជស្នេហ៍ស្ងួន នាងពុទ្ធបិតា ក្រោធាកន្ទួន ព្រះអង្គខ្ញាល់ផង
ព្រះវៀមរាជា ៗ ព្រះអង្គឲ្យចាប់ យកទៅសម្លាប់ បំបាត់ជន្មា នាងពុ
ស្វាមី ត្រូវក្តីហើយណា នាងសោយសោកា ពន់ពិលាបលន់ ៗ
នាងយកព្រះករ តាំងពីរនាងគរ ទុកស្រើតន់ ហាក់ទឹងក្សណក្ស័យ
ប្រល័យជីវជន្ម នាងទ្រង់ព្រះក- ន្សែងសោកទូញថា ៗ ឱអម្ចាស់ថ្លៃ
បើព្រះអង្គក្ស័យ ខ្ញុំសូមមរណា ស្លាប់ផងជៀសជ័យ នាថ្ងៃនេះណា
ព្រមព្រះរាជា ស្មឹងកជីវី ៗ នាងទូញបណ្តើរ ស្រើតន់ប្រូសើរ លី-
លាចុះពី ប្រាសាទមកទល់ មណ្ឌលដេទី ទើបនាងទេវី ទូលព្រះមាតា ៗ
បពិត្រព្រះម៉េ ជាមកុដសិរ គុណាតម្កើក សូមទានព្រះអង្គ ស្តេច
ទ្រង់ករុណា អាសូរខ្ញុំជា កូនកាលនេះមួង ៗ តឡូវកូនសូន មាន
ទុក្ខកងខ្លួន ជូនក្រៃកន្ទួន ដៀតព្រះបិតា ក្រោធាខ្ញាល់ផង ប្តីខ្ញុំឯងហោង
ពន្ទឹកយមហិមា ៗ សូមអ្នកម៉ែទៅ ក្រាបទូលព្រះចៅ ព្រះវរបិតា ទូល
សូមជីវិត ស្វាមីខ្ញុំណា កុំឲ្យរាជា ពិឃាដបង់បាត់ ៗ ដៀតបុត្រព្រះបឹង
ចាំខ្ញុំមកទឹង ប្រុសមានរូបរតន៍ បើព្រះបិតា ក្រោធាពេកក្តាត មិនអា-
សូរសោក ដល់តិចឡើយណា ៗ សូមឲ្យខ្ញុំក្ស័យ ជីវិតប្រល័យ មូលមួយ

ផងគ្នា សឹមទៅយកប្តី ស្វាមីស្នេហា រួមឋានទៅនា ស្រុកខ្មោចនោះ
នៃ ៗ ព្រះមាតាស្តាប់ បុត្រទូលប្រាប់ ជ្រាបព្រះហឫទ័យ អាសូរ
កដបុត្រ ប្រាកដពេកក្រៃ បន្ទូលថាហៃ កូនស្ងួនពុំគាំ ៗ កុំទល់ទុក
ទៀត ព្រលឹងម្តាយអើយ ម្តាយនឹងទៅណា ទៅទូលអង្វរ ព្រះវរបិតា
ឲ្យនាងកាលគ្រា នេះឯងកូនអើយ ៗ ទើបនាងនាថទៅ ទូលលាសព្រះ
ចៅ ពិតពុំលង់ឡើយ បពិត្រព្រះមហា ក្សត្រាត្រាណត្រើយ សូមស្តេច
លំហើយ លះបង់ក្រោធា ៗ អាសូរកូនស្ងួន ពន្លកខ្ញុំខ្លួន ផង្សែ-
នេះក៏ បានជាអាល័យ នឹងក្សែយផងគ្នា សូមស្តេចករុណា អត់ទោស
ទៅហោង ៗ មិនតែកូនយើង នេះនឹងបើង ក្រៅច្បាប់គន្លង និយាយ
ចុពណ សឹងមានបេះហោង សូមទានកុំបង ព្រះទ័យក្រោធា ៗ
ក្សិណៈនោះភូមី ស្តាប់ពជទេវី ទូលដូច្នោះណា ស្តេចទ្រង់ព្រះក្រោធ
ពេកពេកមហិមា បន្ទូលត្រាស់ថា មឹងកុំធ្វើច្នេះ ៗ កូនកាចកាចខ្មាស
ឲ្យអាស្រូវកាស មុខគញ់គាំងម៉្លេះ ជ្រិតគំនិតហោង សមផងរាំនេះ
រឹបខ្សៀវបញ្ចោះ លុកលទៅមក ៗ បើរាំចង់ស្លាប់ អញនេះសំាតពុំ
រាប់ ទុកស្មើឈាមកក បង់មៀតដោយដី កុំបីមឹងមក ស្រដីរៈ-
រក អង្វរអញឡើយ ៗ ឯព្រះមាតា ស្តាប់ព្រះពជា បន្ទូលច្នោះ
ហើយ នាងខ្លាចភូមី ឥតបីហានធ្លើយ សាសង់ទៀតហើយ
នាងនាថក្រាបលា ។ មកដល់បុត្រី ទើបនាងជននី ទូនទូលបុត្រ

ក្វា ទ្រង់ព្រះកន្សែង ថាថ្លែងប្រាប់ថា នាងអើយបិតា ក្រោធពន់ពេក ក្រៃ ៗ ជេរដាលដល់ម្តាយ ខ្វាល់ណាស់នាងអាយ ក្រោធក្រៅវិស័យ កំម្តាយក៏គគ្វាច ព្រះពជហ្ឫទ័យ ដូចកូនមាសម៉ៃ ដឹងហើយណា នាង ៗ នាងនាថទេវី ស្តាប់ព្រះជននី ប្រាប់ដូច្នោះណា នាងយកព្រះករ គកគរទុក សែនសោយសោកា ពន់ពិលាបលន់ ៗ នាងទូលមាតា ខ្ញុំសូមក្រាបលា អ្នកមានគុណធ្ងន់ ដ្បិតខ្ញុំទឹងក្សយ ប្រល័យជីពជន្ម ថ្ងៃនេះឯងអ-ន្តរធាន តាមប្តី ៗ ព្រះវរមាតា ស្តាប់បុត្រទូលលា ទឹងថយទៅខ្វ នាងឱបកូន រតន៍ លេះមយាត់បុត្រី នាងអើយកុំបី កូនគិតដូច្នោះណា ៗ ម្តាយសោក ចាស់ហើយ ព្រលឹងម្តាយអើយ ម្តាយមាននាងជា កូនស្រីតែមួយ ជា ត្រួយទយា ខ្មោចម្តាយនេះណា ផ្ញើលើនាងហោង ៗ ពីរពន្សត្រី សែន សោយសោកពិ- លាបលន់កន្ទុង សឹងសន្ធប់លង់ ពីរពន្សជាម្តង ហេតុដ្បិត តែរង ទុក្ខទៀងសោកសោះ ៗ នេះទឹងស្រដី ដំណើរអំពី អស់ពង្ស- ឃាដនោះ នាំព្រះអង្គដល់ មណ្ឌលព្រៃស្នោះ ដោយចិត្តបំពោះ បង់ទឹង ពិឃា[illegible] ៗ កាលនោះពោធិ- សត្វសាងបារមី ប្រសើរសល់ខ្នាត គាវទាព្រះ ធម៌ សម្មាជាអាទិ៍ សម្តេចនរនាថ ពុំកួចធមថ្ងៃ ៗ ទើបស្តេចត្រាស់ថា ហៃតាអស់ទាំងគ្នា បងប្អូននេះនៃ សំណឹកអាត្មា អញណាទឹងក្សយ ប្រាកដនាថ្ងៃ នេះឯងហោងណា ៗ អញមានទ្រព្យថ្ងៃ មួយមានដំរៃ ប្រពៃមហិមា រូបពជហង្សមាស ធ្នះធ្លាសថ្ងៃថ្លា អញទុកនៅនា ចុង

ឈើមួយហោង ៗ អញនឹងឲ្យជា ស្ពានអស់គ្នា កាលគ្រានេះមួង បើគ្នា
ស្រឡាញ់ នាំអញទៅផង ដល់ឈើហើយហោង អ្នកឡើងយកណា ៗ
អស់ពេជ្ឈឃាដស្តាប់ ព្រះអង្គថ្លែងប្រាប់ គេគអរណាស់ណា គ្រប់គ្នាក៏ទៅ
សំដៅព្រឹក្ស ទើបព្រះកុមារ ទ្រង់នាំទៅដល់ ៗ ក្រោមដើមព្រឹក្ស ទើប
ព្រះកុមារ បង្ហាញឲ្យយល់ រូបហង្សមាសមៃ ថ្វៃសួស្តីសល់ នៅ
នាមណ្ឌល ចមចុងព្រឹក្ស ៗ ឯអស់ពេជ្ឈឃាដ យល់ហង្សមាសស្អាត
គ្រេកអរមេបាមា ដណ្តើមគ្នាពាន ចង់បានសុវណ្ណ គ្នាខ្វះស្រែកថា
ឲ្យអញឯងពាន ៗ ខ្វះសោតថាទៅ ចំណោះអ៊ូអា ហៅនឹងឡើងបាន ឈើ
សោតធំលន់ ខ្ពស់ពន់ប្រមាណ អត់ឲ្យអញពាន ម្នាក់ៗក្សៀណក៏ ៗ
គ្នាខ្វះពានឡើង គ្នាខ្វះចាប់ជើង កើចចុះវិញណា ដណ្តើមគ្នាឯង កោង
ក្រងិកាគ្នា របូតហត្ថា ធ្លាក់ចុះដល់ដី ៗ យើងយល់គ្នាធ្លាក់ ស្ទុះទៅ
កន្ត្រាក់ ដៃដោះឡើងវិញ មិនឈប់មើលអញ ឡើងវិញខ្លាចអ្វី យក
ឲ្យបានឥ ឲ្យរនេះហោងណា ៗ ក្សៀណស្ទុះទៅពាន ប៉ុនប៉ងឲ្យបាន
ដូចចិត្តចិន្តា ធ្វើហាក់ឯងស្អាត ក្សៀណក្តាត់បាត របូតហត្ថា ធ្លាក់
ចុះវិញហោង ៗ ឯពេជ្ឈឃាដណា ចំឡើងព្រឹក្ស ច្រើនគ្រាច្រើនជង
ពុំបានដូចចិត្ត គំនិតប៉ុនប៉ង សោយដៃហោង ឈរមើលទេណា ៗ
គេជះបារមី សម្តេចជិនស្រី សពេជ្ញសាស្តា ពុំឲ្យពេជ្ឈឃាដ នេសាទនោះពាំ

ឡើងដើមព្រឹក្សា រួចផល់មួយនៃ ៗ ក្សណនោះព្រះបាទ សម្តេចនរទេថ
ធិរាជរៀស្ដជ័យ ទ្រង់ព្រះចិន្តា ប្រាជ្ញាទិព្វថ្វៃ បន្ទូលថាហៃ បងប្អូន
តាំងឡាយ ៗ ចូរបបួលគ្នា ហោមដើមព្រឹក្សា ស្រេចហើយគ្នាស្រាយ
អញចឹងឡើងយក ចុះមកតាំងរាយ ឲ្យអ្នកតាំងឡាយ ជារង្វាន់
ណា ៗ ពេជ្ឈឃាដស្ដែងស្ដាប់ ស្ដេចបន្ទូលប្រាប់ ក្រេកអរគ្រប់គ្នា
មកស្រាយពោធិ៍- សត្វវិសេសា ប្រាកដហើយណា ហោមជុំវិញ
ហោង ៗ កាលនោះពោធិ៍- សត្វរួចអំពី បរិបូណ៌ឥតគ្គង ស្រេច
ហើយក្សត្រថ្វៃ ប្រពៃប្រាស់ប្បង ឡើងឈើដូចបង ពុំលង់ឡើយ
ណា ៗ សម្តេចទសពល ស្ដេចឡើងទៅដល់ លុះលើរុក្ខា ខ្ពស់
ពន់ពេកក្រៃ ក្សត្រថ្វៃធ្វើជា ភិតភ័យមហិមា ស្ទើរឡើងពុំបាន ៗ
ឯអស់ពេជ្ឈឃាដ យល់យល់ព្រះបាទ គក់ទ្រូងគក់ប្រាណ គ្នាខ្លះ
ស្រែកថា គាហោរសាមាន្យ បើឡើងពុំបាន ចុះមកវិញណា ៗ ទើប
ព្រះអង្គឆ្លើយ ថាអស់គ្នាហើយ កុំគិតអញា សំណើកឧង់ក្សយ នា
ថ្ងៃនោះណា កុំបីអស់គ្នា គិតអញឡើយហោង ៗ វែលងកែអញ
បាន រូបហង្សមាសមាន ដំឡៃក្នុង ឲ្យជារង្វាន់ គ្រប់គ្រាន់អស់
បង ប្អូនតាំងនេះហោង ដូចចិត្តប្រាថ្នា ៗ ស្ដេចឡើងទៅដល់ ហង្ស
យន្តទិមល ហើយទ្រង់ចិន្តា អញបង់ទម្លាក់ មាសប្រាក់ឲ្យវា គិតដួង
កុំត្រា ផលគិតឡើយនៃ ៗ (នៅមានត)

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

## ទំនៀមកាន់ទុក្ខសពនៃសាមញ្ញជនជាតិខ្មែរ

លោក ប៊ូ–ប៊ុ រៀបរៀង

សំនួរ– គួរឲ្យឆ្ងល់ថា នៅវេលាមានបុណ្យសពនៃសាមញ្ញជនទីមួយៗ គេតែងឃើញក្រុមគ្រួសាររបស់សព អ្នកខ្លះកោរសក់, អ្នកខ្លះមិនកោរសក់, អ្នកខ្លះស្លៀកពាក់សំពត់អាវស, អ្នកខ្លះស្លៀកពាក់សំពត់អាវខ្មៅ ឬក៏គ្រាន់តែយកកំណាត់សំពត់ខ្មៅមួយបន្ទះតូចខ្ទាស់ភ្ជាប់នឹងអាវក៏មាន, ការដែលគេធ្វើយ៉ាងនេះ តើជាខុសឬត្រូវ, ហើយគេប្រកាន់យកអ្វីជាគោលការណ៍ ?

ចម្លើយ – សូមដោះស្រាយប្រស្នានេះថា បណ្ដាជនជាតិខ្មែរនៅស្រុកស្រែចម្ការ ច្រើនតែកោរសក់ ហើយស្លៀកពាក់សំពត់អាវសកាន់ទុក្ខសព តាមទម្លាប់ដែលចាស់ទុំធ្លាប់ធ្វើតៗគ្នា តាំងពីព្រេងនាយ ជាប់ជាទំនៀមរៀងរហូតមកដល់សម័យនេះ ។

តាមយោបល់នៃលោកអ្នកប្រាជ្ញជាតិខ្មែរខ្លះយល់ថា ការដែលបណ្ដាជនជាតិខ្មែរកោរសក់ ហើយស្លៀកពាក់សំពត់អាវសកាន់ទុក្ខសពនោះ ដោយប្រកាន់តាមក្បួនច្បាប់ក្នុងព្រះពុទ្ធសាសនាជាគោល ដូចជាការកោរសក់ជាប្រស្នាសម្រាប់ពិចារណាឲ្យឃើញថា សក់ដែលកោរ

អស់ហើយ តែនៅតែដុះឡើងវិញជាមិនខាន ប្រៀបធៀបនឹងមនុស្សស្លាប់ទៅហើយ ទៀនតែកើតឡើងទៀត ហើយសោយសុខទុក្ខទៅតាមផលបុណ្យ-បាបរបស់ខ្លួន ។

ចំណែកសំពត់ការមានពណ៌ផ្សេងៗជាច្រើន ប៉ុន្តែ ពណ៌ស ជាពណ៌អាចផ្លាស់ប្តូរប្រែប្រួលទៅជាពណ៌អ្វីៗ ដទៃទៀតបាន គឺថាបើប៉ះពាល់ប្រឡាក់នឹងវត្ថុមិនស្អាតណាមួយ មានជ្រលជាដើម តែងក្លាយទៅជាសំពត់ក្រខ្វក់អាក្រក់ដោយជ្រលប្រឡាក់ មិនទៅជាពណ៌ស ស្អាតតាមភាពដើមទេ ។ ពណ៌សនេះ ទុកជាប្រស្នាមួយ សម្រាប់ឲ្យគិតពិចារ-ណាប្រៀបធៀបទៅនឹងរូបមនុស្ស ដែលតែងផ្លាស់ប្តូរប្រែប្រួលពីក្មេងទៅជាចាស់, ពីជាទៅជាឈឺ, ពីរស់ទៅជាស្លាប់ ។

ពួកអ្នកពុទ្ធសាសនិកយល់ឃើញថា សំពត់ពណ៌សមានប្រយោជន៍ដ៏សំខាន់យ៉ាងនេះហើយ បានជាគេនិយមស្លៀកពាក់សំពត់ការសកាន់ទុក្ខសព ។

ម្យ៉ាងវិញទៀត ការប្រើសំពត់ស ជាការចាំបាច់ក្នុងពិធីបុណ្យដារណាធម៌ សឹងមានអត្ថាធិប្បាយក្នុងគម្ពីរពុទ្ធសាសនាថា:

«កាលព្រះបរមសាស្តានៅយ៉េនគង់ព្រះជន្មនៅឡើយ, មានព្រះថេរៈមួយរូបព្រះនាមចូឡបន្ថកៈ ចូលទៅគាល់ព្រះសាស្តាក្រាបថ្វាយបង្គំលាសឹក, ព្រះពុទ្ធអង្គទ្រង់ប្រោសប្រទានកំណាត់សំពត់សមួយផ្ទាំងតូច ឲ្យ

យកទៅអង្គុយឈរកណ្ដាលវាលហាលថ្ងៃ ហើយឲ្យសំឡឹងមើលសំពត់ស ដែលខ្លួនឈរទីនឹងឲ្យទន្ទេញថា " សំពត់សនេះមិនស្អាតទេ, សំពត់នេះមិនស្អាតទេ" ។

ព្រះថេរៈ ទទួលព្រះពុទ្ធដីកា យកសំពត់សពីព្រះហស្ដ ចេញទៅរានក្រៅអង្គុយកណ្ដាលវាលហាលថ្ងៃ ដៃឈរសំពត់ស ក្អែកសំឡឹងសំពត់ស មាត់ទន្ទេញរឿយៗថា "សំពត់សនេះមិនស្អាតទេ, សំពត់សនេះមិនស្អាតទេ" មិនយូរប៉ុន្មាន សំពត់សដែលលោកឈរនោះ ប្រឡាក់ញើសក្អែលដៃទៅជារបស់ខ្មៅក្រខ្វក់ លែងសស្អាតដូចពីដើម ។ ព្រះថេរៈឃើញដូច្នោះ ក៏កើតព្រះទ័យសង្វេគតក់ស្លុតពិចារណាឃើញធម៌ថា "វត្ថុទាំងអស់ជារបស់មិនទៀងទាត់ទេ, ជារបស់នាំឲ្យកើតទុក្ខទោស, មិនមែនជារបស់ខ្លួនសោះឡើយ" នៅទីបំផុតនៃការពិចារណាធម៌ ព្រះថេរៈបានសម្រេចព្រះអរហត្តផលនៅពេលនោះឯង ។

អាស្រ័យរឿងព្រះចូឡបន្ថកថេរនេះជាគោលការណ៍ បានជាបណ្ដាជនជាតិខ្មែរអ្នកកាន់ធម៌ក្បាសីលក្ដី អ្នកកាន់ទុក្ខសពក្ដី ច្រើនតែស្លៀកពាក់សំពត់សរសេ នឹងច្រើនតែកោរសក់ផង ។

សូម្បីក្នុងច្បាប់ព្រះរាជពង្សាវតារក្រុងកម្ពុជា ក៏ឃើញមានសេចក្ដីប្រកាសឲ្យប្រជាពលរដ្ឋខ្មែរគ្រប់គ្នាកោរសក់, ស្លៀកពាក់សំពត់សរសេ កាន់ទុក្ខព្រះបរមសពនៃព្រះមហាក្សត្ររបស់ខ្លួនដែរ ។

ប៉ុន្តែ សព្វថ្ងៃនេះ ឃើញមានបណ្ដាជនជាតិខ្មែរខ្លះ ស្លៀកពាក់សំពត់អាវខ្មៅ ឬក៏គ្រាន់តែខ្ទាស់បន្ទះសំពត់ខ្មៅបន្តិចភ្ជាប់នៅអាវស ជាគ្រឿងសំគាល់ថា ខ្លួនកាន់ទុក្ខសព ។ ការដែលធ្វើយ៉ាងនេះ មិនមែនធ្វើតាមទំនៀមទម្លាប់របស់ជាតិខ្មែរពីបុរាណកាលមកទេ គឺគេធ្វើតាមពួកអឺរ៉ុបដែលចូលមកនៅក្នុងប្រទេសខ្មែរ ។

នៅទីបំផុតនេះ សូមដោះស្រាយបញ្ហាប្រស្នាខាងដើមនេះថា អ្នកកាន់ទុក្ខសព ទោះកោរសក់ក្ដី មិនកោរសក់ក្ដី ស្លៀកពាក់សក្ដី ខ្មៅក្ដី ឬពណ៌អ្វីឯទៀតក្ដី ទឹងអារកាត់ថា អ្នកណាធ្វើខុស អ្នកណាធ្វើត្រូវ ក៏មិនបាន ព្រោះព្រះពុទ្ធអង្គមិនបានបញ្ញត្តិពីរឿងកាន់ទុក្ខសពនេះទេ ស្រេចតែគេធ្វើតាមទំនៀមទម្លាប់របស់ជាតិគេ វៀរលែងតែមានព្រះរាជប្រកាសជាការចាំបាច់ ខានមិនបាន ។

បរិយាយអំពីរបៀបកាន់ទុក្ខសពនៃប្រជារាស្ត្រខ្មែរ ចប់តែប៉ុណ្ណេះ ។

## កណ្ឌទី ៣៦

ឧកញ៉ាវិបុលរាជសេនា ង៉ូ-ហ៊ាង ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកភាងវៃឆ្លាស បើបានអាន
នឹងចេះឧបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ស្រូតទៅចាំចំឡងទាំងអស់គ្នា លុះអ្នកស្រុកឆ្លងអស់ហើយ ឡៅពីក៏នាំទាំងស្រី ទាំងប្រុស ចាស់ក្មេង លើកទៅដល់ស្រុកសុងយ៉ុង ទឹងចូលទៅក្នុងស្រុកក៏មិនបាន ឡៅពីក៏ជិះសេះតម្រង់ទៅតាមជើងកំពែង ហើយស្រែកហៅឡៅចង់ថា ក្មួយអើយអ្នកកុំមានសេចក្ដីសង្ស័យ យើងលើកមកនេះមិនមែននឹងធ្វើប្រទូសរ៉ាយអ្នកទេ យើងមកដោយសេចក្ដីអាណិតអាសូរអ្នកស្រុកទាំងអស់គ្នា ចូរក្មួយបើកទ្វារឲ្យយើងចូលទៅចុះ ។ ឯឈួមឹងទៀអ៊ុង ឃើញឡៅពីតាំងរ៉ាំងមកស្រែកហៅឲ្យបើកទ្វារដូច្នោះ ក៏ឡើងទៅលើសើន ឲ្យទាហានបាញ់ធ្នូចម្រុះចេញមក ។

ខណៈនោះ អ៊ុយអៀនជាពួកស្រុកងីយ៉ុង ខ្ពស់៦ហត្ថ មុខក្រហម

ពណ៌ដូចផ្លែពុទ្រាទុំ នៅក្នុងស្រុកនោះ លុះឃើញឈ្មោះទឹងទៀវអ៊ុនធ្វើដូច្នោះ ក៏លើកពួកម៉ាកប្រហែល១០០នាក់ទៅត្រង់ទ្វារស្រុក ស្រែកដេរឈ្មោះទឹងទៀវអ៊ុនថា ឯងនេះជាសត្រូវលក់ម្ចាស់ មកធ្វើដូច្នេះ គួរហើយឬ ? ។ ឡៅពីនេះ ជាមនុស្សចិត្តល្អទឹងការណាប្រុងជាទុក្ខរាស្ត្រទាំងពួងណាស់ ដែលលើកមកនេះ ព្រោះសង្គ្រោះដោះទុក្ខរាស្ត្រ មួយទៀតបិតាអ្នកស្លាប់ក៏បានផ្តាំផ្ញើកិច្ចការស៊ុំទុក្ខនឹងឡៅពី ហេតុម្តេចឯងមិនឲ្យឡៅពីចូលមក ថាដូច្នោះហើយ ក៏យកដាវដេញកាប់ពាហានដែលនៅរក្សាទ្វារស្លាប់ខ្ចាត់ខ្ចាយអស់ទៅ ទើបប្រាប់បើកទ្វារស្រុកចេញទៅទទួលឡៅពី ស្រែកថា អញ្ជើញលោកនាំបណ្តាអ្នកស្រុកទាំងអស់គ្នាចូលមកចុះ ចូរជួយកំចាត់សត្រូវលក់ម្ចាស់ចេញ ។

ឡៅពីឮដូច្នោះ ក៏អរណាស់ ទើបនាំពាហានទឹងបណ្តាអ្នកស្រុកចូលទៅ ទទួលជួបនឹងប៊ុនផេង លើកពាហានមក ឃើញអ៊ុយអៀនបើកទ្វារទទួលឡៅពីដូច្នោះ ក៏ស្រែកដេរថា ឯងគ្រាន់តែជាកូនពាហានគ្មាននរណារាប់អានសោះ ហេតុម្តេច ក៏មកបើកទ្វារទទួលឡៅពីឲ្យចូលមកដូច្នេះ ឯងនឹងចង់ឲ្យស្រុកនេះកើតចលាចលឬ ? ។ អ៊ុយអៀនឮប៊ុនផេងដេរប្រមាថដូច្នោះ ក៏ខឹងណាស់ បរសេះចូលទៅកយុទ្ធគ្នានឹងប៊ុនផេង ជាពន្លឹក ពាហានទាំងសងខាងក៏ចូលតដៃគ្នាជាជ្រួលច្របល់វឹកវរទៀង ។

ឡៅតីឃើញដូច្នោះក៏ថា យើងមកគ្រានេះតាំងចិត្តនឹងអនុគ្រោះបណ្ដារាស្ត្រទាំងពួងឲ្យបានសេចក្ដីសុខព្រមមូលគ្នា យើងមិនទាន់នឹងចូលទៅដល់ស្រុក ម្ដេចក៏មកបណ្ដាលទាស់ទែងគ្នាច្បាំងកាប់សម្លាប់កែរដូច្នេះ ត្រឡប់ឲ្យបណ្ដារាស្ត្រក្នុងស្រុកទាំងខាងក្រៅក្ដៅក្រហាយទៅវិញ បើយើងចូលទៅហើយនឹងមិនកើតកែរជាងនេះទៅទៀតឬ ? ដែលយើងតាំងចិត្តជួយឲ្យជាប្រយោជន៍នោះ ក៏នឹងអសារឥតការទទេទៅ ដូចយើងចូលទៅធ្វើឲ្យបណ្ដារាស្ត្រ បានទុក្ខក្ដៅឡើងទៀត យើងក៏មិនចូលទៅឡើយ ។ ខុងបេង ថា: បើដូច្នោះស្រុកកាំងឡេងក៏ជាទីដែនចំណុះស្រុកគេងជីវដែរ សុំឲ្យលោកលើកពលទៅស្រុកនោះចុះ ដើម្បីនឹងបានការរក្សាខ្លួនដោយស្រួល ។ ឡៅតីយល់ឃើញត្រូវ ក៏នាំទាហាននិងបណ្ដារាស្ត្រទាំងនោះ លើកទៅស្រុកកាំងឡេង ។

ឯពួកអ្នកស្រុក ស៊ុងយ៉ុង ឃើញកើតចលាចលកែរដូច្នោះ ក៏នាំគ្នាលើកគ្រប់គ្រួតាមឡៅតីទៅជាច្រើនណាស់ ។ អ៊ុយអៀន នឹងប៊ុនផេង ច្បាំងគ្នាតាំងពីព្រឹកដល់ថ្ងៃត្រង់ ទាហានទាំងសងខាង របួសពិការស្លាប់ជាច្រើន អ៊ុយអៀន តស៊ូនឹងកម្លាំងប៊ុនផេងមិនបាន ក៏ញាក់សេះវេះរត់ចេញទៅក្រៅស្រុក នឹងទៅរកឡៅតីមិនប្រទះ ក៏រត់ប្រះទៅនៅនឹងហាន់ហៀន ចៅហ្វាយស្រុកទៀងសា ។ ឯឡៅតីលើកគ្រប់គ្រួដែលប្រមូលទៅគ្រានោះ មនុស្សប្រហែល ៥ ម៉ឺន លុះទៅដល់ ។ ម្ពុងឡៅប៉ៀវ

កំឡុងឈប់ទ័ពសំរាក  ទៀវពីក៏ចុះពីលើសេះចូលទៅគំនាប់សពទៀវប៉ឿវ ហើយយំសោកថា  លោកជាបងបានផ្តាំផ្តុកនឹងខ្ញុំពីដើម  ឲ្យខ្ញុំទំនុកបំរុងកូនចៅ  ខ្ញុំក៏នៅចាំពាក្យលោកទាំងអស់  តែឥឡូវនេះ ខ្ញុំក៏ធ្វើមិនរហូត  ទោសក៏មានដល់ខ្ញុំច្រើនណាស់  សូមឲ្យលោកអត់ឱនទូវទោសនោះដល់ខ្ញុំផងចុះ  បើដូចលោកបានសង្គ្រោះដោះទុក្ខ  អាណាប្រជានុរាស្ត្រទាំងពួង  ជួយឃុំគ្រងរក្សាឲ្យបានសេចក្តីសុខទៅ ។

កាលទៀវពីចូលទៅគំនាប់សពយំសោកអាឡោះអាល័យទៀវប៉ឿវដូច្នោះ មានបំរើសេះមកប្រាប់ថា ឥឡូវចូចូលើកកងទ័ពកន្ទួនចូលមកដល់ស្រុកអ៊ួនសៀហើយកំពុងចាត់ចែងទូកនឹងធ្ងន់តាមមកទៀត ។ ពាហានទាំងពួងឮដូច្នោះ ក៏នាំគ្នាទៅជំរាបទៀវពីថា លោកនឹងមកប្រកួតប្រកាន់កំណាន់ចិត្តគិតដល់គ្រប់គ្រួទាំងអស់នេះ  មិនបង់លើកទៅឲ្យឆាប់ ដើរទៅ ១ ថ្ងៃត្រុយ ១ ដូច្នេះឃើញថា រត់មិនផុតទេ  បើចូចូតាមមកទាន់ នឹងមិនបង់ការថុសចោលទៅទេឬ? សូមឲ្យលោកនាំពលគ្រប់គ្រួទាំងនេះទៅចុះ ខំស្រូតក្រូតទៅខាងមុខឲ្យដល់ស្រុកកាំងឡេងសិន  ព្រោះស្រុកកាំងឡេងជាទីសំខាន់នឹងការពារគេស៊ូនឹងចូចូបាន ។  ទៀវពីយំបណ្តើរនិយាយបណ្តើរថា ប្រវេណីអ្នកមានប្រាជ្ញាប្រាជ្ញានឹងគិតធ្វើការធំម៉ាមួននោះ រមែងទំនុកតាំងចិត្តគ្រប់គ្រងការពារអាណាប្រជានុរាស្ត្រ  ឲ្យមានសេចក្តីមេត្រីស្រឡាញ់ ឲ្យអស់អញ្ចលំគេញអាត្មា  គំនិតនោះជាឫសគល់  ទើបមិនសំរេចផល

ប្រយោជន៍បាន ឥឡូវបណ្ដាកស្រ្តទាំងអស់នេះ មានចិត្តអាណិតយើង ស៊ូជិតដោយតាមជេយ មកដោយលំបាកជាទីបំផុត យើងនឹងដោះរត់ យកតែខ្លួនទៅមុន ចោលឲ្យនៅកំព្រាទូកកូវទន់ ក៏ជាការមិនគួរសមសោះ ។ បណ្ដាកស្រ្តទាំងអស់ ឮឡៅពីនិយាយដូច្នោះ ក៏យំសោកទាំងអស់គ្នា រឹតតែមានចិត្តស្នេហាស្រឡាញ់ឡៅពីជាច្រើនណាស់ ។

---

## សាមកុកខ្សែ ៣៧

---

តាំងពីខុងបេង, ឡៅពី ប្រើគួនអ៊ូទៅសុំទ័ពឡៅគីមកជួយ ចូចូលើកចូលទៅស្រុកសុងៈប៊ុងបញ្ឆោតសម្លាប់ឡៅបងនិងម្ដាយស្លាប់ ហើយលើកតាម ឡៅពី, ខុងបេងចុះទូកទៅនៅបន្ទាយហៃទៅ ។

---

ខុងបេងនិយាយនឹងឡៅពីថា ឥឡូវចូចូលើកទ័ពជាប់តាមមក ជិតដល់ហើយ សុំលោកប្រើគួនអ៊ូស្រូតទៅប្រាប់ឡៅគីឯស្រុកកាំងហែ ឲ្យលើកទ័ពទូកមកជួយបញ្ចូលគ្នានឹងកងទ័ពស្រុកកាំងឡេង ។ ឡៅពីក៏យល់ឃើញត្រូវ ទើបប្រើគួនអ៊ូនឹងស៊ុនខៀនកាន់សំបុត្រទៅ ឲ្យឡៅគីលើកកងទ័ពទូកមកជួយ ហើយឲ្យជូឡុងនាំគ្រប់គ្រួទាំងពួង ឲ្យទៀវហ៊ុយនាំទាហានលើកទៅជាកងទ័ពក្រោយសម្រាប់ការពារ ឡៅពីក៏ដើរកៀរប្រមូលគ្រប់គ្រួទៅតាមផ្លូវ ១ ថ្ងៃបាន ១០០សិន ( ៤ គ.ម.) ។

ឯបូចូកាលលើកទ័ពទៅដល់ស្រុកអ៊ីនសៀហើយ ក៏ស្រុកត្រូនាំតា-ហានតាំងពួងជូនទៅស្រុកសុនយ៉ុង លុះទៅដល់ហើយ ក៏ឲ្យបំរើទៅហៅឡៀបចងឲ្យចេញមក ។ ឈូម៉ីទឹងទៀះអ៊ីន ក៏និយាយនឹងឡៀបចងថា មហាឧបកដលើកមកដល់ស្រុកហើយ ឲ្យបំរើមកហៅលោកចេញទៅគំនាប់ ក៏ត្រូវនឹងចេញទៅគំនាប់តាមទម្លាប់ប្រវេណី ។ អនអ៊ុយទីប្រឹក្សាចូលទៅខ្សឹបប្រាប់ឡៀបចងថា ពីដើមលោកនឹងទៅចំណុះចុះចូលបូចូក៏ពិតមែនឥឡូវឡើងពីរត់ពីបូចូទៅមិនបានគស្ទូទេ ឃើញថាបូចូគ្រានេះ មានចិត្តក្រើសក្រួនអង់អាចណាស់ មិនបានខាត់ថែងនឹងរក្សាខ្លួនឲ្យមាំមួនដូចពីដើមទេ មុខជាធ្វេសប្រហែសណាស់ហើយ នាចិតណ្ដាមនុស្សតាំងពួងក៏នឹងដឹងព្រាកដ ថាលោកមានដម្រេះប្រាជ្ញាចេះរិះគិតរកកែកោតខ្លាចដែលនឹងគិតការធំៗទៅទៀត ក៏គង់នឹងមានអំណាចសម្រេចតាមប្រាថ្នា ។ ឡៀបចងក៏យកសំដីដែលអនអ៊ុយនិយាយនោះទៅប្រាប់ឈូម៉ី ។

ឈូម៉ីពូជូនោះ ក៏ឲ្យហៅអនអ៊ុយចូលទៅហើយនិយាយថា ខ្លួនឯងនេះ មិនបានដឹងច្បាស់លក្ខណៈផែនដីដែលនឹងវិនាសនឹងចំរើន ហេតុម្ដេចឯងព្រហើនអាចហានចរចាដូច្នេះ ។ អនអ៊ុយបានឮឈូម៉ីនិយាយដូច្នោះទឹងណាស់ ឆ្លើយថា អាសត្រូវលក់ម្ចាស់ កាលណាអញនឹងបានស៊ីសាច់អាឯងទើបអញអស់ទឹង ។ ឈូម៉ីពូជូនោះ ក៏បង្គាប់ពាហានឲ្យចាប់អនអ៊ុយយកទៅសម្លាប់ ។ កេងអ៊ួតក៏ឃាត់ហាមសូមទោស

អង់អ៊ុយ ។ ឈួម៉ក៏នាំទៀវអ៊ុនចេញទៅគំនាប់ចូចូដល់ក្បែរប្រាំងស៊ីនទីងធុង ។ ចូចូសួរថា ក្នុងទីដែនដែលឡើងស្រុកកេងជីវនេះ មានស្បៀងអាហារទឹកស្រូវចំណុះស្រុកទាំងអស់ប៉ុន្មាន? ។ ឈួម៉ឆ្លើយថា មានទាហានសេះ៥ម៉ឺន, ទាហានថ្មើរជើង ១៥ ម៉ឺន, ទាហានទូក ៨ ម៉ឺន; រួមផ្សំគ្នាត្រូវជា ២៨ ម៉ឺន, ឯស្បៀងអាហារនោះបានប្រមូលទុកដាក់ក្នុងស្រុកកាំងឡេងជាច្រើន បើប្រមូលផ្សំគ្នាគ្រប់ខែត្រទាំងអស់ទីងស៊ុបានប្រហែល ១ ឆ្នាំ ។

ចូចូសួរថា ទូកចម្បាំងមានចំនួនប៉ុន្មាន ? នរណាជាអ្នកបង្គាប់បញ្ជាត្រួតត្រា? ។ ឈួម៉ឆ្លើយថា ទូកចម្បាំងទាំងធំទាំងតូចមាន ៧ ពាន់ប្លាយ នៅក្នុងបង្គាប់បញ្ជាខ្ញុំបាទ ២ នាក់នេះទាំងអស់ ។ ចូចូឮដូច្នោះត្រេកអរណាស់ ទើបតាំងឲ្យឈួម៉នឹងទៀវអ៊ុនជានាយកងទ័ពជើងទឹក ហើយថាឥឡូវនេះ ឡៅប៉ៀវក៏ស្លាប់បាត់ហើយ ឯឡៅចងជាកូន ក៏មកចំណុះចុះចូលយើងៗ នឹងក្រាបទូលព្រះចៅហៀនតេ ឲ្យតាំងជានាម៉ឺនធំ សម្រេចការពារក្នុងស្រុកកេងជីវតទៅ ។ ឈួម៉, ទៀវអ៊ុន បានស្តាប់ដូច្នោះ ក៏មានចិត្តបីតិប្រាមោជ្ជត្រេកអរណាស់ គំនាប់លាចូចូមកវិញ ។

ស៊ុនហ៊ុវជំរាបចូចូថា ឈួម៉ នឹងទៀវអ៊ុន២នាក់នេះ ជាមនុស្សប្រចុបប្រចែងឡែបឡប ហេតុម្តេចលោកមិនស្គាល់ចិត្តគំនិត ក៏តែងតាំងឲ្យ

ធ្វើជានាយទាហានដឹងទឹកតែម្ដងនោះម្ដេចទៅ ! ។ ចូចូអស់សំណើច ហើយថា បើយើងមិនដឹងមិនស្គាល់ចិត្តមនុស្សទេ នឹងធ្វើការធំម្ដេចបាន ប្រការ១ទៀត ទាហានរបស់យើងពុំនប្រសប់តែផ្លូវគោក ដែលនឹងរកឲ្យស្ទាត់ជំនាញខាងដើរទឹកនោះមិនមាន យើងធ្វើតាំងម្សិលនេះ ប្រាថ្នានឹងយកចិត្តទុកដាក់ហ្វឹកហាត់ទាហានយើងឲ្យប្រសប់ រួចសឹមកំចាត់វាចេញទៅចុងដៃ នឹងក្រោយអ៊ូ ។

ឯឈួមី នឹងទៀវអ៊ុន ក៏នាំយកសេចក្ដីទៅសំដែងប្រាប់ឡៅចង់ តាមពាក្យចូចូសព្វគ្រប់ប្រការ ។ ឡៅចង់ឮហើយមានអំណរណាស់ នាំយកសេចក្ដីនោះទៅសំដែងប្រាប់នាងឈួហ៊ូយិនជាម្ដាយ លុះវេលាព្រឹក ក៏រៀបតាក់តែងរបស់ទ្រព្យដែលនឹងនាំទៅគំនាប់ចូចូ ، លុះរៀបចំស្រេចហើយ ឡៅចង់ និងនាងឈួហ៊ូយិន ក៏នាំចូលទៅគំនាប់ចូចូ, យកត្រាសម្រាប់ការជូនទៅផង រួចក៏លើករបស់នឹងត្រានោះជូនទៅចូចូ ។ ត្រេកអរណាស់ ក៏លើកកងទ័ពទៅតាំងនៅប្របស្រុកសុងយ៉ុង ។

ឯឈួម៉ , ទៀវអ៊ុន ក៏អុជធូបទៀនគំនាប់ចូចូ អញ្ជើញឲ្យចូចូចូលទៅក្នុងស្រុក ។ ចូចូឲ្យរកហៅកេងអ្អួតមកហើយ ក៏និយាយថា ខ្ញុំយើងមកយកស្រុកកេងជីវគ្រានេះ មិនមែននឹងមានអំណរប៉ុន្មានទេ ដែលយើងបានខ្លួនអ្នកតែមួយក៏មានចិត្តត្រេកអរ លើសជាងបានស្រុកកេងជីវទាំងមូលទៅទៀត ហើយក៏តាំងកេងអ្អួតជាចៅហ្វាយស្រុក

កាំងឡេង តាំងហ៊ូស្នួន , អង់សាន់ជាមន្ត្រីធំ តាំងឡៅចង់ជាចៅហ្វាយស្រុកកេងជីវ ហើយក៏ឲ្យរៀបខ្លួនចេញទៅ ។

ឡៅចង់ឮដូច្នោះ ក៏សុតសុងកង៉ចិត្ត ទើបអង្វរសុំខ្លួនថា ដែលមហាខបកដតាំងឲ្យខ្ញុំបាទជាចៅហ្វាយស្រុកកេងជីវនោះ ជាព្រះគុណធ្ងន់គ្មានទីបំផុត ដែលខ្ញុំបាទខំប្រញាប់ចេញមកគំនាប់លោកទាំងម្ទេះ មិនមែនទទឹងមានសេចក្តីប្រាថ្នាចង់ធ្វើចៅហ្វាយស្រុកនោះណាស់ណាទេ ខ្ញុំបាទសុំឲ្យបានតែវាក្រស្តីពាសនៅក្នុងស្រុកកេងជីវនេះ ដើម្បីនឹងបានថែរក្សាសពបិតាប៉ុណ្ណោះ ក្រៅពីនោះប្រាថ្នានឹងរកស្រាកញ្ញាភិសារលោកិកតាមប្រពៃណីតទៅ សូមលោកអាណិតករុណាដល់ខ្ញុំបាទចុះ ។ ប៉ូងថា ដែលយើងនឹងឲ្យអ្នកទៅនៅស្រុកកេងជីវនោះ ដោយសេចក្តីប្រណីអាណិតអ្នក ព្រោះយើញថាស្រុកកេងជីវនឹងក្រុងហ៊ូតោទៅជិតគ្នា អ្នកនឹងបានចូលចេញគាល់ហ្មៅព្រះចៅហៀនតេដោយស្រួល , ប្រការ១ទៀត បើអ្នកនឹងចង់នៅក្នុងស្រុកកេងជីវនេះ ឆ្ងាយពីយើងនឹងព្រះចៅហៀនតេ គង់ជាទីបៀតបៀននៃមនុស្សដែលជាសត្រូវទាំងពួង នឹងមិនសប្បាយទៅចុងដៃ ។ ឡៅចង់ឮហើយ ក៏គាល់គំនិតព្រោះគិតខ្លាចប៉ូង នឹងរើងទទឹងមិនបានក៏ព្រមទទួល ហើយគំនាប់លាទាំងមាតាចេញទៅស្រុកកេងជីវ លុះទៅដល់មាត់កំពង់នឹងធ្ងន់ស៊ូង នាម៉ឺនទាំងអស់ក៏លាចូលទៅតាន់វិកនៃខ្លួនរៀងខ្លួន ។ ឯម៉ង់អ៊ុយក៏ជាប់តាមឡៅចង់ទៅផង ។

កាលដែលឡៅចង់ចេញផុតពីស្រុកនោះហើយ, ចូចូក៏បង្គាប់អ៊ុគីមថា អ្នកចូរលើកទាហានស្រួតតាមទៅស្កាត់ចាប់សម្លាប់ឡៅចង់ចេញ ៗ អ៊ុគីមក៏លើកទាហានស្រួតតាមទៅ លុះទៅទាន់ឡៅចង់ហើយ ក៏ស្រែកថា ឥឡូវមហាឧបរាជប្រើឲ្យយើង តាមមកសម្លាប់អ្នកឯង ព្រមទាំងម្ដាយទាំង ២ នាក់ចេញ អ្នកកុំរើរត់ទៅឯណាឡើយ ចូរនៅស្ងៀមឲ្យយើងកាត់ក្បាលនាំទៅឲ្យមហាឧបរាជចុះ ៗ នាងឈួហ៊ូយិនឮដូច្នោះក៏តក់ស្លុតស្មារតី ម្ដាយនឹងកូនក៏ឱបគ្នាទួញយំដំនុក ៗ អង់អ៊ុយឃើញដូច្នោះខឹងណាស់ ត្រឡប់មុខវិលមកទង់តស៊ូ ៗ អ៊ុគីមឲ្យទាហានចាប់សម្លាប់ចេញ ហើយក៏កាត់ក្បាលនាងឈួហ៊ូយិននឹងឡៅចង់ត្រឡប់នាំទៅឲ្យចូចូ ៗ ក៏ឲ្យបំណាច់រង្វាន់អ៊ុគីមតាមសមគួរ ហើយបង្គាប់ទាហានឲ្យទៅចាប់គ្រប់គ្រួខុងបេងមិនឃើញសោះ ហើយក៏វិលមកប្រាប់ចូចូវិញ ៗ ចូចូក៏មានកំហឹងគុំគួនមិនរសាយ ៗ ខណៈកាលខុងបេងនឹងលើកព្យុហៈទ័ពចេញពីស្រុកស៊ុនអៀនោះ ក៏ទុកខ្លាចក្រែងចូចូនឹងធ្វើអន្តរាយដល់គ្រប់គ្រួ ក៏គេបបួលទៅនាំគ្រប់គ្រួយកទៅលាក់បំពួននៅដំបន់សាំងតាំង បានជាទាហានស្រាវជ្រាវរកមិនជួបប្រទះ ៗ

ចំណែកស៊ុនហ៊ីវជំរាបចូចូថា ស្រុកកាំងឡេងនោះ ជាទីមាំមួនណាស់ ទាំងស្បៀងអាហារក៏ប្រមូលយកទៅទុកជាច្រើន បើប្រសិនឡៅពីទៅតាំងនៅមុនបាន យើងនឹងតាមទៅធ្វើការច្បាំងដណ្ដើមក៏មិនងាយ

ទីងយកជ័យជំនះបានសោះ ។ ចូចូតបថា អ្នកនិយាយនោះត្រូវហើយ យើងភ្លេចទេ យើងក៏នៅគិតឃើញដកប តែឥឡូវយើងត្រូវឲ្យទាហានប្រុតរួតលើងទៅមុខ ចូបេយកស្រុកកាំងឡេងឲ្យបានមុន, ចូចូក៏ឲ្យអញ្ជើញពលទាហានរបស់ឡៅចងមកត្រួតមើល ឃើញបាត់ម្នាក់ឈ្មោះប៊ុនផេង, ចូចូក៏ឲ្យមនុស្សទៅហៅយកខ្លួន ទទួលជួបប្រទះទីងប៊ុនផេងក៏នាំចូលមកគំនាប់ចូចូ ។ សួរថា តាំងពីយើងមកនៅក្នុងស្រុកស៊ុងយ៉ុងនេះច្រើនពេល ហេតុម្តេចក៏ខ្លួនទៅពួនមុខមិនមករកជួបទីងយើង? ។ ប៊ុនផេងឆ្លើយថា ខ្ញុំបាទមិនបានមករកលោកនោះ មិនមែនទីងពួនមុខលាក់ខ្លួនទេ ព្រោះខ្ញុំបាទកើតមកជាទាហាន មិនបានធ្វើការយកអាសាចៅហ្វាយនាយឲ្យស្រុកភូមិនៅជាសុខ បានជាខ្ញុំបាទកើតទុក្ខអៀនខ្មាសណាស់ ទើបមិនបានមករកលោក និយាយហើយក៏យំ ។ ចូចូឃើញដូច្នោះ ក៏ពេញចិត្តណាស់ សំឡឹងមើលឃើញថា ជាមនុស្សសុចរិតទៀងត្រង់មែន ទើបតាំងឲ្យប៊ុនផេងជាចៅហ្វាយស្រុកកាំងហែ ហើយឲ្យលើកទាហានដែលមានកម្លាំងខ្លាំងពូកែបាន៥ពាន់ស្រួតទៅតាមឡៅពី, ចូចូក៏លើកទ័ពហ្លួងជាជំនួយតាមទៅក្រោយ ។

ឯខុងបេងនិយាយនឹងឡៅពីថា បណ្តាគ្រប់គ្រួដែលមកតាំងអម្បាលនេះ មានចំនួនដល់ ៣ ម៉ឺន ៤ ម៉ឺន មានទាហានចំបាំងប្រហែលតែ ៣ ពាន់តិចពេកណាស់ ហើយខ្លួនលោកក៏ដើរកៀរប្រមូលគ្រប់គ្រួយឺតតាំងម្ទះ កងទ័ពចូចូក៏លើកជាប់តាមមកខ្លាំង ៗ ជិតទាន់ហើយ កាលដែល

លោកប្រើគួនអ៊ូ ទៅសុំកងទ័ពពីស្រុកកាំងហែមកជួយ តាំងពីថ្ងៃទៅកប់មកដល់ថ្ងៃនេះ កំណត់ ១ ខែហើយ នឹងបានមិនបាន ក៏មិនឃើញវិលមកវិញ មិនដឹងជាកាចជាយ៉ាងណាឡើយ នឹងគិតដូចម្តេច ? ។ ឡៅពីថា បើដូច្នោះលោកកុំឃើញតែនឿយហត់ឡើយ ចូរសម្រាកទៅខ្លួនឯងបន្តិចចុះ ព្រោះលោកមានគុណូបការៈ នឹងឡៅពីពីថ្ងៃមុន ឡៅពីឃើញលោកទៅខ្លួនឯងហើយ ក៏នឹងបោះបង់ពុំបាន គង់នឹងកេណ្ឌពលទាហានឲ្យលោកខ្លះ ។ ខុងយ៉ុងទទួលពាក្យហើយក៏ចេញទៅ នាំឡៅហង់ទៅផងជា ២ នាយលើកទាហាន ៥០០ ស្រូតទៅស្រុកកាំងហែ ។

កាលឡៅពីនឹងប៊ីតុក ប៊ីហង់ កានយ៉ុង នាំគ្រប់គ្រួលើកប្រពាក់ប្រ-ពូនទៅក្នុងថ្ងៃនោះ ក៏កើតខ្យល់ព្យុះកំបុតត្បូងបោកបក់កួចយកផ្ទាំងរូលីហុយត្រឡប់ទៀត ទៅត្រង់មុខសេះ ឡៅពី ។ ស្ទុះគិត ក៏សួរប៊ីតុក ប៊ីហង់ កានយ៉ុងថា ហេតុនេះនឹងល្អឬអាក្រក់ឬការម្តេច ? ។ កានយ៉ុងចាប់យាមមើល ហើយជំរាបឡៅពីថា ហេតុនេះកាចណាស់ ពេលយប់នេះភ័យនឹងមកដល់លោកជាប្រាកដហើយសុំឲ្យលោកបោលគ្រប់គ្រួចេញសិន ស្រូតរត់ទៅមុនឲ្យរួចខ្លួនសិនចុះ ។ ឡៅពីថា បងកំឡាំងដែលយើងបានការពារក្រុមមនុស្សទាំងអស់នេះមកពីស្រុកស៊ិនអៀ រហូតដល់ទីនេះហើយដែលនឹងបោះបង់បោលគ្នារត់យកតែខ្លួននោះ យើងមិនដឹងនឹងធ្វើកើតសោះឡើយ ។ កានយ៉ុងថា បើលោកនៅតែមិនជឿស្តាប់ពាក្យខ្ញុំបាទ

(នៅមានត)

## ផ្នែកកំណាត់ដឹងប្រវត្តិការណ៍

ពតិមានផ្សេងៗរបស់ក្រសួងធម្មការ

# អំពីការតាំងមន្ត្រីសង្ឃទីរាជាគណៈពីររូប ខាងគណៈធម្មយុត្ត តាមព្រះរាជក្រិត្យលេខ ២៨ វ.រ.ចុះថ្ងៃទី៦ មិថុនា ១៩៥៩

---

១-ព្រះអរិយកស្សប កែវ.អ៊ុច ជន្មាយុ៧១ឆ្នាំ វស្សា៥០ រាជាគណៈសម្រាប់ទោ នៅវត្តបទុមវតី ក្រុងភ្នំពេញ ជាទីរាជាគណៈសម្រាប់ឯក មានគោរម្យងារជា " ព្រះមង្គលទេពាចារ្យ " ជំនួសសម្ដេចព្រះមង្គលទេពាចារ្យ កែប-ភួន ដែលទទួលអនិច្ចធម្ម ។

២- ព្រះមហាវិរិយាចារ្យ ហ៊ី-ជា ជន្មាយុ៥៤ឆ្នាំ វស្សា៣១ រាជាគណៈសម្រាប់ត្រី នៅវត្តបទុមវតី ក្រុងភ្នំពេញ ជាទីរាជាគណៈសម្រាប់ទោ មានគោរម្យងារជា "ព្រះធម្មឧត្តម" ជំនួសព្រះធម្មឧត្តម ឡុង-សន ដែលទទួលអនិច្ចធម្ម ។

៣- ព្រះញាណវង្ស ចាន់-គង់ ជន្មាយុ៦៣ឆ្នាំ វស្សា៣៨ រាជាគណៈសម្រាប់ត្រី នៅវត្តបទុមវតី ក្រុងភ្នំពេញ ទីរាជាគណៈសម្រាប់ទោមានគោរម្យងារជា " ព្រះអរិយកស្សប " ជំនួសព្រះអរិយកស្សប កែវ អ៊ុច ដែលឡើងជាទីរាជាគណៈសម្រាប់ឯក ។

៤- ព្រះអមរកិរក្ខិត ឡុង-ណារ ជន្មាយុ ៤៩ឆ្នាំ វស្សា ២៧ រាជាគណៈសម្រាប់ចត្វា នៅវត្តបទុមវតី ក្រុងភ្នំពេញ ជាទីរាជាគណៈសម្រាប់ត្រី មានគោរម្យងារជា "ព្រះញាណវង្ស" ជំនួសព្រះញាណវង្ស តាន់-គង់ ដែលឡើងជាទីរាជាគណៈសម្រាប់ត្រី ។

៥- ព្រះញាណវីរិយៈ ពាន់-សាឌុម ជន្មាយុ ៥៤ ឆ្នាំ វស្សា ៣៤ រាជាគណៈសម្រាប់ចត្វា នៅវត្តនួនមណីរាម ក្រុងភ្នំពេញ ជាទីរាជាគណៈសម្រាប់ត្រី មានគោរម្យងារជា "ព្រះមហាវិរវង្សាចារ្យ" ជំនួសព្រះមហា-វិរវង្សាចារ្យ ប៉ុ-ជា ដែលឡើងជាទីរាជាគណៈសម្រាប់ទោ ។

៦- ព្រះគ្រូមហាបទុម កែវ-ស៊ុមន៍ ជន្មាយុ ៤១ឆ្នាំ វស្សា ២១ ទីឋានានុក្រមនៅវត្តបទុមវតី ក្រុងភ្នំពេញ ជាទីរាជាគណៈសម្រាប់ចត្វា មានគោរម្យងារជា "ព្រះអមរកិរក្ខិត" ជំនួសព្រះអមរកិរក្ខិត ឡុង-ណារ ដែលឡើងជាទីរាជាគណៈសម្រាប់ត្រី ។

៧- ព្រះគ្រូធម្មធីរមុនី ចិន-ចេង ជន្មាយុ ៥៨ ឆ្នាំ វស្សា ៣៥ ទីឋានានុក្រម នៅវត្តប្រយុរវង្សារាម ក្រុងភ្នំពេញ ជាទីរាជាគណៈសម្រាប់ចត្វាមានគោរម្យងារជា « ព្រះញាណវីរិយៈ » ជំនួសព្រះញាណវីរិយៈ ពាន់-សាឌុម ដែលឡើងជាទីរាជាគណៈសម្រាប់ត្រី ។

## អំពីការតាំងមន្ត្រីសង្ឃទីបរិនាគុក្រម

-បានតាំងភិក្ខុ ទិត អ៊ិន វត្តព្រៃធុក ឃុំស្វាយកាយាន ស្រុកស្វាយទាប ខេត្តស្វាយរៀង ឲ្យឡើងជាទីវិន័យធរ អនុគណក្នុងស្រុកស្វាយទាប ។

-បានតាំងភិក្ខុ អ៊ុម-អាំ វត្តព្រៃអង្គុញ ឃុំប្រកម្មេស ស្រុកស្វាយទាប ខេត្តស្វាយរៀង ឲ្យឡើងជាទីព្រះសមុហ៍អនុគណ ក្នុងស្រុកស្វាយទាប ។

## អំពីការតាំងចៅអធិការ

-បានតាំងភិក្ខុ ស្វាយ-គុន នាមឆាយាចន្ទសារោ គណៈធម្មយុត្តិកនិកាយ ឲ្យឡើងជាចៅអធិការ វត្តសាលា ឃុំកូមិធំ ស្រុកល្វាឯម ខេត្តកណ្ដាល ។

-បានតាំងភិក្ខុ ចន្ទ-ឡាច ឲ្យឡើងជាទីចៅអធិការ វត្តពោធិវង្ស ឃុំទឹកវិល ស្រុកស្អាង ខេត្តកណ្ដាល ។

-បានតាំងភិក្ខុ ទៀង សំ ឲ្យឡើងជាទីចៅអធិការ វត្តវាលមាស ឃុំវាលចេញ ស្រុកព្រៃនប់ ខេត្តកំពត ។

## វចនានុក្រមសំស្ក្រឹត-ខ្មែរ

( តទៅ )

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

អញ្ជលិ បុ. អញ្ជលី, ក្រពុំម្រាមដៃ ។ *អញ្ជលី-កម្ម* នមស្ការ, *អញ្ជលី ពន្ធ* នមស្ការ ។ - *កម្ម* នបុ. កិរិយាធ្វើអញ្ជលី ។ - *ការិកា* ស្ត្រី. ទេវរូបតូចៗធ្វើពីដី ។ - *បាត* បុ. កិរិយានមស្ការ ។ - *បុដ* បុ. នបុ កំបង់នៃអញ្ជលី ។ - *ប្រគ្រហ* គុ. ដែលផ្គងអញ្ជលី ។

អញ្ជលិក បុ. ព្រួញមួយបែប ។ អញ្ជលិកា ស្ត្រី. កណ្តុរញីតូចៗ ។

អញ្ជសា ក្រិ.វិ. ដោយត្រឹមត្រូវ ដោយត្រង់; មួយរំពេច ។

អញ្ជីរ បុ. ដើម ឬ ផ្លែមក្លៀ, ដើម ឬ ផ្លែក្របែក ។

អញ្ជោ-គតិ គុ. (សរ) ដែលហើរត្រង់ ។

អដ៍ ធាតុ. អដតិ. អដតេ; អដិតុំ អដិត្វា ។ ដើរត្រេច ,ស្វះស្វែង ។

អដន នបុ. កិរិយាដើរត្រេច, កិរិយាត្រេចត្រាត់ ។

អដនិ ឬ អដនី ស្ត្រី. ចុងបំផុតនៃធ្នូ ។

អដវិក បុ. អ្នកព្រៃ, អ្នកថ្មើរព្រៃ ។

អដវិ ស្ត្រី. ព្រៃ; ក្រុងសាវត្ថី ។ - *ប្រាយ-ប្រាន្តតា* ស្ត្រី. ភាវៈនៃទីប្រទេសនៃ...ដែលព័ទ្ធជុំវិញដោយព្រៃ ។ - *ពល* នបុ. "ពលនៃព្រៃ" ពួកពលស ។

(មានត)